សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

ការគ្រប់គ្រងឥណទានគេហដ្ឋាន

កម្មសិក្សាពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **លី ច័ន្ទសុជាតិ**
ស៊ុន ស្រីលាភ

សាស្ត្រាចារ្យណែនាំ
លោក **សួន ចំរើន**

ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេររបាយការណ៍ ២០១៩

សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ លី ច័ន្ទសុជាតិ និងស៊ុន ស្រីលាភ ជានិស្សិតថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៣ ឆ្នាំសិក្សា២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

- លោកឪពុក និងអ្នកម្តាយ អ្នកមានគុណទាំងទ្វេនៃយើងទាំងពីរ ដែលបានផ្តល់កំណើតដល់កូនៗ ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ទាំងបួន ព្រមទាំងខិតខំអស់ពីកម្លាំងកាយ និងកម្លាំងចិត្តដើម្បីផ្គត់ផ្គង់ ទំនុកបំរុងទាំងសម្ភារៈ និងថវិកាដល់កូនៗចាប់តាំងពីថ្នាក់ចំណេះដឹងទូទៅ ដល់ថ្នាក់ឧត្តមសិក្សា និងរហូតឱ្យយើងខ្ញុំក្លាយទៅជាធនធានមនុស្សសម្រាប់ប្រទេសជាតិ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីប្រធាន អនុប្រធានការិយាល័យស្រាវជ្រាវ សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹងគ្រប់បែបយ៉ាង និងផ្តល់នូវដំបូន្មានល្អៗដល់យើងខ្ញុំ។
- លោកសាស្ត្រាចារ្យ សួន ចំរើន ដែលជាសាស្ត្រាចារ្យទទួលបន្ទុកផ្ទាល់លើការដឹកនាំក្រុមយើងខ្ញុំក្នុងការសរសេរនូវរបាយការណ៍កម្មសិក្សានេះ ដោយលោកបានចំណាយទាំងកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការពន្យល់ណែនាំ និងផ្តល់នូវវិធីសាស្ត្រល្អៗ ព្រមទាំងជួយកែលម្អ និងកែសម្រួលរាល់កំហុសខុសឆ្គងទាំងឡាយ ដើម្បីឱ្យរបាយការណ៍កម្មសិក្សានេះកាន់តែល្អប្រសើរ។
- លោកអនុប្រធាននាយកប្រតិបត្តិ និងជាប្រធាននាយកប្រតិបត្តិធនធានមនុស្សនៃធនាគារប្រៃសណីយ៍កម្ពុជា ក.អ និងលោកនាយកធនាគារ ព្រមទាំងបុគ្គលិកទាំងអស់នៃធនាគារប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ដែលបានផ្តល់ឱកាសដល់យើងខ្ញុំចុះស្រាវជ្រាវកម្មសិក្សា និងពន្យល់ណែនាំរាល់ចម្ងល់ទាំងឡាយដែលយើងខ្ញុំមាន។
- ញាតិមិត្ត បងប្អូន និងមិត្តរួមថ្នាក់ដែលបានផ្តល់ជាកម្លាំងចិត្តក្នុងការរៀបចំរបាយការណ៍កម្មសិក្សាមួយនេះឡើង។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមជូនពរដល់អ្នករាល់គ្នានូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

អារម្ភកថា

សៀវភៅ ដែលលោក លោកស្រីសាស្ត្រាចារ្យ និស្សិត និងអ្នកស្រាវជ្រាវកំពុងតែអាននេះ គឺជាសម្ទិផលនៃការខិតខំប្រឹងប្រែងស្រាវជ្រាវ និងរៀបរៀងដោយយើងខ្ញុំទាំងពីរនាក់ ដែលជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ជំនាន់ទី១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានតួនាទីក្នុងការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទ "**ការគ្រប់គ្រងឥណទានគេហដ្ឋាន**" នៅធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ក្នុងគោលបំណងសរសេររបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា។

ដោយយើងខ្ញុំសម្លឹងមើលឃើញថា សេដ្ឋកិច្ចនៃប្រទេសកម្ពុជានាពេលបច្ចុប្បន្នមានការរីកចម្រើនជាលំដាប់ ជាពិសេសវិស័យអចលនទ្រព្យមានសំទុះគួរឱ្យកត់សម្គាល់។ វិនិយោគិនភាគច្រើនកំពុងតែចាប់អារម្មណ៍ទៅលើវិស័យមួយនេះ ដោយពួកគេធ្វើការជួញដូរនូវអចលនទ្រព្យជាពិសេស លំនៅដ្ឋាន។ ស្របពេលនេះផងដែរ មានធនាគារជាច្រើន មិនថាធនាគារក្នុងស្រុក ឬធនាគារអន្តរជាតិដែលប្រកបអាជីវកម្មនៅកម្ពុជា សុទ្ធតែមានផ្តល់នូវសេវាកម្មឥណទានគេហដ្ឋានដែលមានលក្ខណៈពិសេសរៀងៗខ្លួន ដើម្បីជួយសម្រួលដល់សាធារណជន។

អាស្រ័យហេតុនេះហើយ យើងខ្ញុំក៏បានរៀបរៀងនូវសៀវភៅនេះឡើង ហើយក៏សង្ឃឹមថារបាយការណ៍កម្មសិក្សាមួយនេះនឹងជួយពង្រីកចំណេះដឹងបន្ថែម ក៏ដូចជាតម្កល់ទុកជាឯកសារស្រាវជ្រាវបន្តសម្រាប់មិត្តនិស្សិតរួមជំនាន់ និស្សិតជំនាន់ក្រោយ ព្រមទាំងមិត្តនិស្សិតទាំងឡាយណាដែលមានចំណាប់អារម្មណ៍នឹងប្រធានបទដែលកំពុងពេញនិយមមួយនេះ។

ជាទីបញ្ចប់ យើងខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំងដែលរបាយការណ៍ស្រាវជ្រាវរបស់យើងខ្ញុំបានចេញជារូបរាង និងជាប្រយោជន៍ដល់និស្សិតជំនាន់ក្រោយ។ យើងខ្ញុំជឿជាក់ថារបាយការណ៍ស្រាវជ្រាវមួយនេះប្រាកដជានៅមានចំណុចខ្វះខាត និងកំហុសឆ្គងផ្សេងៗ ដែលអ្នកអាន អ្នកស្រាវជ្រាវទាំងឡាយយល់ថាមិនទាន់សមស្របនឹងត្រូវកើតមានឡើង។ យើងខ្ញុំទទួលស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយពីសំណាក់លោក លោកស្រីបណ្ឌិត លោក លោកស្រីសាស្ត្រាចារ្យ និស្សិត និងអ្នកស្រាវជ្រាវទាំងអស់ ដើម្បីញ៉ាំងឱ្យរបាយការណ៍របស់និស្សិតជំនាន់ក្រោយៗទៀត ក្លាយជារបាយការណ៍ស្រាវជ្រាវមួយដែលមានខ្លឹមសារត្រឹមត្រូវជាសារវ័ន្ត និងមានអត្ថប្រយោជន៍។

មាតិកា

បញ្ជីអក្សរកាត់ vi

បញ្ជីតារាង vii

បញ្ជីរូបភាព viii

បញ្ជីដ្យាក្រាម ix

បញ្ជីឧបសម្ព័ន្ធ x

សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ១

៣. គោលបំណងនៃការស្រាវជ្រាវ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ២

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៣

ជំពូកទី១ ៖ រំលឹកទ្រឹស្តី

១.១. ធនាគារពាណិជ្ជ ៦

១.១.១. ប្រវត្តិនៃការកកើតធនាគារ ៦

១.១.២. និយមន័យ ៧

១.១.៣. តួនាទីរបស់ធនាគារពាណិជ្ជ ៨

១.១.៣.១. តួនាទីអន្តរការី ៨

១.១.៣.២. តួនាទីទូទាត់ ៨

១.១.៣.៣. តួនាទីជាអ្នកធានា ៨

១.១.៣.៤. តួនាទីគ្រប់គ្រងហានិភ័យ ៨

១.១.៣.៥. តួនាទីជាធនាគារវិនិយោគ ៨

១.១.៣.៦. តួនាទីផ្តល់ប្រឹក្សាសម្រាប់ការសន្សំ និងវិនិយោគ ៩

១.១.៣.៧. តួនាទីការពារ និងបញ្ជាក់តម្លៃ ៩

១.១.៣.៨. តួនាទីជាភ្នាក់ងារ ៩

១.១.៣.៩. តួនាទីក្នុងគោលនយោបាយ ៩

១.២. លក្ខណៈទូទៅនៃឥណទាន ៩
១.២.១. និយមន័យឥណទាន ៩
១.២.២. លក្ខណៈពិសេសនៃឥណទាន ៩
១.២.៣. ប្រភេទនៃឥណទាន ១០
១.២.៣.១. ឥណទានឯកជន ១០
១.២.៣.២. ឥណទានសាធារណៈ ១០
១.២.៤. គូនាទីឥណទាន ១០
១.២.៤.១. ឥណទានផ្តល់ដល់អ្នកប្រើប្រាស់ ១០
១.២.៤.២. ឥណទានផ្តល់ដល់ធុរកិច្ច ១០
១.២.៤.៣. ឥណទានផ្តល់ដល់សេដ្ឋកិច្ច ១១
១.៣. ដំណើរការនៃការផ្តល់ឥណទាន ១១
១.៣.១. ជំហានទី១៖ ការទទួលស្វាគមន៍អតិថិជន ១១
១.៣.២. ជំហានទី២៖ ការបំពេញពាក្យសុំខ្ចីឥណទាន ១១
១.៣.៣. ជំហានទី៣៖ ការចុះអង្កេត និងវាយតម្លៃអតិថិជន ១២
១.៣.៤. ជំហានទី៤៖ ការអនុម័តឥណទាន ១២
១.៣.៥. ជំហានទី៥៖ ការរៀបចំឯកសារឥណទាន ១៣
១.៣.៦. ជំហានទី៦៖ ការបញ្ចេញឥណទាន ១៤
១.៣.៧. ជំហានទី៧៖ ការតាមដានឥណទាន ១៤
១.៣.៨. ជំហានទី៨៖ ការសងឥណទានត្រឡប់មកវិញ ១៥
១.៤. ចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ១៦
១.៤.១. ការធ្វើចំណាត់ថ្នាក់ឥណទាន ១៦
១.៤.២. ការធ្វើសំវិធានធន ១៦
១.៥. ការគ្រប់គ្រងហានិភ័យឥណទាន ១៧
១.៥.១. និយមន័យហានិភ័យឥណទាន ១៧
១.៥.២. មូលហេតុដែលធ្វើឱ្យមានហានិភ័យ ១៧
១.៥.២.១. កត្តាអតិថិជន ១៧
១.៥.២.២. កត្តាធនាគារ ១៨
១.៥.២.៣. កត្តាសង្គម និងធម្មជាតិ ១៩

១.៥.៣. ការគ្រប់គ្រងហានិភ័យឥណទាន ១៩
១.៥.៣.១. ហានិភ័យនៃអ្នកធានា ២០
១.៥.៣.២. ហានិភ័យនៃវត្ថុបញ្ចាំ ២១
ក. ហានិភ័យនៃវត្ថុធានាដែលជាអចលនទ្រព្យ ២១
ខ. ទ្រព្យសកម្មដែលអាចដាក់ជាវត្ថុធានាបាន ២១

ជំពូកទី២៖ ស្ថានភាពទូទៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

២.១. ប្រវត្តិសង្ខេបរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ២២
២.២. អត្តសញ្ញាណ និងស្លាកសញ្ញារបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ២៤
២.៣. ចក្ខុវិស័យ និងបេសកកម្ម ២៤
២.៣.១. ចក្ខុវិស័យ ២៤
២.៣.២. បេសកកម្ម ២៤
២.៣.៣. តម្លៃស្នូល "RICE" ២៤
២.៤. ផលិតផល និងសេវាកម្ម ២៥
២.៥. ទីតាំងភូមិសាស្ត្ររបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ២៦
២.៦. ទីតាំងភូមិសាស្ត្ររបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ២៦
២.៧. រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ២៧

ជំពូកទី៣៖ ការគ្រប់គ្រងឥណទានគេហដ្ឋានរបស់
ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា

៣.១. លក្ខណៈទូទៅនៃឥណទានគេហដ្ឋាន ២៨
៣.១.១. និយមន័យ ២៨
៣.១.២. គោលបំណង ២៨
៣.១.៣. អត្ថប្រយោជន៍ ២៨
៣.១.៣.១. សម្រាប់ធនាគារ ២៨
៣.១.៣.២. សម្រាប់អតិថិជន ២៨
៣.១.៣.៣. សម្រាប់សង្គម ២៨
៣.១.៤. ទីផ្សារគោលដៅ ២៨
៣.១.៥. ទីតាំងនៃទីផ្សារគោលដៅ ២៩
៣.១.៦. ផលិតផលឥណទានគេហដ្ឋាន ២៩

៣.១.៦.១. ទំហំនៃការផ្តល់ឥណទាន ២៩
៣.១.៦.២. រយៈពេលឥណទាន ២៩
៣.១.៦.៣. អត្រាការប្រាក់ ២៩
៣.១.៦.៤. សោហ៊ីយ និងកម្រៃ ៣០
៣.១.៦.៥. វិធីសាស្ត្រនៃការសងត្រឡប់ និងការកត់ត្រា ៣០
៣.២. លក្ខខណ្ឌតម្រូវសម្រាប់ឥណទានគេហដ្ឋាន ៣០
៣.២.១. លក្ខខណ្ឌសម្រាប់អ្នកខ្ចី ៣០
៣.២.២. ការលើកលែង/ព្រំដែនក្នុងការផ្តល់ឥណទាន ៣១
៣.២.៣. ទ្រព្យធានា ៣២
៣.២.៤. អ្នកធានា ៣៣
៣.២.៥. ការទិញធានារ៉ាប់រង ៣៣
៣.២.៦. ការរៀបចំឯកសារ ៣៣
៣.២.៧. ការខកខានសង និងការផាកពិន័យ ៣៥
៣.៣. នីតិវិធីឥណទានគេហដ្ឋាន ៣៦
៣.៤. ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ៣៨
៣.៤.១. ការធ្វើចំណាត់ថ្នាក់ឥណទាន ៣៩
៣.៤.១.១. និយមន័យ ៣៩
៣.៤.១.២. ប្រភេទនៃចំណាត់ថ្នាក់ឥណទាន ៣៩
៣.៤.២. ការធ្វើសំវិធានធន ៤០
៣.៤.២.១. ការធ្វើសំវិធានធនទូទៅ ៤០
៣.៤.២.២. ការធ្វើសំវិធានធនជាក់លាក់ ៤០
៣.៤.៣. ការលុបចោលបំណុលចេញពីបញ្ជី ៤០
៣.៤.៤. ឥណទានរៀបចំឡើងវិញ ៤១
៣.៥. ការគ្រប់គ្រងហានិភ័យឥណទានគេហដ្ឋាន ៤២
៣.៥.១. កត្តាដែលបណ្តាលអោយមានហានិភ័យឥណទាន ៤២
៣.៥.២. យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ៤២
៣.៥.៣. ដំណោះស្រាយបញ្ហាឥណទានគេហដ្ឋាន ៤៤
៣.៦. ការវិភាគទិន្នន័យ ៤៤

៣.៦.១. ការវិភាគលើសមតុល្យឥណទានគេហដ្ឋានសរុប ៤៥
៣.៦.២. ការវិភាគលើសមតុល្យឥណទានគេហដ្ឋានដែលសងយឺត..... ៤៦
៣.៧. ចំណុចខ្លាំង និងចំណុចខ្សោយ.....៤៧
៣.៧.១. ចំណុចខ្លាំង ៤៧
៣.៧.២. ចំណុចខ្សោយ ៤៧

សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន..... ៤៩
២. ការផ្តល់អនុសាសន៍ ៥០
ឯកសារយោង
ឧបសម្ព័ន្ធ

បញ្ជីអក្សរកាត់

- CASA = Current Account and Saving Account
- CBC = Credit Bereau Cambodia
- CDV = Cash Disbursement Voucher
- EMI = Equated Monthly Installment
- EMP = Equated Monthly Principle
- LTV = Loan To Value

បញ្ជីតារាង

តារាង ៣.១៖ សមតុល្យឥណទានគេហដ្ឋានសរុប

តារាង ៣.២៖ សមតុល្យឥណទានគេហដ្ឋានដែលសងយឺត

បញ្ជីរូបភាព

រូបភាព ២.១៖ ភាគទុនិកនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

រូបភាព ២.២៖ ស្លាកសញ្ញានៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

រូបភាព ២.៣៖ ទីតាំងភូមិសាស្ត្ររបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា

បញ្ជីដ្យាក្រាម

ដ្យាក្រាម ៣.១៖ សមតុល្យឥណទានគេហដ្ឋានសរុប
ដ្យាក្រាម ៣.២៖ សមតុល្យឥណទានគេហដ្ឋានដែលសងយឺត

បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

- ពាក្យស្នើសុំខ្ចីឥណទាន
    - o កិច្ចសន្យាធានា
    - o កិច្ចសន្យាខ្ចីប្រាក់ (ឥណទានគេហដ្ឋាន)
    - o លិខិតស្នើសុំរក្សាទុកឯកសារកម្មសិទ្ធិនៅធនាគារ
    - o កិច្ចសន្យាបង្កើតហ៊ីប៉ូតែក
    - o កិច្ចសន្យាដាក់បញ្ចាំ
    - o កិច្ចសន្យាព្រមព្រៀងទូទាត់លើការទិញ លក់ គេហដ្ឋាន
    - o កំណត់ហេតុស្តីពីការចុះត្រួតពិនិត្យ និងវាយតម្លៃទ្រព្យ
    - o សម្រង់ព័ត៌មាន និងគម្រោងជំនួញ (ឥណទានទំហំធំជាង ៥០.០០០ដុល្លារ ឬសមមូល)
    - o សម្រង់ព័ត៌មាន និងគម្រោងជំនួញ (ឥណទានទំហំធំជាង ១០.០០០រហូតដល់ ៥០.០០០ដុល្លារ ឬសមមូល)
    - o សម្រង់ព័ត៌មានការទិញគេហដ្ឋានរបស់អតិថិជន
    - o ការយល់ព្រមរបស់អ្នកខ្ចីប្រាក់ចំពោះធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
- ការខកខានសងប្រាក់

ឧបសម្ព័ន្ធទី២

កម្រងសំណួរពាក់ព័ន្ធទៅនឹងការគ្រប់គ្រងឥណទានគេហដ្ឋាន

សេចក្តីផ្តើម

សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីរំដោះខ្លួនចេញពីសង្គ្រាមផ្ទៃក្នុងអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ប្រទេសកម្ពុជាបានក្លាយខ្លួនជាប្រទេសកំពុងអភិវឌ្ឍមួយទៅលើគ្រប់វិស័យ។ វិស័យសេដ្ឋកិច្ចមានភាពរីកចម្រើនផងដែរ ដោយសារតែស្ថាប័នហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ និងជាកម្លាំងចលករជម្រុញឱ្យប្រព័ន្ធសេដ្ឋកិច្ចមានភាពរឹងមាំ។ ភាពរីកចម្រើននៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនបានធ្វើឱ្យតម្រូវការមានការកើនឡើង ហើយអ្វីដែលមនុស្សខ្វះមិនបាននោះគឺ "ជម្រក" ដែលវាជាតម្រូវការចម្បងរបស់មនុស្ស។ ដោយតម្រូវការមានការកើនឡើងជាលំដាប់ ជាហេតុនាំឱ្យតម្លៃនៃគេហដ្ឋាននីមួយៗមានការកើនឡើងឥតឈប់ឈរ ហើយប្រជាជនមួយចំនួនពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទិញ ឬសាងសង់គេហដ្ឋាន។ ទាំងនោះហើយជាមូលហេតុចម្បងដែលធ្វើឱ្យអ្នកវិនិយោគខាងវិស័យអចលនទ្រព្យ និងស្ថាប័នហិរញ្ញវត្ថុភាគច្រើន បានបែរទៅយកចិត្តទុកដាក់លើការផ្តល់ឥណទានគេហដ្ឋាន។ សព្វថ្ងៃនេះ សេវាឥណទានគេហដ្ឋានជាផលិតផលមួយដែលពេញនិយមសម្រាប់ប្រជាជនទូទៅ ព្រមទាំងជាផលិតផលមួយដែលមានទីផ្សារប្រកួតប្រជែងផងដែរ ពីព្រោះមានគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុជាច្រើនសុទ្ធតែផ្តត់ផ្គង់នូវផលិតផលនេះ។

ដោយយើងខ្ញុំសង្កេតឃើញពីការកើនឡើងនៃតម្រូវការរបស់ឥណទានគេហដ្ឋាន និងភាពរីកចម្រើនរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកនូវប្រធានបទមួយដែលស្តីអំពី "ការគ្រប់គ្រងឥណទានគេហដ្ឋាន" របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់។

២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រតិបត្តិការដែលជាសកម្មភាពរបស់ធនាគាររួមមាន ៣ធំៗគឺ ការផ្តល់ឥណទាន ការទទួលប្រាក់បញ្ញើ និងការផ្តល់មធ្យោបាយទូទាត់។ ក្នុងចំណោមប្រតិបត្តិការទាំង ៣នេះ ប្រតិបត្តិការដែលធ្វើឱ្យមានចំណូលចម្បងសម្រាប់ធនាគារ គឺការផ្តល់ឥណទានដល់សាធារណជន ពីព្រោះធនាគារទទួលបានការប្រាក់ពីការផ្តល់កម្ចី ដែលក្នុងនោះរួមមានឥណទានគេហដ្ឋានផងដែរ។ ដូច្នេះហើយធនាគារនីមួយៗមានគោលការណ៍គ្រប់គ្រងនូវប្រតិបត្តិការផ្សេងៗគ្នា ដើម្បីទប់ស្កាត់កុំឱ្យធនាគារជួបប្រទះនឹងហានិភ័យដោយការធ្វេសប្រហែស។

ដោយមើលឃើញពីភាពរីកចម្រើននៃប្រតិបត្តិការនេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេច

ចិត្តធ្វើការស្រាវជ្រាវឱ្យបានដឹងអំពីវិធីសាស្ត្រ និងការគ្រប់គ្រងផ្សេងៗនៃឥណទានគេហដ្ឋាន របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ថាតើធនាគារ ធ្វើការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ខ្លួនយ៉ាងដូចម្តេច? តើធនាគារត្រូវមានលក្ខខណ្ឌអ្វីខ្លះ មុននឹងផ្តល់កម្ចីជូនដល់អតិថិជន?

៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃការស្រាវជ្រាវនេះ គឺសម្រាប់ផ្តល់នូវចំណេះដឹងបន្ថែម និងធ្វើឱ្យមានការរីកចម្រើនផ្នែកធនាគារ ដែលទាក់ទងទៅនឹងប្រធានបទ "ការគ្រប់គ្រងឥណទានគេហដ្ឋាន" ។ ដើម្បីឱ្យដឹងកាន់តែច្បាស់អំពីប្រធានបទ ក៏ដូចជាសំណួរដែលបានចោទសួរខាងលើ ក្រុមយើងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ស្វែងយល់ពីស្ថានភាពទូទៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
- ស្វែងយល់ពីលក្ខណៈទូទៅនៃឥណទានគេហដ្ឋាន
- ស្វែងយល់ពីលក្ខខណ្ឌតម្រូវផ្សេងៗក្នុងការផ្តល់ឥណទានគេហដ្ឋាន
- ស្វែងយល់ពីការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
- ស្វែងយល់ពីភាពខ្លាំង និងភាពខ្សោយរបស់ធនាគារ ក្នុងការផ្តល់ឥណទានគេហដ្ឋាន។

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា មានផ្តល់នូវផលិតផល និងសេវាជាច្រើនជូនដល់អតិថិជន ប៉ុន្តែក្រុមយើងខ្ញុំធ្វើការផ្តោតសំខាន់តែទៅលើផលិតផលមួយក្នុងចំណោមផលិតផលរបស់ធនាគារ នោះគឺផលិតផលឥណទានគេហដ្ឋាន។ ក្រុមយើងខ្ញុំនឹងធ្វើការស្រាវជ្រាវទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវសម្រាប់អតិថិជន នីតិវិធីឥណទាន និងការគ្រប់គ្រងហានិភ័យ ព្រមទាំងវិធីសាស្ត្រដោះស្រាយបញ្ហា ដែលយើងខ្ញុំនឹងស្វែងរកទិន្នន័យក្នុងរយៈពេល ៣ឆ្នាំ គឺចាប់ពីឆ្នាំ ២០១៦ រហូតដល់ឆ្នាំ២០១៨។

៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ការគ្រប់គ្រងឥណទានគេហដ្ឋាន" របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ នេះ បានផ្តល់នូវសារៈសំខាន់ដូចជា៖

- ទទួលបានចំណេះដឹងកាន់តែច្បាស់អំពីនីតិវិធីនៃការផ្តល់ឥណទានគេហដ្ឋាន និងការគ្រប់គ្រងឥណទាននេះ

- បង្កើននូវចំណេះដឹងផ្ទាល់ខ្លួនដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែងក្នុងស្ថាប័ន
- ជាចំណេះដឹងថ្មីបន្ថែមសម្រាប់សាធារណៈជនទូទៅ ដើម្បីសិក្សាស្វែងយល់ពីឥណ-ទានគេហដ្ឋាន
- ទុកជាឯកសារតម្កល់សម្រាប់សិស្ស និស្សិតជំនាន់ក្រោយ អំពីការគ្រប់គ្រងឥណទានគេហដ្ឋាន
- ផ្តល់ជាឯកសារសម្រាប់ ក្រសួង មន្ទីរ អង្គការ និងស្ថាប័នពាក់ព័ន្ធនានា ដែលមានបំណងស្វែងយល់ពីឥណទានគេហដ្ឋាន។

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការចងក្រងនូវរបាយការណ៍កម្មសិក្សានេះឡើង គឺយើងបានប្រមូលទិន្នន័យតាមបែបគុណភាព និងបែបបរិមាណ ដែលព័ត៌មានទាំងនោះទទួលបានពីប្រភពទិន្នន័យពីរគឺ ទិន្នន័យចម្បង (Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data) តាមរយៈការចុះសិក្សាស្រាវជ្រាវផ្ទាល់ និងការសាកសួរតាមកម្រងសំនួរដែលបានរៀបចំទុក។

- ទិន្នន័យបន្ទាប់បន្សំ (Secondary Data)
    - ឯកសារគោលលការណ៍ ដែលផ្តល់ដោយគណៈគ្រប់គ្រងនៃធនាគារប្រៃស-ណីយ៍ កម្ពុជា ក.អ សាខាសុវណ្ណា
    - ទ្រឹស្តីដែលទទួលបានមកពីការសិក្សាកន្លងមក និងឯកសាររបស់សាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រសេដ្ឋកិច្ច
    - របាយការណ៍ និងឯកសារបស់ស្ថាប័នដែលពាក់ព័ន្ធទៅនឹងប្រធានបទ
    - សៀវភៅជាភាសាខ្មែរ និងអង់គ្លេសដែលមាននៅក្នុងបណ្ណាល័យ និងឯកសារប្រភពដើមដែលទាក់ទងនឹងឥណទានគេហដ្ឋាន
    - ការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណែត រួមមានគេហទំព័ររបស់ធនាគារ ប្រៃស-ណីយ៍កម្ពុជា ក.អ និងគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជាជាដើម។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវទៅលើប្រធានបទនេះ ត្រូវបានចែកចេញជា៖

- សេចក្តីផ្តើម
- ជំពូកទី១៖ រំលឹកទ្រឹស្តី
- ជំពូកទី២៖ ស្ថានភាពទូទៅនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា

- ជំពូកទី៣៖ ការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

រចនាសម្ព័ន្ធនៃការស្រាវជ្រាវ



ជំពូកទី១

រំលឹកគ្រឹស្ត

ជំពូកទី១
រំលឹកទ្រឹស្តី

១.១. ធនាគារពាណិជ្ជ

១.១.១. ប្រវត្តិនៃការកកើតធនាគារ

[1]ប្រវត្តិនៃការកកើតធនាគារ បានផ្សារភ្ជាប់នឹងប្រវត្តិនៃការរីកចម្រើននៃវិស័យពាណិជ្ជកម្ម។ ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច គឺជាលក្ខខណ្ឌមួយដែលទាមទារនូវការអភិវឌ្ឍរបស់ធនាគារ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ ការអភិវឌ្ឍប្រព័ន្ធធនាគារបានក្លាយជាកាតាលីករក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ធនាគារចាប់ផ្តើមកកើតឡើងតាមរយៈមុខងារប្តូរប្រាក់របស់ជាងមាស។ ចំពោះការចរាចរលុយនៅក្នុងប្រទេសនីមួយៗ និងក្នុងតំបន់នីមួយៗ ជាពិសេសចំពោះពាណិជ្ជកម្មអន្តរជាតិ ទាមទារឱ្យមានការប្តូរប្រាក់នៅតាមច្រកព្រំដែន ដើម្បីបង្កឱ្យមានភាពងាយស្រួលក្នុងការដោះដូរទំនិញ និងសេវាកម្មផ្សេងៗ។ ចំពោះអ្នកដែលរកស៊ីប្តូរប្រាក់ ភាគច្រើនជាអ្នកមាន និងពីមុនមកជាអ្នកផ្តល់កម្ចីក្នុងអត្រាការប្រាក់ខ្ពស់ ឬរក្សាលុយទុកឱ្យអ្នកធ្វើអាជីវកម្មផ្សេងៗ។

ដោយសារតែការប្រើលោហធាតុធ្វើជារូបិយវត្ថុ ដូចនេះម្ចាស់ហាងមាសមានតួនាទីមួយទៀតជាអ្នកប្តូរប្រាក់ និងទូទាត់ជំនួស រក្សារូបិយវត្ថុទុក និងផលិតរូបិយវត្ថុ។ ធនាគារប្រភេទនេះហៅថា ធនាគាររបស់ជាងមាស។

ដំបូងឡើយ ធនាគារទាំងនោះប្រើប្រាស់នូវធនធានរបស់ខ្លួនក្នុងការប្រតិបត្តិ ប៉ុន្តែកត្តានេះមិនស្ថិតស្ថេរយូរអង្វែងនោះទេ។ តាមរយៈប្រតិបត្តិការជាក់ស្តែង ម្ចាស់ធនាគារយល់ឃើញថាជានិច្ចកាលគឺមានអ្នកផ្ញើប្រាក់ និងអ្នកសុំខ្ចីប្រាក់ ហើយម្យ៉ាងទៀតអ្នកផ្ញើប្រាក់ទាំងនោះពុំធ្វើការដកប្រាក់ព្រមគ្នានោះទេ វាធ្វើឱ្យបរិមាណប្រាក់សល់នៅក្នុងធនាគារច្រើន។ ដូចនេះ ម្ចាស់ធនាគារក៏ប្រើប្រាស់នូវប្រាក់ទាំងនោះដើម្បីផ្តល់ជាកម្ចីបន្ថែម ដែលធ្វើឱ្យធនាគារទទួលបានប្រាក់ចំណេញកាន់តែច្រើន។ ដោយសារតែហេតុនេះហើយ ធនាគារក៏ស្វែងរកនូវយុត្តិសាស្ត្រក្នុងការទាក់ទាញអតិថិជនឱ្យមកផ្ញើប្រាក់ឱ្យបានច្រើន ដែលអាចឱ្យការប្រមូលប្រាក់បញ្ញើកាន់តែច្រើនឡើង ដើម្បីផ្តល់កម្ចី តាមរយៈការផ្តល់នូវអត្រាការប្រាក់ជូនដល់អតិថិជនវិញ។

[1] សួន ចំណើន, *រូបិយវត្ថុ និងធនាគារ* (២០១៣), ទំព័រទី៦-៩។

តាមរយៈការរីកចម្រើននៃសេដ្ឋកិច្ច និងបច្ចេកវិទ្យា បានធ្វើឱ្យប្រតិបត្តិការរបស់ធនាគារកាន់តែមានការរីកចម្រើន និងទំនើបឡើង។ ចាប់ផ្តើមពីធនាគារបុគ្គលរហូតដល់ធនាគារភាគហ៊ុន និងបង្កើតឡើងនូវប្រភេទផលិតផលជាច្រើនជូនដល់អតិថិជនរហូតមកទល់សព្វថ្ងៃ។

១.១.២. និយមន័យ

[2]បើយោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធនាគារ គឺជានីតិបុគ្គលដែលមាននីតិសម្បទាពិសេសក្នុងការធ្វើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី។ ប្រតិបត្តិការដែលជាសកម្មភាពធនាគាររួមមាន៖

- ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ដោយមានកម្រៃរាប់បញ្ចូលទាំងឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខា។
- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន។
- ប្រព្រឹត្តិកម្ម និងការដាក់ឱ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឬជារូបិយប័ណ្ណ។

[3]ធនាគារពាណិជ្ជ គឺជាបណ្តុំនៃស្ថាប័នសន្សំដ៏ធំមួយ។ ធនាគារពាណិជ្ជដើរតួនាទីស្រដៀងទៅនឹងស្ថាប័នសន្សំ និងសហគមន៍ផ្តល់ឥណទានដែលទទួលប្រាក់បញ្ញើ និងផ្តល់ប្រាក់កម្ចី។

សរុបមក ធនាគារពាណិជ្ជ គឺជាស្ថាប័នហិរញ្ញវត្ថុមួយប្រភេទ ដែលទទួលប្រាក់បញ្ញើ និងសន្សំពីសាធារណជន ផ្តល់ឥណទានដល់បុគ្គល ឬក្រុមហ៊ុន និងផ្តល់នូវសេវាផ្ទេរប្រាក់ និងទូទាត់ប្រាក់ ព្រមទាំងមានបំណើនូវសេវាកម្មផ្សេងៗទៀតផងដែរ។

[4] យោងតាមប្រកាសនៃធនាគារជាតិនៃកម្ពុជា ស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធនាគារពាណិជ្ជដែលបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេស ដែលមានធនាគារមេមានចំណាត់ថ្នាក់វិនិយោគដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០.០០០.០០០.០០០ រៀល (ពីររយប៊ីលានរៀល)។ ចំពោះធនាគារពាណិជ្ជដែលបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេស ដែលធនាគារមេ

[2] ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, លេខ នស/រកម/១១៩៩/១៣, ០៣ វិច្ឆិកា ១៩៩៩, មាត្រា១ និងមាត្រា២

[3] Anthony S, 2003, "Financial Institution Management", p.24

[4] ប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, លេខ ធ៧ ០១៦ ១១៧ ប្រ.ក, ២៣ មីនា ២០១៦, ប្រការ៣ និងប្រការ៤

មិនមានចំណាត់ថ្នាក់វិនិយោគ និងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ឬជាបុគ្គលម្ចន្ធធនាគារបរទេស ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា៣០០.០០០.០០០.០០០រៀល(បីរយប៊ីលានរៀល)។

១.១.៣. តួនាទីរបស់ធនាគារពាណិជ្ជ[5]

កាលពីសម័យមុន ធនាគារពាណិជ្ជមានមុខងារត្រឹមតែទទួលប្រាក់បញ្ញើ និងផ្តល់ប្រាក់កម្ចីតែប៉ុណ្ណោះ។ ប៉ុន្តែមកដល់សព្វថ្ងៃ ធនាគារសម័យទំនើបបានប្រើប្រាស់នូវតួនាទីជាច្រើន ដើម្បីរក្សានូវការប្រកួតប្រជែង និងឆ្លើយតបទៅនឹងតម្រូវការរបស់សាធារណជន។ តួនាទីទាំងនោះមានចំនួន ៩ សំខាន់ៗដូចជា៖

១.១.៣.១. តួនាទីជាអន្តរការី

ធនាគារមានតួនាទីក្នុងការបំលែងប្រាក់បញ្ញើ ឬសន្សំដែលបានមកពីសាធារណជនឱ្យទៅជាឥណទាន ឬជាកម្ចីសម្រាប់អាជីវកម្ម ព្រមទាំងអ្នកត្រូវការដទៃទៀតដែលមានបំណងវិនិយោគទៅលើអគារថ្មីៗ គ្រឿងបរិក្ខារ និងផលិតផលផ្សេងៗទៀត។

១.១.៣.២. តួនាទីទូទាត់

ធនាគារមានតួនាទីក្នុងការអនុវត្តការទូទាត់លើទំនិញ និងសេវាកម្មជំនួសមុខឱ្យអតិថិជនរបស់ពួកគេ ដូចជាតាមរយៈការបោះពុម្ព ទូទាត់មូលប្បទានបត្រ ផ្ទេរប្រាក់ ការដកប្រាក់ដោយស្វ័យប្រវត្តិ និងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច។

១.១.៣.៣. តួនាទីជាអ្នកធានា

តួនាទីជាអ្នកធានា គឺជាតួនាទីមួយដែលធនាគារធ្វើការធានាពីក្រោយអតិថិជនរបស់ខ្លួនដើម្បីសងបំណុលជំនួសអតិថិជន ដូចជាការបញ្ចេញនូវលិខិតឥណទាន នៅពេលដែលពួកគេគ្មានលទ្ធភាពសងបំណុល។

១.១.៣.៤. តួនាទីជាអ្នកគ្រប់គ្រងហានិភ័យ

ធនាគារផ្តល់នូវសេវាកម្មក្នុងការជួយដល់ការរៀបចំនូវរាល់កិច្ចការទាំងឡាយ ដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុនានា ដើម្បីការពារហានិភ័យនៃការបាត់បង់នូវទ្រព្យសម្បត្តិ។

១.១.៣.៥. តួនាទីជាធនាគារវិនិយោគ

ធនាគារផ្តល់នូវសេវាកម្មក្នុងការជួយដល់រដ្ឋាភិបាល និងស្ថាប័ននានាក្នុងការបង្កើតនូវមូល

[5] Peter S. Rose និង Sylvia C.Hudgins, *Bank Management & Financial Service* [ការគ្រប់គ្រងធនាគារ និងសេវាកម្មហិរញ្ញវត្ថុ], Ninth Edition (New York: McGraw-Hill Companies,Inc., 2013), 9

និធិថ្មី ការទទួលបានការវិនិយោគ និងការស្វែងរកទីផ្សារថ្មីៗក្នុងការវិនិយោគ។

១.១.៣.៦. តួនាទីជាទីប្រឹក្សាសម្រាប់ការសន្សំ និងវិនិយោគ

ធនាគារផ្តល់នូវសេវាកម្មក្នុងការផ្តល់ការប្រឹក្សាយោបល់ដល់អតិថិជន ក្នុងការរៀបចំផែនការហិរញ្ញវត្ថុសម្រាប់គោលដៅរយៈពេលវែងរបស់អតិថិជន ដូចជាការគ្រប់គ្រងចាត់ចែង និងការពារនូវប្រាក់សន្សំរបស់អតិថិជនជាដើម។

១.១.៣.៧. តួនាទីការពារ និងបញ្ជាក់តម្លៃ

ធនាគារបានដើរតួនាទីជា អ្នកថែរក្សាទុកនូវសម្ភារៈមានតម្លៃរបស់អតិថិជនមិនឱ្យបាត់បង់ និងធ្វើការវាយតម្លៃទ្រព្យនោះទៅតាមតម្លៃទីផ្សារជាក់ស្តែង។

១.១.៣.៨. តួនាទីជាឆ្លាក់ទារ

ធនាគារដើរតួនាទីជាអ្នកគ្រប់គ្រង និងការពារទ្រព្យសម្បត្តិជំនួសឱ្យអតិថិជនរបស់ខ្លួនឱ្យមានប្រសិទ្ធិភាពខ្ពស់។

១.១.៣.៩. តួនាទីក្នុងគោលនយោបាយរបស់រដ្ឋាភិបាល

ធនាគារមានតួនាទីក្នុងការបម្រើគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីគ្រប់គ្រងការលូតលាស់ផ្នែកសេដ្ឋកិច្ច និងសម្រេចបាននូវគោលដៅសង្គម។

១.២. លក្ខណៈទូទៅនៃឥណទាន[6]

១.២.១. និយមន័យឥណទាន

ឥណទាន គឺជាការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់ជាបណ្តោះអាសន្នទៅឱ្យអ្នកខ្ចីនូវបរិមាណមួយអាចជាវត្ថុ ឬរូបិយវត្ថុ (លុយ) ជាមួយនឹងការសន្យាសងត្រឡប់វិញដល់ម្ចាស់ទាំងប្រាក់ដើម និងការប្រាក់។

១.២.២. លក្ខណៈពិសេសនៃឥណទាន

ឥណទានមានលក្ខណៈពិសេសចំនួន ៣គឺ៖

- ការផ្ទេរសិទ្ធិលើការប្រើប្រាស់ពីម្ចាស់កម្មសិទ្ធិស្របច្បាប់ទៅឱ្យជនម្នាក់ទៀត។
- ការផ្ទេរសិទ្ធិលើការប្រើប្រាស់នេះ ជាការផ្ទេរសិទ្ធិបណ្តោះអាសន្នតែប៉ុណ្ណោះ។
- នៅពេលដល់ពេលកំណត់ អ្នកខ្ចីត្រូវធ្វើការទូទាត់នូវចំនួនដែលបានខ្ចីជាមួយនឹងផ្លែឈ្នូលនៃកម្ចីនោះ (ការប្រាក់)។

[6] ឈាង ហ៊ីយ, "Credit Management," (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ២៨-៣៤។

១.២.៣. ប្រភេទនៃឥណទាន

១.២.៣.១. ឥណទានឯកជន

ឥណទានឯកជន គឺជាឥណទានដែលប្រើប្រាស់ដោយបុគ្គល និង/ឬអាជីវកម្ម នៅក្នុងគោលបំណងដោះដូរទំនិញ ឬសេវាកម្ម ដោយមានការពន្យាពេលនៃការទូទាត់សាច់ប្រាក់នៅក្នុងវិស័យឯកជននៃសេដ្ឋកិច្ច។ ឥណទានឯកជនចែកចេញជា ២ គឺ៖

- ឥណទានសម្រាប់អ្នកប្រើប្រាស់ ជាការទិញទំនិញ ឬសេវាកម្មពីអ្នកលក់ ដោយមានការសន្យាសងប្រាក់ត្រឡប់វិញនាពេលអនាគត (ទិញជំពាក់)។
- ឥណទានអាជីវកម្ម ជាប្រភេទកម្ចីមួយដែលផ្តល់ឱ្យអាជីវកម្មក្នុងការទិញនូវវត្ថុធាតុដើមសន្និធិ ដោយធ្វើការពន្យានូវពេលវេលានៃការទូទាត់ប្រាក់ត្រឡប់វិញ។

១.២.៣.២. ឥណទានសាធារណៈ

ឥណទានសាធារណៈ គឺជាប្រភេទកម្ចីកម្រិតរដ្ឋាភិបាលសម្រាប់ធ្វើហិរញ្ញប្បទាន (ខ្ចីប្រាក់) ទិញទំនិញ ឬសេវាកម្ម និងកម្មវិធីសុខមាលភាព ការសង្គ្រោះដល់ប្រជាពលរដ្ឋ។

១.២.៤. តួនាទីឥណទាន

ឥណទានបានកំពុងតែក្លាយជាផ្នែកមួយដែលពុំអាចជៀសផុតនៅក្នុងការរស់នៅប្រចាំថ្ងៃ។ ការប្រើប្រាស់ឥណទានអាចនាំមកនូវផលល្អ និងផលអាក្រក់ទាំងពីរយ៉ាង ដែលវាអាស្រ័យទៅលើមូលហេតុនៃតម្រូវការ និងលទ្ធភាពទូទាត់សងរបស់អ្នកខ្ចីតាមពេលកំណត់។

ឥណទានមានតួនាទីយ៉ាងសំខាន់ចំពោះអ្នកប្រើប្រាស់ ធុរកិច្ច ឬអាជីវកម្ម និងសេដ្ឋកិច្ច។

១.២.៤.១. ឥណទានផ្តល់ជល់អ្នកប្រើប្រាស់

ឥណទានបានជួយបង្កើនកម្រិតជីវភាពរស់នៅរបស់អ្នកប្រើប្រាស់ ពីព្រោះពួកគេអាចប្រើប្រាស់ចំណូលនាពេលអនាគតសម្រាប់ផ្គត់ផ្គង់នូវចំណាយលើទំនិញ និងសេវាកម្មដែលត្រូវការ ហើយពួកគេក៏អាចប្រើប្រាស់វាក្នុងការបង្កើននូវប្រាក់ចំណូលនាពេលបច្ចុប្បន្នផងដែរ។ ម្យ៉ាងវិញទៀត ឥណទានអាចជួយដោះស្រាយនូវបញ្ហាអាសន្នបាន ក្នុងករណីដែលអ្នកប្រើប្រាស់ត្រូវការប្រាក់បន្ទាប់ក្នុងការព្យាបាលជម្ងឺផ្សេងៗ។ អ្វីដែលកាន់តែងាយស្រួលនោះគឺ អតិថិជនអាចទូទាត់ចំណាយគ្រប់ទីកន្លែងដោយគ្រាន់តែមាន Credit Cards នៅក្នុងដៃសម្រាប់ទូទាត់ថ្លៃសណ្ឋាគារ ថ្លៃសំបុត្រយន្តហោះ និងចំណាយដទៃទៀតជាច្រើនជំនួសឱ្យសាច់ប្រាក់។

១.២.៤.២. ឥណទានផ្តល់ជល់ធុរកិច្ច

ចំពោះធុរកិច្ច ឥណទានមានតួនាទីយ៉ាងសំខាន់ក្នុងការជួយពង្រីកទីផ្សារតាមរយៈការទិញ

ទំនិញជំពាក់ ដែលផ្តល់នូវភាពងាយស្រួលដល់អាជីវកម្មក្នុងការបង្វិលសាច់ប្រាក់របស់ខ្លួន។ លើសពីនេះទៅទៀត អាជីវកម្មជាច្រើនធ្វើការខ្ចីប្រាក់ពីធនាគារ ដើម្បីធ្វើការពង្រីកដើមទុន និងទំហំអាជីវកម្មរបស់ខ្លួនផងដែរ។

១.២.៤.៣. ឥណទានផ្តល់ដល់សេដ្ឋកិច្ច

ឥណទាន ជាប្រេងរំអិលសម្រាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ឥណទានបង្កើតបានជាចលនាសាច់ប្រាក់ និងជាផ្នែលមួយនៃផលិតកម្មនៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ ឥណទានតែងផ្តល់នូវមធ្យោបាយនានា ដើម្បីឱ្យមានស្ថេរភាពកម្រិតសកម្មភាពសេដ្ឋកិច្ច ដោយធ្វើការកំណត់កម្រិតបន្ទុកហិរញ្ញវត្ថុ (អត្រាការប្រាក់) ខុសៗគ្នា។

១.៣. ដំណើរការនៃការផ្តល់ឥណទាន[7]

មុននឹងផ្តល់ឥណទាន មន្ត្រីឥណទានត្រូវអនុវត្តតាមដំណើរការខាងក្រោម៖

១.៣.១. ជំហានទី១៖ ការទទួលស្វាគមន៍អតិថិជន

នៅពេលមានអតិថិជនចូលមក បុគ្គលិកប្រចាំការនៅការិយាល័យអាចជាភ្នាក់ងារឥណ-ទាន ឬបេឡាករ ឬរដ្ឋបាល នឹង៖

- អញ្ជើញអតិថិជនអង្គុយ និងសួរពីគោលបំណង។
- ពន្យល់ពីក្រុមហ៊ុន ឥណទាន និងវិធីសងត្រឡប់។
- សួរពីប្រវត្តិ និងមុខរបររបស់អតិថិជន។
- ប្រាប់ពីតម្រូវការឯកសារស្របច្បាប់មួយចំនួន។

បើអតិថិជនមានលក្ខណៈមិនគ្រប់គ្រាន់តាមលក្ខខណ្ឌមិនបន្តទំនាក់ទំនង។

បើអតិថិជនមានលក្ខណៈគ្រប់គ្រាន់ បន្តទៅជំហានទី២។

១.៣.២. ជំហានទី២៖ ការបំពេញពាក្យសុំខ្ចីឥណទាន

បន្ទាប់ពីបានធ្វើការពន្យល់ណែនាំ និងពិនិត្យឯកសារមួយចំនួនរួចមក ភ្នាក់ងារឥណទាន ឬបុគ្គលិកធនាគារត្រូវ៖

- រៀបចំទម្រង់ដើម្បីឱ្យអតិថិជនបំពេញ។
- ថតចម្លងអត្តសញ្ញាណប័ណ្ណ និងឯកសារស្របច្បាប់មួយចំនួន។

[7] ឈាង ហ៊ីយ, "Credit Management," (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ឯកសារបន្ថែម។

- កំណត់ពេលវេលាដើម្បីជួបជាមួយនឹងអតិថិជនដល់ផ្ទះ និងកន្លែងធ្វើការដែលភ្នាក់ងារឥណទានចាំបាច់ត្រូវចុះទៅត្រួតពិនិត្យមើល។
- អ្នកទទួលពាក្យ បញ្ជូនទម្រង់ដែលបានបំពេញរួចទៅភ្នាក់ងារឥណទានទទួលខុសត្រូវប្រតិបត្តិការ។

១.៣.៣. ជំហានទី៣៖ ការចុះអង្កេត និងវាយតម្លៃអតិថិជន

ភ្នាក់ងារឥណទានចុះសួរអ្នកជិតខាង កន្លែងធ្វើការ ដោយមិនបង្ហាញសមាសភាព ដើម្បីទទួលបានព័ត៌មានពិត។

ភ្នាក់ងារឥណទានជួបជាមួយអតិថិជនតាមកាលកំណត់ ដោយ៖

- ពិនិត្យសកម្មភាពមុខរបរ និងទ្រព្យសម្បត្តិបញ្ចាំ។
- ធ្វើគម្រោងជំនួញតាមសភាពជាក់ស្តែងនៃមុខរបររបស់អតិថិជន។
- តម្រូវឱ្យអតិថិជនដាក់លិខិតសម្គាល់ច្បាប់ដើមម្ចាស់កម្មសិទ្ធិតម្កល់។
- ចេញបង្កាន់ដៃដាក់តម្កល់ជូនអតិថិជន។
- ជួបអ្នកធានា និងមើលពីស្ថានភាព និងលទ្ធភាពធានា។
- ពន្យល់ពីការទទួលខុសត្រូវរបស់អ្នកធានា។
- សួរព័ត៌មានបន្ថែមរបស់អតិថិជនពីអ្នកធានា និងទំនាក់ទំនងរបស់ពួកគេ។

ភ្នាក់ងារឥណទានបញ្ចប់ការបំពេញ៣សន្លឹកចុងក្រោយនៃពាក្យសុំខ្ចីឥណទាន ដោយវិភាគផ្ទៀងផ្ទាត់ និងវាយតម្លៃនូវចំណុចដូចជា៖

- ប្រវត្តិអតិថិជន ប្រវត្តិនៃការសងពីមុន អត្តចរិត គោលបំណង និងការប្រើប្រាស់។
- លទ្ធភាពសង ដោយមើលទៅលើប្រាក់ចំណូល, កម្រិតជីវភាព និងទំហំទ្រព្យសម្បត្តិទាំងអស់របស់អតិថិជន។
- ទ្រព្យធានាបំណុល និងអ្នកធានាបំណុល។
- ស្ថានភាពទីផ្សារលើមុខរបររបស់អតិថិជន និងការប្រែប្រួលសេដ្ឋកិច្ច និងនយោបាយ។

១.៣.៤. ជំហានទី៤៖ ការអនុម័តឥណទាន

ប្រធានផ្នែកឥណទាន សង្ខេបព័ត៌មានរបស់អតិថិជនជូនទៅសមាជិកគណៈកម្មាធិការផ្នែកឥណទាន ដើម្បីស្នើសុំយោបល់។

គណៈកម្មាធិការឥណទានប្រចាំសាខាផ្តល់យោបល់៖

១. អនុម័តឥណទាន

- ➢ ឥណទានលើសពីការសម្រេចរបស់សាខា
  - ✓ បញ្ជូនទៅការិយាល័យកណ្តាល។
  - ✓ គណៈកម្មាធិការឥណទាននៅការិយាល័យកណ្តាល ធ្វើការវាយតម្លៃ និងសម្រេចចិត្ត រួចបញ្ជូនមកប្រធានផ្នែកឥណទានប្រចាំសាខា។
  - ✓ ប្រធានផ្នែកផ្តល់ចម្លើយ និងមូលហេតុទៅភ្នាក់ងារឥណទាន។

២. បដិសេធការស្នើសុំឥណទាន៖ ប្រធានផ្នែកឥណទានសាខាត្រូវ

- ➢ រក្សាឯកសារមិនអនុម័តទុក។
- ➢ ផ្តល់ចម្លើយ និងមូលហេតុទៅភ្នាក់ងារ។
- ➢ ភ្នាក់ងារផ្តល់ចម្លើយទៅអតិថិជន ដើម្បីបញ្ចប់ទំនាក់ទំនង។

៣. ចុះអង្កេតដើម្បីប្រមូលព័ត៌មានបន្ថែមពីអតិថិជន

បន្ទាប់ពីអនុម័តឥណទាន ភ្នាក់ងារឥណទានផ្តល់ចម្លើយទៅកាន់អតិថិជន ហើយបើសិនជាអតិថិជន៖

- ➢ បដិសេធ: ត្រូវរៀបចំដកប័ណ្ណកម្មសិទ្ធិជូនអតិថិជនវិញ។
- ➢ យល់ស្រប: បន្តទៅជំហានទី៥។

១.៣.៥. ជំហានទី៥៖ ការរៀបចំឯកសារឥណទាន

ភ្នាក់ងារឥណទានត្រូវ៖

- រៀបចំកិច្ចសន្យាខ្ចី បញ្ចាំ ឬផ្ទេរសិទ្ធិ។
- ឱ្យអតិថិជន និងអ្នកធានាផ្ដិតស្នាមមេដៃលើកិច្ចសន្យា និងអត្តសញ្ញាណប័ណ្ណដោយចុះកាលបរិច្ឆេទត្រឹមត្រូវ។
- ឱ្យអតិថិជនយកឯកសារទៅបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន។
- បើអតិថិជនចង់ដកយកប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិច្បាប់ដើម ភ្នាក់ងារត្រូវស្នើសុំបង្ហាន់ដៃតម្កល់ និងឱ្យអតិថិជនផ្ដិតស្នាមមេដៃបញ្ជាក់។

អតិថិជនបញ្ជូនឯកសារឥណទានត្រឡប់មកវិញ បន្ទាប់ពីបានបំពេញតាមការណែនាំរបស់ភ្នាក់ងារឥណទាន។

ភ្នាក់ងារឥណទានពិនិត្យកិច្ចសន្យាឡើងវិញ និងថតចម្លងឯកសារ១ច្បាប់សម្រាប់អតិថិជនបន្ទាប់មក៖

- កំណត់ពេលបញ្ចេញឥណទាន។

- សុំរដ្ឋបាលធ្វើតារាងសងរំលស់ប្រាក់ និងដាក់ប្រាក់សន្សំចំនួន២ច្បាប់។
- រៀបចំសៀវភៅតាមដានការសងប្រាក់ និងការសន្សំប្រាក់។
- បញ្ជូលឯកសារទាំងអស់ទៅប្រធានផ្នែកឥណទាន។

ប្រធានផ្នែកឥណទានធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ពីភាពគ្រប់គ្រាន់និងត្រឹមត្រូវរបស់ឯក-សារអតិថិជនផងដែរ។

- បើមិនគ្រប់គ្រាន់ ភ្នាក់ងារឥណទានពិនិត្យឡើងវិញ។
- បើគ្រប់គ្រាន់ ប្រធានផ្នែកចុះហត្ថលេខាលើតារាងត្រួតពិនិត្យ។

បន្ទាប់ពីប្រធានផ្នែកពិនិត្យរួចរាល់ហើយ បញ្ជូនមកអោយរដ្ឋបាលពិនិត្យម្តងទៀត៖

- បើមិនគ្រប់គ្រាន់ ប្រធានផ្នែកត្រូវយកទៅពិនិត្យម្តងទៀត។
- បើគ្រប់គ្រាន់ រដ្ឋបាលចុះហត្ថលេខាលើតារាងត្រួតពិនិត្យ។

ក្រោយពីបានរដ្ឋបាលចុះហត្ថលេខារួចមក គណនេយ្យករសាខាពិនិត្យ រួច៖

- រៀបចំ cash disbursement voucher (CDV)។
- បញ្ជូលទៅប្រធានសាខាចុះហត្ថលេខាលើតារាងត្រួតពិនិត្យ និងបោះត្រាលលើ CDV។
- បញ្ជូនឯកសារទៅបេឡាករសាខា ឬសាខារងដែលអតិថិជនមកទទួលប្រាក់។

១.៣.៦. ជំហានទី៦៖ ការបញ្ជេញឥណទាន

បេឡាករសាខា ធ្វើការ៖

- ពិនិត្យឈ្មោះ និងរូបថតអ្នកខ្ចី។
- ឱ្យអតិថិជនផ្ដិតស្នាមមេដៃលើ CVD និងតារាងកាលវិភាគសងប្រាក់។
- ជូនតារាងកាលវិភាគសងប្រាក់ទៅអតិថិជន។
- ជូនកិច្ចសន្យាថតចម្លងទៅអតិថិជន។
- ពិនិត្យសៀវភៅការតាមដានការសងប្រាក់ម្តងទៀត រួចជូនទៅអតិថិជនដើម្បីរក្សាទុក។

បេឡាករសាខា ឬសាខារងផ្ដល់ឯកសារឥណទានដល់រដ្ឋបាលដើម្បីរក្សាទុក។

រដ្ឋបាលសាខាចុះក្នុងបញ្ជីតាមដានការប្រគល់ ដកប័ណ្ណសម្គាល់កម្មសិទ្ធិ និងរក្សាទុករាល់ឯកសារឥណទានទាំងអស់។

១.៣.៧. ជំហានទី៧៖ ការតាមដានអតិថិជន

ភ្នាក់ងារឥណទានដែលពាក់ព័ន្ធ៖

- សួរសុខទុក្ខអតិថិជន១សប្តាហ៍យ៉ាងយូរក្រោយពេលចេញឥណទាន និងតាមដានរាល់

ខែ (១ដង/១ខែ)។

- មើលពីការប្រើប្រាស់ឥណទាន និងសួរពីការវិវត្តមុខរបរ។
- សរសេររបាយការណ៍សង្ខេបជូនប្រធានផ្នែក៖
  - o បើអតិថិជនប្រើប្រាស់ឥណទានតាមគោលបំណងត្រឹមត្រូវ នោះអតិថិជនអាចបន្តឥណទានបានជាធម្មតា។
  - o បើអតិថិជនប្រើប្រាស់ឥណទានមិនត្រឹមត្រូវតាមគោលបំណង នោះភ្នាក់ងារស្នើទារបំណុលមកវិញ៖
    - ▪ បើអតិថិជនយល់ស្រប នោះបញ្ចប់ឥណទាន។
    - ▪ បើអតិថិជនបដិសេធ នោះភ្នាក់ងារត្រូវរាយការណ៍ទៅប្រធានផ្នែកជាបន្ទាន់ដើម្បីឱ្យប្រធានផ្នែកចុះជួបអតិថិជន និងដោះស្រាយបញ្ហាតាមគោលការណ៍។

១.៣.៨. ជំហានទី៨៖ ការសងឥណទានត្រឡប់មកវិញ

នៅពេលដែលអតិថិជនមកទូទាត់សងប្រាក់ បេឡាករត្រូវ៖

- ពិនិត្យសៀវភៅតាមដានការសងប្រាក់ និងកត់ត្រាការសង។
- ទទួលប្រាក់ពីអតិថិជន និងចេញប័ណ្ណទទួលប្រាក់ជូនអតិថិជន។
- អោយអតិថិជនផ្ដិតស្នាមមេដៃលើប័ណ្ណទទួលប្រាក់ និងរំលឹកថ្ងៃសងបន្ទាប់។

ប្រសិនបើអតិថិជនមិនមកទូទាត់ប្រាក់ បេឡាករត្រូវ៖

- ពិនិត្យសៀវភៅតាមដានការសងប្រាក់។
- ធ្វើរបាយការណ៍មិនសងប្រាក់អោយភ្នាក់ងារទទួលខុសត្រូវ។
- ភ្នាក់ងារចុះជួប និងសួរពីមូលហេតុមិនសង។
- រំលឹកគោលការណ៍ឥណទាន និងរកដំណោះស្រាយ។

ក. ករណីអតិថិជនសន្យានឹងទូទាត់ប្រាក់ នោះភ្នាក់ងារឥណទានត្រូវ៖

- ➢ ធ្វើកិច្ចសន្យាទូទាត់ប្រាក់ជាថ្មីជាមួយអតិថិជន។
- ➢ ជូនដំណឹងដល់ប្រធានផ្នែកឥណទាន។
- ➢ តាមដានជាប្រចាំ និងចុះរំលឹកជាញឹកញាប់។

ខ. ករណីអតិថិជននៅតែមិនព្រមទូទាត់ នោះភ្នាក់ងារឥណទានត្រូវ៖

- ➢ រាយការណ៍ទៅប្រធានផ្នែក និងគណកម្មការឥណទាន។

- ➢ ប្រធានផ្នែក និងគណកម្មការឥណទានចុះជួបអតិថិជន និងអ្នកធានាដើម្បីរកដំណោះស្រាយថ្មី។
- ➢ ស្នើសាច់ញាតិ ឬអ្នកធានាជួយសងប្រាក់។

១.៤. ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន[8]

១.៤.១. ការធ្វើចំណាត់ថ្នាក់ឥណទាន

ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ត្រូវធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនឱ្យបានលម្អិត ច្បាស់លាស់ និងគ្រប់គ្រាន់ទៅតាមកម្រិតនៃហានិភ័យឥណទានរបស់គ្រឹះស្ថាន។ គ្រឹះស្ថានត្រូវបែងចែកហ្វាស៊ីលីធីតាមប្រភេទ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃលើសមត្ថភាពទូទាត់សងរបស់សមភាគី តាមរយៈប្រភពចំណូលជាក់ស្តែង។

ការចាត់ថ្នាក់ទាំង ៥ប្រភេទមានដូចខាងក្រោម៖

- ធម្មតា៖ មានការទូទាត់សងតាមកាលកំណត់។
- ឃ្លាំមើល៖ បើហួសកាលកំណត់សងអតិបរមារយៈពេល ៣០ថ្ងៃ។
- ក្រោមស្តង់ដារ៖ បើហួសកាលកំណត់សងអតិបរមារយៈពេល ៦០ថ្ងៃ។
- សង្ស័យ៖ បើហួសកាលកំណត់សងអតិបរមារយៈពេល ៩០ថ្ងៃ។
- បាត់បង់៖ បើហួសកាលកំណត់សងអតិបរមារយៈពេល ១៨០ ថ្ងៃ។

១.៤.២. ការធ្វើសំវិធានធន

យោងទៅតាមចំណាត់ថ្នាក់ដែលបានធ្វើខាងលើ កម្រិតអប្បបរមានៃការធ្វើសំវិធានធនត្រូវមានដូចខាងក្រោម ដោយមិនគិតដល់ទ្រព្យសកម្មដែលបានរក្សាទុកជាទ្រព្យសម្រាប់ធានា៖

- ១% នៃហ្វាស៊ីលីធីដុល ដែលបានចាត់ថ្នាក់ ធម្មតា។
- ៣% នៃហ្វាស៊ីលីធីដុល ដែលបានចាត់ថ្នាក់ ឃ្លាំមើល។
- ២០% នៃហ្វាស៊ីលីធីដុល ដែលបានចាត់ថ្នាក់ ក្រោមស្តង់ដារ។
- ៥០% នៃហ្វាស៊ីលីធីដុល ដែលបានចាត់ថ្នាក់ សង្ស័យ។
- ១០០% នៃហ្វាស៊ីលីធីដុល ដែលបានចាត់ថ្នាក់ បាត់បង់។

[8] ប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែមិន, លេខ ធ៧-០១៧-៣៤៤ ប្រក, ០១ ធ្នូ ២០១៧, ប្រការ២ ដល់ប្រការ៤។

ការធ្វើសំវិធានធន ត្រូវបានកត់ត្រានៅក្នុងគណនីរបស់ធនាគារ ហើយត្រូវបានដកចេញពីគណនីចំណេញ-ខាត នៅក្នុងខែដែលត្រូវធ្វើសំវិធានធននេះ។ សំវិធានធនមិនអាចពន្យាទៅគ្រាបន្ទាប់ទៀតទេ។

១.៥. ហានិភ័យឥណទាន

១.៥.១. និយមន័យហានិភ័យឥណទាន

[9] ហានិភ័យឥណទាន គឺជាហានិភ័យដែលអ្នកខ្ចីប្រាក់ខកខានសង ឬមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការសងបំណុលតាមកិច្ចសន្យា។ វាអាចកើតឡើងនៅពេលដែលអតិថិជនមិនអាចសងតាមពេលវេលាកំណត់។ សរុបមក ហានិភ័យឥណទាន គឺជាប្រូបាប៊ីលីតេដែលអាចកើតមានឡើងចំពោះធនាគារ ដែលធ្វើអោយធនាគារ ដែលធ្វើអោយធនាគារទទួលរងនូវការខាតបង់ ដោយសារអតិថិជនរបស់ខ្លួនមិនបានសងបំណុលតាមកិច្ចសន្យា ឬមិនអាចសងបំណុលបាន ឬសងមិនគ្រប់ចំនួនទាំងប្រាក់ដើម និងការប្រាក់។

១.៥.២. មូលហេតុដែលធ្វើអោយមានហានិភ័យឥណទាន

[10]ហានិភ័យ គឺជាហេតុការណ៍ដែលបង្កអោយមានការខូចខាតជាយថាហេតុ។ យោងតាមការសិក្សាស្រាវជ្រាវកន្លងមកបានបង្ហាញថា ហានិភ័យឥណទានអាចកើតមានឡើង គឺដោយសារតែកត្តា៣យ៉ាង៖

១.៥.២.១. កត្តាអតិថិជន

- ការយល់ពីលក្ខខណ្ឌឥណទានខុស ការមិនយកចិត្តទុកដាក់របស់អតិថិជន ដែលធ្វើអោយមិនបានដឹងពីលក្ខខណ្ឌនានាដូចជា មិនបានដឹងពីគម្រោងនៃការសងបំណុលបាត់វិក្កយបត្រ ឬវិក្កយបត្រផ្ញើមិនដល់។
- អ្នកខ្ចីមានគំនិតផ្តេកផ្តួលមិនចង់សងបំណុល បានបង្កើតនូវវប្បធម៌មើលបំណាំគ្នា និងមានបំណងកេងប្រវ័ញ្ចពេលវេលាសងប្រាក់។
- មិនគោរពតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀង និងព្យាយាមបង្កើតបញ្ហា ដើម្បីពន្យាពេលនៃការសងបំណុល។
- អ្នកខ្ចីរួមគំនិតជាក្រុម ឬជាមួយនឹងអ្នកធានាក្នុងការចែករំលែកឥណទាន បន្លំឯកសារ

[9] សួន ចំណើន, ២០០៧, "ស្ថាប័នទីផ្សារ និងហិរញ្ញវត្ថុ", ទំព័រទី៦

[10] Anthony S.,2010, "Credit Risk Measurement In and Out of the Financial Crisis", p24-33

ដើម្បីទទួលបានឥណទាន ក្នុងគោលបំណងយកទៅប្រើប្រាស់ខុសពីទិសដៅជំនួញ ដោយសារខ្លួនកំពុងជួបវិបត្តិហិរញ្ញវត្ថុជាមួយម្ចាស់បំណុលផ្សេង។

- អតិថិជនធ្លាប់មានប្រវត្តិរស់នៅមិនចុះសម្រុងជាមួយសង្គម និងប្រព្រឹត្តល្បែងស៊ីសង អំពើអបាយមុខ ដែលបណ្តាលអោយអន្តរាយទ្រព្យសម្បត្តិ។
- ក្រុមគ្រួសារមានវិបត្តិ និងមានបំណងចង់គេចវេស៖ អតិថិជនមានឆន្ទៈក្នុងការសង ប៉ុន្តែដោយសារមានបញ្ហាកើតឡើងដូចជា សមាជិកក្នុងក្រុមគ្រួសារមានជម្ងឺ ឬមុខរបរមានបញ្ហាដែលជាមូលហេតុនាំឱ្យអតិថិជនបាត់បង់លទ្ធភាពក្នុងការសងបំណុល។
- អតិថិជនអាចត្រូវបានដៃគូ ឬអ្នកវិនិយោគដទៃទៀតបោកប្រាស់។ នៅពេលខ្លះ ដោយសារតែវិនិយោគិន ឬសហគ្រិនទុកចិត្តទៅលើដៃគូវិនិយោគខ្លាំងពេក បណ្តាលអោយពួកគេប្រឈមមុខនឹងការខាតបង់ ដោយសារតែដៃគូវិនិយោគបោកប្រាស់ និងកេងផលចំណេញនៅក្នុងមុខរបរ។
- ការប្រើប្រាស់ប្រាក់ខុសគោលដៅ ដោយអតិថិជនមួយចំនួនបានប្រើប្រាស់ឥណទានដែលបានផ្តល់អោយខុសគោលដៅ ដោយមិនបានយកឥណទានទាំងនោះទៅប្រើប្រាស់ទៅតាមគោលបំណងដែលខ្ចីនោះទេ តែបែរជាយកប្រាក់កម្ចីទាំងនោះទៅប្រព្រឹត្តល្បែង ឬអំពើខុសច្បាប់ផ្សេងៗ។

១.៥.២.២. កត្តាធនាគារ

- កើតឡើងដោយសារអ្នកអោយខ្ចី និងបុគ្គលិកដែលពាក់ព័ន្ធមិនបានយកចិត្តទុកដាក់ទៅលើការងាររបស់ខ្លួន ដូចជាភ្នាក់ងារឥណទានវាយតម្លៃប្រាក់កម្ចីមិនបានត្រឹមត្រូវ និងសិក្សាមិនបានល្អិតល្អន់ពីប្រវត្តិ និងអត្តចរិតអ្នកខ្ចី លំហូរសាច់ប្រាក់ លទ្ធភាពសង និងហានិភ័យដែលពាក់ព័ន្ធ។ កត្តានេះអាចគ្រប់គ្រងបាន តាមរយៈការពង្រឹងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តទៅតាមគោលការណ៍ និងនីតិវិធីស្តីពីឥណទាន។
- ភ្នាក់ងារឥណទាន មិនបានយកចិត្តទុកដាក់បំពេញឯកសារឥណទានអោយបានត្រឹមត្រូវ ឬមិនបានបង្កើតជាកិច្ចព្រមព្រៀងនានាដើម្បីជំនួយ និងជាភស្តុតាងក្នុងការដោះស្រាយបញ្ហាបំណុលដែលអាចនឹងកើតមានឡើង។
- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់ ក្នុងការតាមដានត្រួតពិនិត្យបំណុលអោយទាន់ពេលវេលា។

១.៥.២.៣. កត្តាសង្គម និងធម្មជាតិ

- សង្គម៖ សង្គ្រាម ការប្រែប្រួលសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាល នយោបាយសេដ្ឋកិច្ច។
- វិបត្តិសេដ្ឋកិច្ច៖ កាលណាវិបត្តិសេដ្ឋកិច្ចកើតឡើងនាំអោយក្រុមហ៊ុន សហគ្រាសអាជីវកម្ម ត្រូវប្រឈមមុខនឹងការក្ស័យធន ព្រោះថាតម្រូវការអតិថិជនមានការធ្លាក់ចុះ ដែលជាមូលហេតុធ្វើអោយចំណូលផ្ទាល់ខ្លួន និងចំណូលក្រុមហ៊ុនធ្លាក់ចុះ ដូច្នេះធ្វើអោយក្រុមហ៊ុនមិនមាលទ្ធភាពសងបំណុលអោយធនាគារ។
- គ្រោះធម្មជាតិ៖ ទឹកជំនន់ គ្រោះរាំងស្ងួត ភ្លើងឆេះផ្ទះ ដែលនាំអោយអតិថិជនបាត់បង់លទ្ធភាពសងបំណុល ដោយសារតែអាជីវកម្ម ឬមុខរបរត្រូវបានផ្អាកដំណើរការ។

ធនាគារនៅលើទីផ្សារកំពុងអភិវឌ្ឍន៍ភាគច្រើន ត្រូវបានកត់សម្គាល់ថានៅមិនទាន់មានវិធីសម្រាប់គ្រប់គ្រងហានិភ័យឥណទានអោយមានប្រសិទ្ធភាព ដោយសារកត្តាដូចជា៖

- ការខ្វះនយោបាយឥណទានជាលាយលក្ខណ៍អក្សរ
- បញ្ហាមជ្ឈការ និងវិមជ្ឈការនៃអំណាចក្នុងការអោយខ្ចីហួសព្រំដែន
- ការវិភាគហិរញ្ញវត្ថុពីឧស្សាហកម្ម និងសេដ្ឋកិច្ចនៅទន់ខ្សោយ
- ការវិភាគហិរញ្ញវត្ថុរបស់កូនបំណុលមិនបានជិតដល់
- ការអោយខ្ចីផ្នែកឥណទានវិបារូបរ៍ច្រើនហួសហេតុ
- ការបំពេញបែបបទឥណទានមិនបានសព្វគ្រប់
- ការខ្វះខាតក្នុងការចាត់ថ្នាក់ទ្រព្យសកម្ម
- ការបរាជ័យក្នុងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពលើដំណើរការឥណទាន

ចំណុចខ្វះខាតទាំងនេះនឹងនាំដល់ភាពខ្សោយក្នុងការអោយខ្ចី រួមទាំងការប្រមូលផ្តុំការខ្ចីនៅក្នុងឧស្សាហកម្មតែមួយ ឬផ្នែកនៃសេដ្ឋកិច្ចតែមួយ និងមានបំណុលមិនដំណើរការច្រើនពេក ការខាតបង់ផ្នែកឥណទាន ការខ្វះខាតលទ្ធភាពសងបំណុល និងខ្វះខាតសាច់ប្រាក់ងាយស្រួល។

១.៥.៣. ការគ្រប់គ្រងហានិភ័យឥណទាន

ការគ្រប់គ្រងហានិភ័យឥណទាន គឺជាដំណើរការដែលពាក់ព័ន្ធគ្រប់បុគ្គលិក និងថ្នាក់ដឹកនាំទាំងអស់ត្រូវតែចូលរួម ដើម្បីទប់ស្កាត់ហានិភ័យ ធានាអោយមាននិរន្តភាព។

ការគ្រប់គ្រងហានិភ័យឥណទាន គឺជាដំណើរការនៃការវាស់វែងទៅតាមប្រព័ន្ធដែលងាយស្រួងយល់ជាអាទិភាពសម្រាប់ហានិភ័យ និងការអនុវត្តយុទ្ធសាស្ត្រដើម្បីកាត់បន្ថយហានិភ័យឱ្យនៅកម្រិតទាប។ លទ្ធផលទាំងនោះរួមមាន៖

- ការការពារបញ្ហាដែលមិនទាន់កើតមានឡើង
- រកអោយឃើញសញ្ញាណនៃបញ្ហាតាំងពីដំបូង
- ធ្វើការដោះស្រាយរាល់បញ្ហាដែលកើតមានឡើង

វិធីសាស្ត្រគ្រប់គ្រងហានិភ័យ ត្រូវតែពង្រឹងតាំងពីដំណាក់កាលដំបូងរហូតដល់ទីបញ្ចប់ ដោយប្រមូលព័ត៌មានអោយបានគ្រប់គ្រាន់សម្រាប់ធ្វើការវាយតម្លៃមុននឹងផ្តល់ឥណទាន ហើយបុគ្គលិកទាំងអស់ត្រូវធ្វើការអោយបានម៉ត់ចត់ទៅលើ៖

- ធ្វើការវាយតម្លៃទំហំឥណទានអោយបានត្រឹមត្រូវ
- ធ្វើការអនុម័ត និងទទួលខុសត្រូវ
- រៀបចំឯកសារឥណទាន (ឯកសារឥណទានត្រូវគ្រប់គ្រាន់ ត្រឹមត្រូវ និងទាន់ពេល)
- បញ្ចេញឥណទាន
- តាមដាន និងត្រួតពិនិត្យឥណទាន
- ធ្វើចំណាត់ថ្នាក់ឥណទាន
- ចាត់ចែងធ្វើចំណាត់ថ្នាក់បំណុលមានបញ្ហាដើម្បីប្រមូលត្រឡប់មកវិញ។

១.៥.៣.១. ហានិភ័យនៃអ្នកធានា

ប្រសិនបើភ្នាក់ងារឥណទានធ្វើការសម្រេចចិត្តជ្រើសរើសអ្នកធានាខុស ដូចនេះការផ្តល់ឥណទាននឹងមានផលពិបាក។ ដូចនេះហានិភ័យនៃអ្នកធានាត្រូវបានគេសង្កត់ធ្ងន់ថា ប្រសិនបើអ្នកខ្ចីគ្មានប្រាក់សងទេ អ្នកធានាត្រូវសងជំនួសរហូតដល់អស់បំណុល។

- គុណសម្បត្តិ៖ ការជ្រើសរើសអ្នកធានាដែលមានសក្តានុពលផ្តល់នូវអត្ថប្រយោជន៍៖
  - ងាយស្រួលដោះស្រាយបញ្ហារបស់កូនបំណុលដែលជួបបញ្ហា
  - ទប់ស្កាត់មិនអោយមានបំណុលបាត់បង់
  - រក្សាសុវត្ថិភាពប្រាក់កម្ចី
  - ទីផ្សារមានស្ថេរភាព
  - បង្កើនប្រាក់ចំណេញដល់ស្ថាប័ន
- គុណវិបត្តិ៖ ការជ្រើសរើសអ្នកធានាមិនបានត្រឹមត្រូវ ផ្តល់នូវគុណវិបត្តិដូចជា៖
  - ទីផ្សារទាំងមូលពោរពេញដោយបំណុលបាត់បង់
  - តម្លៃ និងសីលធម៌របស់ភ្នាក់ងារឥណទានធ្លាក់ចុះ ហើយបាត់បង់ការគាំទ្រ។

ដោយសារតែមានគុណវិបត្តិដូចដែលបានរៀបរាប់ខាងលើ ភ្នាក់ងារឥណទានបានធ្វើការពិនិត្យយ៉ាងជិតដល់ទៅលើ៖

- អ្នកធានា៖ ត្រូវយល់ព្រមថាខ្លួនជាអ្នកធានា មិនមែនជាសាក្សីទេ ហើយមានលទ្ធភាពសងបំណុលជំនួសកូនបំណុលបាន១០០% ហើយយល់ព្រមទទួលខុសត្រូវចំពោះរាល់លក្ខខណ្ឌរបស់ធនាគារ។
- អ្នកខ្ចី៖ ត្រូវមានមុខរបរ និងចំណូលដែលអាចសងបំណុលបានគ្រប់១០០% ហើយត្រូវបំពេញ និងគោរពរាល់លក្ខខណ្ឌដែលគោលការណ៍ធនាគារតម្រូវអោយ។

១.៥.៣.២. ហានិភ័យនៃឥត្ថុបញ្ញាំ

ក. ហានិភ័យនៃវត្ថុធានាជាអចលនទ្រព្យ

- ប្រភេទដីដែលមានបញ្ហា
  - ដីរបស់រដ្ឋាភិបាលដែលមានគម្រោងអភិវឌ្ឍន៍ ឬសំណង់អនាធិបតេយ្យ
  - ដីច្រាំងទន្លេ ដីបាតបឹង ដីចិញ្ចឹមផ្ទល់
  - ដីក្នុងបរិវេណសាលារៀន មន្ទីពេទ្យ វត្ត ឬក្រសួងផ្សេងៗ
  - ដីកេរមរតក ដីមានទំនាស់
  - ដីមិនមែនជាកម្មសិទ្ធិផ្ទាល់ខ្លួន ដីដែលពាក់ព័ន្ធនឹងការដាក់បញ្ចាំច្រើន
  - ដីដែលគ្មានតម្លៃលើទីផ្សារ
  - ដីដែលមិនមានតម្លៃគ្រប់គ្រាន់ក្នុងការទូទាត់បំណុល

❖ វិធីការពារ៖ ហានិភ័យលើទ្រព្យធានាតែងតែកើតមានឡើងក្នុងប្រតិបត្តិការជាញឹកញាប់ ដូច្នេះក្នុងការទប់ស្កាត់ហានិភ័យ អ្នកប្រតិបត្តិគ្រប់រូបត្រូវធ្វើការសង្កេតឱ្យបានច្បាស់លាស់មុននឹងធ្វើការសម្រេចចិត្តវាយតម្លៃលើអចលនទ្រព្យរបស់អតិថិជន។

ខ. ទ្រព្យសកម្មដែលអាចដាក់ជាវត្ថុធានាបាន

ផ្ទះដែលត្រូវបានគេចាត់ទុកជាអចលនវត្ថុ ត្រូវជាផ្ទះ៖

- សង់លើដីកម្មសិទ្ធិស្របច្បាប់
- មានទំហំ និងតម្លៃសមរម្យ
- សំណង់ដែលមានលក្ខណៈរឹងមាំ មិនអាចលើកផ្លាស់ទី ឬរុះរើដោយងាយស្រួលបាន។

ជំពូកទី២

ស្ថានភាពទូទៅរបស់

ធនាគារ

ប្រៃសណីយ៍កម្ពុជា ក.អ

សាខាសុវណ្ណា

ជំពូកទី២

ស្ថានភាពទូទៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

២.១. ប្រវត្តិសង្ខេបរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទទួលបានអជ្ញាប័ណ្ណជាធនាគារពាណិជ្ជ និងបានបើកដំណើរការជាផ្លូវការនៅក្នុងខែកញ្ញា ឆ្នាំ ២០១៣ ជាមួយនឹងដៃគូយុទ្ធសាស្ត្ររវាងកាណាឌីយ៉ាអ៊ីនវេសមិនហ្ជលឌីង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កម្ពុជា និងហ្ជូឡឹតុនហ្ជាយណាន់ស៊ីល្យ ហ្ជលឌីង។ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ មានបំណងក្លាយជាធនាគារផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខគេ ជូនអតិថិជនគ្រប់កំរិត ដើម្បីលើកកម្ពស់ជីវភាព និងជួយបំពេញបំណង រីកចម្រើនរបស់ប្រជាជនកម្ពុជា ហើយបង្កើតតម្លៃជានិរន្តដល់ភាគទុនិក បុគ្គលិក និងសង្គម។

ចាប់តាំងពីការបង្កើតឡើងដំបូង ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានចុះបញ្ជីដើមទុន ៣៨ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៣ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ធនាគារ មានការរីកចម្រើនកាន់តែលឿន ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ នៅខែមករា ឆ្នាំ ២០១៧ ធនាគារបានបង្កើនដើមទុនចុះបញ្ជីចំនួន ៥៨ លានដុល្លារអាមេរិក ហើយបន្តកើនឡើងម្តងទៀតនៅក្នុងខែកញ្ញា ឆ្នាំ ២០១៧ រហូតដល់ ៧០.៧៩ លានដុល្លារអាមេរិក ដើម្បីត្រៀមខ្លួនបំពេញតាមតម្រូវការដើមទុនអប្បបរមាក្នុងចំនួន ៧៥ លានដុល្លារអាមេរិកក្រោមបទបញ្ញត្តិថ្មីរបស់ធនាគារជាតិនៃកម្ពុជា ដែលតម្រូវឲ្យធនាគារពាណិជ្ជទាំងអស់អនុវត្តន៍ឲ្យបាននៅមុនដំណាច់ខែមីនា ឆ្នាំ ២០១៨។

- **ដៃគូរយុទ្ធសាស្ត្ររបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ**

កាណាឌីយ៉ាអ៊ីនវេសមិនហ្ជលឌីង

កាណាឌីយ៉ាអ៊ីនវេសមិនហ្ជលឌីង គឺជាក្រុមហ៊ុនធំមួយដែលទទួលបានជោគជ័យបំផុតលើវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដោយមានការវិនិយោគហិរញ្ញវត្ថុក្នុងវិស័យធនាគារ មីក្រូហិរញ្ញវត្ថុ និងធានារ៉ាប់រង សាជីវកម្មខ្នាតធំ សហគ្រាសខ្នាតតូច និងមធ្យម និងអាជីវកម្មផ្សេងៗទៀតទូទាំងប្រទេសកម្ពុជា។ កាណាឌីយ៉ាអ៊ីនវេសមិនហ្ជលឌីង មានបទពិសោធន៍ច្បាស់លាស់នៅក្នុងទីផ្សារកម្ពុជា និងធ្វើប្រតិបត្តិការដោយមានវិន័យ និងប្រកបដោយប្រសិទ្ធភាព។

ហ្ជូឡឹតុនហ្ជាយណាន់ស៊ីល្យហ្ជលឌីង

ហ្ជូឡឹតុនហ្ជាយណាន់ស៊ីល្យហ្ជលឌីង បានធ្វើការវិនិយោគ និងធ្វើប្រតិបត្តិការជាស្ថាប័ន

មួយហិរញ្ញវត្ថុនៅក្នុងទីផ្សារដែលកំពុងរីកចម្រើន ដោយផ្តោតលើការបម្រើសេវាកម្មដល់សហ-គ្រាសខ្នាតតូច និងមធ្យម និងអាជីវកម្មទីផ្សារចម្រុះតាមរយៈការអភិវឌ្ឍន៍ និងប្រតិបត្តិនូវខ្នាតគំរូអាជីវកម្មប្រកបដោយភាពច្នៃប្រឌិតខ្ពស់ និងល្អដាច់គេ។ បច្ចុប្បន្ននេះ ហ្ស្ទ្រីតុនហ្វាយណាន់ស៊ីល្យ ហ្ជលឌីង បានវិនិយោគនៅក្នុងតំបន់អាស៊ីខាងត្បូង តំបន់អាស៊ីអគ្នេយ៍ និងប្រទេសចិន ជាមួយនឹងបណ្តាញសរុបចំនួន ៣,៣០០កន្លែង និងបានផ្តល់សេវាជូនអតិថិជនប្រមាណ ៧លាននាក់។ ហ្ស្ទ្រីតុនហ្វាយណាន់ស៊ីល្យហ្ជលឌីង គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលគ្រប់គ្រងដោយក្រុមហ៊ុនឯកជន (Temasek) លីមីតធីត គឺជាក្រុមហ៊ុនវិនិយោគមួយដែលមានមូលដ្ឋាននៅប្រទេសសិង្ហបុរី។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា គឺជាក្រសួងរបស់រដ្ឋាភិបាលដែលគ្រប់គ្រងប្រព័ន្ធប្រៃសណីយ៍ និងប្រព័ន្ធគមនាគមន៍នៃកម្ពុជា។

<u>រូបភាព ២.១៖</u> ភាគទុនិកនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ



២.២. អត្តសញ្ញាណ និងស្លាកសញ្ញារបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

<u>រូបភាព ២.២</u>៖ ស្លាកសញ្ញានៃធនាគារ ប្រៃសណីយ៍កម្ពុជាក.អ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
東埔寨郵政銀行 CAMBODIA POST BANK PLC.

ស្លាកសញ្ញារបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានអត្ថន័យដូចតទៅ៖

- និមិត្តសញ្ញាពណ៌ទឹកក្រូច ជាសញ្ញាអនន្ត ដែលតំណាងអោយការបំរើសេវាកម្មរបស់ធនាគារជូនដល់អតិថិជនអោយគ្មានព្រំដែនកំណត់
- ឃ្លាពណ៌ខៀវខាងក្រោមនិមិត្តសញ្ញា ជាឈ្មោះរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ជាភាសាខ្មែរ ភាសាចិន និងភាសាអង់គ្លេស។

២.៣. ចក្ខុវិស័យ និងបេសកកម្ម

២.៣.១. ចក្ខុវិស័យ

ជាធនាគារដែលផ្តល់នូវសេវាកម្មហិរញ្ញវត្ថុឈានមុខគេជូនដល់អតិថិជនគ្រប់កម្រិត ដើម្បីលើកកម្ពស់ជីវភាព និងជួយបំពេញបំណងរីកចម្រើនរបស់ប្រជាជនកម្ពុជា ហើយបង្កើតតម្លៃជានិរន្តដល់ភាគទុនិក បុគ្គលិក និងសង្គម។

២.៣.២. បេសកកម្ម

អភិវឌ្ឍផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិតតាមតម្រូវការទីផ្សារ ព្រមទាំងបម្រើសេវាល្អបំផុត ជូនអតិថិជន។

២.៣.៣. តម្លៃស្នូល "RICE"

តម្លៃស្នូលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានដូចជា៖

ការជឿទុកចិត្ត

ផ្តល់នូវភាពជឿជាក់ និងទំនុកចិត្តក្នុងការបម្រើសេវាកម្មជូនអតិថិជន ជាពិសេសគុណភាពនៃផលិតផល និងសេវាកម្ម។

ការច្នៃប្រឌិត

អនុវត្តឲ្យមានប្រសិទ្ធភាពលើការបង្កើតផលិតផល ដំណើរការផ្តល់សេវាកម្ម បច្ចេកវិទ្យា និងគំនិតថ្មីៗ ដើម្បីផ្តល់នូវដំណោះស្រាយសមស្របតាមតម្រូវការរបស់អតិថិជន និងតម្រូវការទីផ្សារគោលដៅ។

ការយកចិត្តទុកដាក់

យកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់ជូនសេវាកម្មដ៏ល្អបំផុតជូនអតិថិជនខាងក្នុង និងអតិថិជនខាងក្រៅដើម្បីកសាង និងរក្សាបាននូវទំនាក់ទំនងយូរអង្វែង។

សហគ្រិនភាព

លើកកម្ពស់ការអនុវត្ត គំនិតថ្មីៗ និងទំនួលខុសត្រូវរវាងបុគ្គលិក ដើម្បីបន្តច្នៃប្រឌិតឲ្យស្របតាមផ្នត់គំនិតរបស់សហគ្រិន។

២.៤. ផលិតផល និងសេវាកម្ម

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្តល់សេវាកម្ម ទទួលប្រាក់បញ្ញើ សេវាផ្ទេរប្រាក់ និងសេវាហិរញ្ញវត្ថុជាច្រើនប្រភេទទៀត ដែលមានប្រភេទរូបិយប័ណ្ណដូចជា៖ ប្រាក់រៀលខ្មែរ (KHR) ប្រាក់ដុល្លារអាមេរិក (USD) និងប្រាក់បាតថៃ (THB) ។

ផលិតផល និងសេវារបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានដូចជា៖

- សេវាឥណទាន
  - ឥណទានកសិកម្ម
  - ឥណទានមិនមែនកសិកម្ម
  - ឥណទានវិបារូបរ៍
  - ឥណទានគ្មានទ្រព្យធានា
  - ឥណទានគេហដ្ឋាន
  - ឥណទានយានយន្ត
- សេវាបញ្ញើសន្សំ
  - គណនីសន្សំ
  - គណនីសន្សំ រីអាយភី
  - គណនីចរន្ត
  - គណនីចរន្ត រីអាយភី

- o គណនីសន្សំរីករាយ
- o គណនីបញ្ញើមានកាលកំណត់
- o គណនីសន្សំ/ចរន្តបានការប្រាក់ខ្ពស់
- o គណនី Trust សម្រាប់អចលនទ្រព្យ

- សេវាផ្សេងៗ
  - o សេវាផ្ទេរប្រាក់
  - o សេវាទូទាត់រហ័ស
  - o សេវាផ្ទេរប្រាក់ក្នុងប្រទេស
  - o សេវាផ្ទេរប្រាក់ក្រៅប្រទេស
  - o សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក

២.៥. ទីតាំងភូមិសាស្ត្រនៃការិយាល័យកណ្តាលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានសាខាសរុបចំនួន ២៧សាខាទូទាំងប្រទេស។ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាការិយាល័យកណ្តាល-រាជធានីភ្នំពេញមានទីតាំងស្ថិតនៅ អគារលេខ ២៦៥-២៦៩ វិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

២.៦. ទីតាំងភូមិសាស្ត្ររបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា-រាជធានីភ្នំពេញ មានទីតាំងស្ថិតនៅ ផ្ទះលេខ D33 ផ្លូវឌីយ៉ាម៉ង់ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

<u>រូបភាព ២.៣៖</u> ទីតាំងភូមិសាស្ត្ររបស់ធនាគារ ប្រៃសណីយ៍កម្ពុជាក.អ សាខាសុវណ្ណា



២.៧. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា



ជំពូកទី៣

ការគ្រប់គ្រងឥណទាន

គេហដ្ឋានរបស់ធនាគារ

ប្រៃសណីយ៍កម្ពុជា ក.ម

សាខាសុវណ្ណា

ជំពូកទី៣
ការគ្រប់គ្រងឥណទានគេហដ្ឋាន
របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា

៣.១. លក្ខណៈទូទៅនៃឥណទានគេហដ្ឋាន

៣.១.១. និយមន័យ

ឥណទានគេហដ្ឋាន គឺជាផលិតផលមួយប្រភេទក្នុងចំណោមផលិតផលជាច្រើនទៀតរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលត្រូវបានបង្កើតឡើងសម្រាប់បំពេញនូវតម្រូវការរបស់សាធារណជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទិញ ឬសាងសង់គេហដ្ឋាននៅលើដីដែលមានស្រាប់។

៣.១.២. គោលបំណង

គោលបំណងតែមួយគត់ដែលធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បង្កើតអោយមានឡើងនូវឥណទានគេហដ្ឋាន គឺដើម្បីបំពេញនូវតម្រូវការរបស់អតិថិជនក្នុងការទិញលំនៅដ្ឋានជាកម្មសិទ្ធិផ្ទាល់ខ្លួនសម្រាប់រស់នៅ។

៣.១.៣. អត្ថប្រយោជន៍

៣.១.៣.១. សម្រាប់ធនាគារ

- ទទួលបានប្រាក់ចំណូលបន្ថែម និងកម្រៃសេវាផ្សេងៗ។
- ធនាគារមានទំនុកចិត្តក្នុងការប្រកួតប្រជែង និងទាក់ទាញអតិថិជន។

៣.១.៣.២. សម្រាប់អតិថិជន

- មានឱកាសក្នុងការទទួលបាននូវគេហដ្ឋានដែលជាកម្មសិទ្ធិផ្ទាល់។
- ទទួលបានកម្ចីក្នុងរយៈពេលវែងក្នុងការទិញ ឬសាងសង់គេហដ្ឋាន។
- ចំណាយតិចទៅលើអត្រាការប្រាក់ និងកម្រៃសេវាផ្សេងៗ។

៣.១.៣.៣. សម្រាប់សង្គម

- ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

៣.១.៤. ទីផ្សារគោលដៅ

ទីផ្សារគោលដៅនៃឥណទានគេហដ្ឋាន រួមមានរូបវន្តបុគ្គលដែលមានប្រាក់ចំណូលពីប្រាក់បៀវត្ស និងបុគ្គលដែលមានអាជីវកម្មផ្ទាល់ខ្លួន ជាពិសេសបុគ្គលនោះត្រូវជាប្រជាជនកម្ពុជា។

៣.១.៥. ទីតាំងនៃទីផ្សារគោលដៅ

ផលិតផលឥណទានគេហដ្ឋាន មានផ្តល់ជូនដល់សាធារណជននៅគ្រប់សាខានៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក្នុងតំបន់នៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែធ្វើការផ្តោតសំខាន់ទៅលើទីតាំង ៤ធំៗគឺរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តព្រះសីហនុ។

៣.១.៦. ផលិតផលឥណទានគេហដ្ឋាន

៣.១.៦.១. ទំហំនៃការផ្តល់ឥណទាន

- **ទំហំឥណទានអប្បបរមា៖** ១៥,០០០ដុល្លារអាមេរិក មិនលើសពី ៧៥% នៃតម្លៃព្រមព្រៀងគ្នានៃគេហដ្ឋានដែលត្រូវទិញ។
- **ទំហំឥណទានអតិបរមា៖** មិនលើសពី ៧៥% នៃតម្លៃព្រមព្រៀងគ្នានៃគេហដ្ឋានដែលត្រូវទិញ៖
  - o នៅតំបន់រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រះសីហនុ
    - ➢ សម្រាប់ប្លង់រឹង ២៥០,០០០ដុល្លារអាមេរិក
    - ➢ សម្រាប់ប្លង់ទន់ ១៥០,០០០ដុល្លារអាមេរិក
  - o នៅតំបន់ផ្សេងពីតំបន់ទាំង៤ខាងលើ
    - ➢ សម្រាប់ប្លង់រឹង ១៥០,០០០ដុល្លារអាមេរិក
    - ➢ សម្រាប់ប្លង់ទន់ ៧៥,០០០ដុល្លារអាមេរិក

អតិថិជនត្រូវមានប្រាក់កក់ ២៥% បង់មុន មុនពេលចាប់ផ្តើមនៃការបញ្ចេញប្រាក់កម្ចីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។

៣.១.៦.២. រយៈពេលឥណទាន

- រយៈពេលអប្បបរមានៃឥណទានគេហដ្ឋានគឺ ៣៦ខែ សមមូលនឹង ៣ឆ្នាំ។
- រយៈពេលអតិបរមានៃឥណទានគេហដ្ឋានគឺ៖
  - o ២៤០ខែ សម្រាប់ឥណទានប្លង់រឹង។
  - o ១៨០ខែ សម្រាប់ឥណទានប្លង់ទន់។

៣.១.៦.៣. អត្រាការប្រាក់

ផ្អែកលើការសម្រេចផ្អែកអាជីវកម្មទៅតាមស្ថានភាពទីផ្សារ អត្រាការប្រាក់អប្បបរមានាពេលបច្ចុប្បន្នត្រូវបានកំណត់សម្រាប់ឥណទានគេហដ្ឋាន គឺអត្រា១០%ក្នុងមួយឆ្នាំសម្រាប់ទ្រព្យធានាជាប្លង់រឹង និង១២%ក្នុងមួយឆ្នាំសម្រាប់ប្លង់ទន់។ អត្រាការប្រាក់មានការប្រែប្រួល។

៣.១.៦.៤. សោហ៊ុយចំណាយ

ដើម្បីទទួលបានឥណទាន អតិថិជនត្រូវចំណាយសោហ៊ុយចំពោះឥណទានគេហដ្ឋាន ចំនួន ១%នៃកម្ចីអនុម័ត ឬទំហំឥណទាន នៅពេលចុះកិច្ចសន្យាខ្ចីប្រាក់។

- ការសងប្រាក់មុនពេលកំណត់/បង់មុនផ្តាច់ ត្រូវមានការបង់ប្រាក់ពិន័យចំនួន ៣% នៃចំនួនដែលសងមុន តាមរយៈការគណនាលើចំនួនសរុបសមតុល្យឥណទាន។
- ការបង់ប្រាក់មួយចំនួនមុនកាលកំណត់ត្រូវគិតថ្លៃសេវា ២% លើទំហំប្រាក់ដែលបង់លើស/សងលើសចំនួននោះ។
- ចំពោះការសងយឺតយ៉ាវក៏ត្រូវមានបង់កម្រៃផងដែរ ដែលត្រូវបានគិតក្នុងអត្រា ២% ក្នុងមួយខែ និងត្រូវបានគិតលើចំនួនទឹកប្រាក់ដែលអតិថិជនសងយឺតចាប់ពីថ្ងៃទី៣ នៃការខកខាន (អតិប្បរមា ៥ដុល្លារអាមេរិក)។

៣.១.៦.៥. វិធីសាស្ត្រនៃការសងត្រឡប់ និងការកត់ត្រា

វិធីសាស្ត្រនៃការសងត្រឡប់នៅក្នុងធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មាន ២ប្រភេទគឺ៖

- ការសងប្រាក់ដើម និងការប្រាក់ថេររាល់ខែ (EMI)
- ការសងប្រាក់ដើមថេរ និងការប្រាក់រាល់ខែ (EMP)

ការប្រាក់នឹងត្រូវបានគណនាលើប្រាក់ដើមប្រចាំខែដែលនៅសល់។

ការកត់ត្រាឥណទានក៏មិនខុសពីការកត់ត្រាប្រតិបត្តិការផ្សេងៗនោះទេ។ សម្រាប់ឥណទានត្រូវបានកត់ត្រាតាមមូលដ្ឋានគណនេយ្យបង្គរទុក (Accrual Basis)។ ចំណែកឯការសងយឺតយ៉ាវរហូតដល់ ៩០ថ្ងៃ ការប្រាក់ត្រូវបានទទួលស្គាល់ និងកត់ត្រាតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់ (Cash Basis)។

៣.២. លក្ខខណ្ឌតម្រូវសម្រាប់ឥណទានគេហដ្ឋាន

៣.២.១. លក្ខខណ្ឌសម្រាប់អ្នកខ្ចី

ដើម្បីទទួលបានឥណទានគេហដ្ឋាន អ្នកខ្ចីត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ជាប្រជាជនកម្ពុជា និងមានលំនៅដ្ឋាននៅប្រទេសកម្ពុជា។
- អាយុ (បុគ្គល)៖
  - o អប្បរមា៖ ២៥ឆ្នាំ នៅពេលសុំឥណទាន។
  - o អតិបរមា៖ ៦០ឆ្នាំ អ្នកដែលមានចំណូលពីប្រាក់បៀវត្ស៍ និង៧០ឆ្នាំ អ្នកមានអាជីវកម្មផ្ទាល់ខ្លួន (អាយុគិតត្រឹមពេលបញ្ចប់នៃឥណទាន)។

- អប្បបរមាបម្រើការងារបៀវត្ស៖/ឆ្នាំអាជីវកម្ម៖
    - ការងារបៀវត្ស៖ អប្បបរមា ៦ខែក្នុងការងារបច្ចុប្បន្ន សរុបបទពិសោធន៍ការងារ ៤ឆ្នាំ។
    - អាជីវកម្មខ្លួនឯង៖ មានរយៈពេល៤ឆ្នាំ ក្នុងសកម្មភាពនៃអាជីវកម្មដូចគ្នា យ៉ាងតិចទទួលបានប្រាក់ចំណេញ១ឆ្នាំ។
- ប្រាក់ចំណូលអប្បបរមាប្រចាំខែសម្រាប់៖
    - អ្នកដែលមានអាជីវកម្មផ្ទាល់ខ្លួន៖ ចំនួនប្រាក់អប្បបរមាចំណេញសុទ្ធ ៧០០ ដុល្លារអាមេរិក។
    - អ្នកដែលមានចំណូលពីប្រាក់បៀវត្ស៖ អប្បបរមាចំណូលសុទ្ធប្រចាំខែ ៧០០ ដុល្លារអាមេរិក។

បទដ្ឋានឯកសារប្រាក់ចំណេញ៖

- សម្រាប់ប្រាក់បៀវត្ស៖- របាយការណ៍ស្តីពីប្រាក់បៀវត្ស, កិច្ចសន្យាការងារ(បើមាន), និងរបាយការណ៍ធនាគារ។
- សម្រាប់អាជីវកម្មផ្ទាល់ខ្លួន- ការត្រួតពិនិត្យវិក័យបត្រទិញ-លក់ យ៉ាងហោចណាស់ រយៈពេលមួយខែ ឬរបាយការណ៍ក្រៅផ្លូវការ(បើមាន) ចំណូលផ្សេងៗទៀតក៏ពិចារ-ណាផងដែរ ផ្អែកលើការបញ្ជាក់របស់ប្រធានឥណទានសាខាចុះពិនិត្យ និងបញ្ជាក់។
- សម្រាប់ឥណទានធំជាង ៥០,០០០ដុល្លារ តម្រូវអោយមានបន្ថែមទៀត ដូចជា៖
    - របាយការណ៍ហិរញ្ញវត្ថុ (មិនទាមទារអោយធ្វើសវនកម្ម ប៉ុន្តែតាមការវិនិច្ឆ័យរបស់មន្ត្រីឥណទាន និងការចុះដល់ទីកន្លែង)
    - ការចុះបញ្ជីពាណិជ្ជកម្ម/លិខិតអនុញ្ញាតអាជីវកម្ម/ប័ណ្ណប៉ាតង់ (ប្រសិនបើមាន)
    - អនុស្សរណៈ និងលក្ខខន្ដិកៈ (បើការស្នើសុំជាក្រុមហ៊ុន)(ប្រសិនបើមាន)។

៣.២.២. ការលើកលែង/ព្រំដែនក្នុងការផ្តល់ឥណទាន

ទោះបីជាឥណទានត្រូវបានផ្តល់ឱ្យដល់អតិថិជនដែលមានន្ទរមុខរបរ និងប្រាក់ចំណូលផ្សេងៗ ប៉ុន្តែក៏មានមុខរបរមួយចំនួនដែលត្រូវជៀសវាងក្នុងការផ្តល់ឥណទានផងដែរ។ បញ្ជីនៃមុខរបរ និងតំបន់ដែលត្រូវជៀសវាងមានដូចជា៖

- សកម្មភាពខុសច្បាប់ និងមិនសមស្របទាំងឡាយណា ដែលស្ថិតនៅក្រោមការហាមឃាត់នៃច្បាប់ ព្រះរាជាណាចក្រកម្ពុជា មានដូចជា៖

- សំណាញ់រសាត់សម្រាប់ចាប់ត្រីក្នុងទឹក ដោយប្រើសំណាញ់មានប្រវែងលើសពី ២.៥គីឡូម៉ែត្រ។
- មុខរបរចិញ្ចឹមត្រីចាប និងប្រភេទត្រីដែលស៊ីសាច់ឆៅជាអាហារ។
- ការចិញ្ចឹមត្រីឆ្គោដែលត្រូចបានហាមឃាត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

- ជាបន្ថែម ចំណុចខាងក្រោមក៏ត្រូវជៀសវាងផ្តល់ឥណទានផងដែរ ដូចជា៖
  - ជនដែលមិនមានសិទ្ធិក្នុងការធ្វើការងារស្របតាមច្បាប់កំណត់។
  - ជនពិការសតិ។
  - ជនញៀនគ្រឿងស្រវឹង
  - ជនញៀនថ្នាំញៀន។
- តំបន់ដែលត្រូវជៀសវាង ជាតំបន់ដែលឥណទានមានការខកខានក្នុងកម្រិតខ្ពស់ បញ្ហាច្បាប់ និងសណ្តាប់ធ្នាប់ និងការលំបាកផ្សេងៗទៀតនៅក្នុងការប្រមូលត្រឡប់វិញនៃឥណទាន ត្រូវបានកំណត់ដោយនាយកគ្រប់គ្រងហានិភ័យនៃការិយាល័យកណ្តាល។ តំបន់អាចត្រូវផ្តល់ឡើងវិញ បន្ទាប់ពីបានធ្វើការវាយតម្លៃឡើងវិញ ដោយការិយាល័យកណ្តាលតាមការស្នើសុំពីនាយក-នាយិកាសាខា។

៣.២.៣. ទ្រព្យធានា

ឥណទានគេហដ្ឋានបញ្ចេញដោយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ត្រូវមានទ្រព្យធានា៖

- ប្រភេទទ្រព្យសម្បត្តិដែលទទួលជាទ្រព្យបញ្ចាំ៖ ទ្រព្យសម្បត្តិលំនៅដ្ឋានដែលកំពុងខ្ចីប្រាក់សម្រាប់ទិញ។
- តម្លៃទ្រព្យសម្បត្តិធានាទាំងអស់ត្រូវចុះវាយតម្លៃដោយមន្ត្រីឥណទាន និងត្រូវចុះត្រួតពិនិត្យឡើងវិញដោយប្រធានឥណទាន។ សម្រាប់ឥណទានដែលធំជាង $៥០,០០០ ទ្រព្យសម្បត្តិនោះនឹងត្រូវវាយតម្លៃដោយភាគីទី៣ ដែលទទួលស្គាល់ដោយធនាគារ។
- ការផ្ទៀងផ្ទាត់ពីសាវតានៃម្ចាស់កម្មសិទ្ធិលើគ្រប់ទ្រព្យបញ្ចាំ គឺត្រូវមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន។
- ការផ្ទៀងផ្ទាត់អំពីសវតានៃម្ចាស់កម្មសិទ្ធិលើគ្រប់ទ្រព្យបញ្ចាំ គឺត្រូវតែមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន។

៣.២.៤. អ្នកធានា

ឥណទានទាំងអស់ត្រូវមានអ្នកខ្ចី និងអ្នករួមខ្ចីយ៉ាងតិចម្នាក់។ អ្នករួមខ្ចីគឺជាប្តីប្រពន្ធបានរៀបការ និងឪពុក ម្តាយ បងប្អូនបង្កើត កូនចៅមិនទាន់រៀបការ លែងលះ ពោះម៉ាយ មេម៉ាយ។ ក្នុងបរិបទដែលមិនមានសមាជិកគ្រួសារសម្រាប់ចូលរួមខ្ចី អាចបុគ្គលភាគីខាងក្រៅទី៣ឈរជាអ្នកធានាឥណទាន។

បើករណីមានអ្នកធានា តម្រូវតាមការណែនាំដូចជា៖

- អតិបរមាអ្នកធានា ៣កម្ចី ក្នុង១ឥណទាន។
- អ្នកធានានីមួយៗអាចធ្វើការធានាបានសរុប ពីរប្រាក់កម្ចីជាមួយ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។
- អ្នកធានាមួយអាចធានាបានតែ៣កម្ចី នៅស្ថាប័នហិរញ្ញវត្ថុទាំងអស់ (CBC)។

៣.២.៥. ការទិញធានារ៉ាប់រង

- ធានារ៉ាប់រងអគ្គីភ័យ៖ តម្រូវចាំបាច់អោយមានទៅលើអចលនទ្រព្យដែលជាទ្រព្យបញ្ចាំធានាឥណទាន។
- ធានារ៉ាប់រងអាយុជីវិត៖ មិនតម្រូវនោះទេ ប៉ុន្តែលើកទឹកចិត្តអោយអតិថិជនទិញ ដើម្បីធានាកម្ចី។
- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក៏មានដៃគូសហការជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងមួយចំនួនផងដែរដូចជា ក្រុមហ៊ុនសុវណ្ណភូមិឡាយហ្វ៍អឺសូរ៉ិនស៍ ភីអិលស៊ី និងក្រុមហ៊ុនធានារ៉ាប់រងកម្ពុជា រ៉ៃតណាម ភីអិលស៊ី។

៣.២.៦. ការរៀបចំឯកសារ

ការរៀបចំឯកសារមុនពេលអនុម័តឥណទាន

- ពាក្យស្នើសុំខ្ចីប្រាក់
- ឯកសារកំណត់អាសយដ្ឋាន
    1. សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ដែលគាត់កំពុងស្នាក់នៅតំបន់នោះ។
    2. ប្លង់ទីតាំងដែលបានគូសបង្ហាញដោយមន្ត្រីឥណទានបានចុះត្រួតពិនិត្យទាំងពីរនេះ ត្រូវទាមទារឱ្យមាន

- ឯកសារកំណត់អត្តសញ្ញាណកម្មមួយក្នុងចំណោមខាងក្រោម៖
    1. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
    2. សៀវភៅគ្រួសារ
    3. សៀវភៅស្នាក់នៅ
    4. លិខិតឆ្លងដែន
    5. សំបុត្រកំណើត
    6. ប័ណ្ណបើកបរ
    7. លិខិតបញ្ជាក់
        - ឯកសារភស្តុតាងប្រាក់ចំណេញ
        - គម្រោងជំនួញ/អាជីវកម្ម
        - ការឆែកអំណះអំណាងបានធ្វើរួចរាល់
        - ឯកសារទ្រព្យបញ្ចាំថតចម្លង
        - ពិនិត្យរិកៃយប័ត្រយ៉ាងហោចណាស់៣ខែ ឬរបាយការណ៍មិនផ្លូវការ (បើមានសម្រាប់អតិថិជនមានអាជីវកម្មផ្ទាល់ខ្លួន បើមិនដូច្នោះទេ ប្រាក់ចំណូលត្រូវបានពិចារណាដោយផ្អែកលើការចុះវាយតម្លៃ និងបញ្ជាក់ពីប្រធានឥណទាន។
        - ការពិនិត្យតាមរយៈអំណះអំណាង បន្ថែមពីលើនេះទៅទៀត ផ្នែកមួយនៃការការតម្រូវពិនិត្យ ការអំណះអំណាងវិជ្ជមានពីអ្នកជិតខាង។
        - ការត្រួតពិនិត្យឆែកអំណះអំណាងតាមរយៈទូរស័ព្ទ ឬទៅជួបជាមួយអាជ្ញាធរដែនដី ក៏តម្រូវផងដែរ។

ការបញ្ជាក់ និងការឆែក ផ្សេងទៀត៖

- ការជាន់គ្នា៖ វិជ្ជមាន អតិថិជនមិនអាចនៅក្រោមដំណើរការនៃការផ្តល់ឥណទានពីសាខាណាមួយផ្សេងទៀត របស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ឡើយ។
- ការពិនិត្យរបាយការណ៍ផ្តល់ឥណទាន CBC៖
    - ព័ត៌មានវិជ្ជមាន - គ្មានការយឺតយ៉ាវសងប្រាក់/ខកខានមិនសងឥណទាន
    - ចំនួនរបាយការណ៍ (Number of account enquiries) យកចេញពីប្រព័ន្ធការិយា-

លុយឥនទានក្នុងរយៈពេល១ខែចុងក្រោយតិចជាង ឬស្មើ

- o គ្មានការបាត់បង់ បើគ្មានអ្នកធានា
- o គ្មានការកំណត់សម្គាល់ជាអវិជ្ជមានជាសាធារណៈ
- o អាសយដ្ឋានឆ្លុះបញ្ចាំងពីអាសយដ្ឋានបច្ចុប្បន្ន
- o សេចក្ដីលម្អិតពីការងារត្រូវបានបើកចំហរអោយដឹងពេញលេញ
- o ចំនួនឥណទានកំពុងមាន តិចជាង ឬស្មើ២

ឯកសារក្រោយពេលអនុម័ត៖

- កិច្ចសន្យាដាក់បញ្ចាំ/ហ៊ីប៉ូតែក
- កិច្ចសន្យាខ្ចីប្រាក់
- បង្កាន់ដៃទទួលប្រាក់
- ទទួលតារាងកាលវិភាគសងប្រាក់

៣.២.៧. ការខកខានសង និងការផាកពិន័យ

អតិថិជននឹងត្រូវធ្វើការផាកពិន័យ នៅពេលដែលពួកគាត់ខកខានមិនបានសងបំណុល និងមិនបានគោរពទៅតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នាជាមួយនឹងធនាគារ។

ការខកខានសងបំណុលក៏ដូចជាការសងប្រាក់មុនកាលកំណត់ នឹងត្រូវមានការផាកពិន័យ នៅក្នុងអត្រាផ្សេងៗគ្នាដូចខាងក្រោម៖

- ការសងប្រាក់មុនពេលកំណត់/បង់មុនផ្តាច់ ត្រូវមានការបង់ប្រាក់ពិន័យចំនួន ៣% នៃចំនួនដែលសងមុន តាមរយៈការគណនាលើចំនួនសរុបសមតុល្យឥណទាន។
- ការបង់ប្រាក់មួយចំនួនមុនកាលកំណត់ (ស្នើសុំរំលស់ប្រាក់ដើម) ត្រូវគិតថ្លៃសេវា ២% លើទំហំប្រាក់ដែលបង់លើស។ ការស្នើសុំរំលស់ប្រាក់ដើមអាចធ្វើទៅបានរហូតដល់ ២៥% នៃសមតុល្យឥណទានក្នុងមួយឆ្នាំមិនមានការពិន័យ។ ចំពោះការបង់នេះ មិនត្រូវលើសពី ២ដងក្នុងមួយឆ្នាំឡើយ។
- ការសងយឺតយ៉ាវក៏ត្រូវមានការផាកពិន័យផងដែរ ដែលត្រូវបានគិតក្នុងអត្រា ២% ក្នុងមួយខែ និងត្រូវបានគិតលើចំនួនទឹកប្រាក់ដែលអតិថិជនសងយឺត។ ការគណនានេះ នឹងត្រូវបានគិតចាប់ពីថ្ងៃទី៣ នៃការខកខានសងប្រាក់ ហើយអប្បរមារនៃការពិន័យ គឺចាប់ពី ៥ដុល្លារអាមេរិក។

៣.៣. នីតិវិធីឥណទានគេហដ្ឋាន

- **<u>ដំណាក់កាលទី១៖</u> ការចុះឈ្មោះខ្ចីប្រាក់**
    - o អតិថិជនត្រូវដាក់ពាក្យស្នើសុំ ដែលភ្ជាប់មកជាមួយនឹងឯកសារកំណត់អត្ត-សញ្ញាណប័ណ្ណនានា ឯកសារបញ្ជាក់ចំណូល និងឯកសារដែលទាក់ទងនឹងទ្រព្យបញ្ចាំជាច្បាប់ចម្លង។
    - o អតិថិជនត្រូវតែយល់ព្រមផ្តល់រាល់ព័ត៌មានឥណទានទាំងអស់ ដែលភ្នាក់ងារត្រូវការតាមរយៈក្រឌីតប្យ៉ូរ។
    - o បន្ទាប់ពីចុះឈ្មោះខ្ចីប្រាក់រួចហើយ នឹងមានការត្រួតពិនិត្យការផ្តល់ឥណទានជាន់គ្នាក្នុងរង្វង់ធនាគារតែមួយ តាមរយៈប្រព័ន្ធការិយាល័យឥណទានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដើម្បីដឹងថាជាអតិថិជនចាស់របស់ធនាគារ ឬធ្លាប់បានដាក់ពាក្យស្នើសុំឥណទានពីមុនៗមកដែរឬទេ។
- **<u>ដំណាក់កាលទី២៖</u> ការចុះអង្កេត និងចុះដល់ទីកន្លែង**
    - o ការចុះដល់ទីកន្លែង ដោយចុះទៅមើលពីលំនៅដ្ឋាន ជីវភាព និងស្ថានភាពអាជីវកម្មរបស់អតិថិជន។
    - o ការសម្ភាសន៍ផ្ទាល់ជាមួយអតិថិជនក៏ត្រូវធ្វើឡើងផងដែរ ដើម្បីដឹងពីមូលហេតុនៃការស្នើសុំឥណទាន និងស្ថានភាពអាជីវកម្ម សម្រាប់ធ្វើការវាយតម្លៃចំណូលរបស់អតិថិជន។
    - o ព័ត៌មានដែលប្រមូលបានទាំងអស់ នឹងត្រូវបានយកមកធ្វើការត្រិះរិះពិចារណាសិក្សា វិភាគ និងវាយតម្លៃ សម្រាប់ធ្វើការវាយតម្លៃតម្រូវការឥណទាន។
- **<u>ដំណាក់កាលទី៣៖</u> ការវាយតម្លៃឥណទាន**

ឥណទានត្រូវបានគេគណនាដោយយោងទៅលើព័ត៌មានដែលទទួលបានពី៖

- o ពាក្យស្នើសុំឥណទាន ដែលបញ្ជាក់ពីគោលបំណងនៃការស្នើសុំឥណទាន និងចំនួនទឹកប្រាក់ដែលចង់ស្នើ។
- o ការិយាល័យឥណទាន ព័ត៌មានដែលទាក់ទងនឹងឥណទានរបស់អតិថិជនត្រូវយកទៅផ្ទៀងផ្ទាត់ជាមួយនឹងការិយាល័យឥណទានកម្ពុជា។
- o ការចុះដល់ទីកន្លែង អាចដឹងច្បាស់ពីស្ថានភាពជីវភាព និងទំហំអាជីវកម្មរបស់អតិថិជន និងដឹងច្បាស់ពីមូលហេតុនៃការស្នើសុំឥណទាន។

- o ការវាយតម្លៃប្រាក់ចំណេញ
  - សម្រាប់អតិថិជនដែលប្រកបអាជីវកម្មផ្ទាល់ខ្លួន
    - ➢ បើមានផ្តល់របាយការណ៍ហិរញ្ញវត្ថុ ត្រូវយល់ដឹងអោយច្បាស់ពីប្រាក់ចំណេញសុទ្ធ។
    - ➢ បើពុំមានផ្តល់នូវរបាយការណ៍ហិរញ្ញវត្ថុទេ ត្រូវប៉ាន់ស្មានពីការលក់ប្រចាំឆ្នាំ និងប្រាក់ចំណេញជាក់ស្តែងរបស់អតិថិជនដែលអាស្រ័យលើការពិភាក្សាជាមួយអតិថិជន។
  - សម្រាប់អតិថិជនដែលមានប្រាក់បៀវត្ស
    - ➢ តួលេខមធ្យមនៃប្រាក់បៀវត្ស ដែលបានមកពីកិច្ចសន្យាការ-ងារ ឬសក្ខីបត្រប្រាក់បៀវត្ស/ប្រកាសគណនីពីធនាគារ។
    - ➢ ចំពោះភាគលាភ ប្រាក់លើសម៉ោង ជាមធ្យម៦ខែ ត្រូវបានយកមកគិត អតិបរមា ៣០%នៃប្រាក់បៀវត្សធម្មតា។
- o ការវាយតម្លៃប្រាក់ចំណាយ ព័ត៌មានដែលទទួលបានពីការិយាល័យឥណទាន និងបានពីការប្រមូលក្នុងពេលចុះដល់ទីកន្លែងត្រូវបានប្រើប្រាស់ ដើម្បីស្វែងរកកាតព្វកិច្ចចំណាយផ្សេងៗរបស់អតិថិជន សម្រាប់ធ្វើការគណនាសមត្ថភាពអតិបរមារបស់អតិថិជន ក្នុងការទូទាត់ឥណទានប្រចាំខែជាមួយនឹងធនាគារប្រៃសណីយ៍កម្ពុជា ក.អ។
- o ឯកសារទ្រព្យបញ្ចាំ៖ ទ្រព្យបញ្ចាំរបស់អតិថិជនត្រូវបានវាយតម្លៃដោយអ្នកជំនាញ សម្រាប់ឥណទានទាំងឡាយណាដែលមានទំហំលើសពី $៥០,០០០។

- **<u>ដំណាក់កាលទី៤៖</u> ការអនុម័តឥណទាន**
  - o ក្រោយពីធ្វើការវាយតម្លៃឥណទានរួចរាល់មក ព័ត៌មានសង្ខេបរបស់អតិថិជននឹងត្រូវបានបញ្ជូនទៅប្រធានផ្នែកសាខាដើម្បីធ្វើការសម្រេចចិត្តអនុម័ត។
- **<u>ដំណាក់កាលទី៥៖</u> ការរៀបចំឯកសារកិច្ចសន្យា**
  - o ឯកសារពាក់ព័ន្ធដែលត្រូវរៀបចំមានដូចជា កិច្ចសន្យាដាក់បញ្ចាំទ្រព្យធានា ឬកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត រួមទាំងកិច្ចសន្យាខ្ចីប្រាក់ផងដែរ។

- **<u>ដំណាក់កាលទី៦</u>៖ ការបញ្ចេញឥណទាន**
  - o មុនពេលបញ្ចេញឥណទាន មន្ត្រីប្រតិបត្តិការ ឬមន្ត្រីប្រតិបត្តិការជាន់ខ្ពស់ ឬប្រធានផ្នែកប្រតិបត្តិការ ធ្វើការពន្យល់ណែនាំអតិថិជនអំពី របៀបសងប្រាក់ កាលបរិច្ឆេទសងប្រាក់ ចំនួនទឹកប្រាក់ត្រូវសង ការពិន័យ លក្ខខណ្ឌនៃការទទួលឥណទាន (អត្រាការប្រាក់ និងរយៈពេលឥណទាន) និងជម្រាបជូនអំពីហេតុការណ៍ដែលអាចកើតមានឡើងនាពេលអនាគត ដូចជាការចុះអង្កេតដល់ទីកន្លែងដោយសវនករជាដើម។
  - o មុនពេលបើកប្រាក់ បេឡាធិការតម្រូវឱ្យអតិថិជនផ្ទិតមេដៃស្តាំលើប័ណ្ណដកប្រាក់ និងជម្រាបពួកគាត់ពីលក្ខខណ្ឌនៃការប្រគល់ ទទួលប្រាក់ ដូចជាពិនិត្យ និងរាប់ប្រាក់ មុចពេលចាកចេញពីបញ្ជរ។
- **<u>ដំណាក់កាលទី៧</u>៖ ការតាមដានអតិថិជន**
  - o ក្នុងកំឡុងពេលមួយខែចាប់ពីការបញ្ចេញឥណទាន មន្ត្រីប្រតិបត្តិការនឹងរៀបចំរបាយការណ៍ត្រួតពិនិត្យឥណទាន ដែលរបាយការណ៍នេះស្តីពីការប្រើប្រាស់ចុងក្រោយរបស់អតិថិជនជាសង្ខេបជូនទៅប្រធានផ្នែកប្រតិបត្តិ ដើម្បីធ្វើការតាមដាននូវការប្រើប្រាស់ប្រាក់របស់អតិថិជន។
- **<u>ដំណាក់កាលទី៨</u>៖ ការសងត្រឡប់មកវិញ**
  - o អតិថិជនត្រូវធ្វើការទូទាត់ប្រាក់តាមរយៈបេឡាករនៅតាមសាខានីមួយៗ។
  - o បើមានបញ្ហាយឺតយ៉ាវផ្សេងៗកើតមានឡើង នោះបេឡាករសាខានឹងរៀបចំរបាយការណ៍មិនសងប្រាក់ជូនទៅមន្ត្រីឥណទានដែលទទួលខុសត្រូវ ដើម្បីឱ្យមន្ត្រីឥណទានធ្វើការដោះស្រាយតាមវិធានការ។

៣.៤. ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន

ដើម្បីបង្ហាញពីគុណភាពទ្រព្យសកម្មរបស់ធនាគារ និងការពារឥណទានបាត់បង់នាពេលអនាគត គ្រប់ធនាគារត្រូវតែធ្វើចំណាត់ថ្នាក់ឥណទាន និងរក្សានូវសំវិធានធនឥណទានបាត់បង់ឱ្យស្របទៅនឹងតម្រូវការបទបញ្ញត្តិ។ ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ត្រូវបានអនុវត្តតាមគោលការណ៍គ្រប់គ្រងហានិភ័យឥណទាន។

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក៏មានការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធនផងដែរគឺក្នុងគោលបំណងដើម្បីពង្រឹងវិន័យឥណទាន និងរចនាសម្ព័ន្ធដើមទុនរបស់ធនាគារ។

៣.៤.១. ការធ្វើចំណាត់ថ្នាក់ឥណទាន

៣.៤.១.១. និយមន័យ

ការធ្វើចំណាត់ថ្នាក់ឥណទាន គឺជាការចាត់ថ្នាក់គ្រប់ឥណទានទាំងអស់របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដោយផ្អែកលើសមត្ថភាពសងរបស់អ្នកខ្ចី។ សមត្ថភាពសងនេះត្រូវបានវាយតម្លៃតាមរយៈលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ប្រវត្តិនៃការទូទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងនៅពេលអនាគត
- គម្រោងលំហូរសាច់ប្រាក់ និងអាជីវកម្មសម្រាប់អនាគតដែលផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន
- លទ្ធភាព និងឆន្ទៈក្នុងការសងត្រឡប់មកវិញរបស់អ្នកខ្ចី
- បរិស្ថានហិរញ្ញវត្ថុ
- គុណភាពនៃការរៀបចំឯកសារ

៣.៤.១.២. ប្រភេទនៃចំណាត់ថ្នាក់ឥណទាន

ចំណាត់ថ្នាក់ឥណទានត្រូវបានចែកជា ៥ប្រភេទដូចខាងក្រោម៖

i. **<u>ធម្មតា</u>** **<u>(Normal)</u>**៖ ឥណទានដែលការសងប្រាក់ទៀងទាត់ និងហួសកាលកំណត់សងតិចជាង ៣០ថ្ងៃ (ពី០ថ្ងៃ ទៅ ២៩ថ្ងៃ)។

ii. **<u>ឃ្លាំមើល</u>** **<u>(Special mention)</u>**៖ ឥណទានដែលការសងត្រឡប់ហួសកាលកំណត់សងចំនួន ៣០ ថ្ងៃ ឬលើសពីនេះ ប៉ុន្តែតិចជាង ៩០ថ្ងៃ ត្រូវបានចាត់ជាឥណទានឃ្លាំមើល ឬអន់ជាងនេះ (ពី ៣០ថ្ងៃ ទៅ ៨៩ថ្ងៃ)។

iii. **<u>ក្រោមស្តង់ដារ</u>** **<u>(Sub-standard)</u>**៖ ឥណទានដែលការសងត្រឡប់ហួសកាលកំណត់សងមានចំនួន ៩០ថ្ងៃ ឬលើសពីនេះ ប៉ុន្តែតិចជាង ១៨០ថ្ងៃ ត្រូវបានចាត់ថ្នាក់យ៉ាងទាបបំផុតគឺក្រោមស្តង់ដារ (ពី ៩០ថ្ងៃ ទៅ ១៧៩ថ្ងៃ)។

iv. **<u>សង្ស័យ</u>** **<u>(Doubtful)</u>**៖ ឥណទានដែលការសងប្រាក់ហួសកាលកំណត់សងចំនួន ១៨០ថ្ងៃ ឬលើសពីនេះ ប៉ុន្តែតិចជាង ៣៦០ថ្ងៃ ត្រូវចាត់ថ្នាក់យ៉ាងទាបបំផុតជាបំណុលសង្ស័យ ឬអន់ជាងនេះ (ពី ១៨០ថ្ងៃ ទៅ ៣៥៩ថ្ងៃ)។

v. **<u>បាត់បង់</u>** **<u>(Loss)</u>**៖ ឥណទានដែលការសងត្រឡប់ហួសកាលកំណត់សងចំនួន ៣៦០ថ្ងៃ ឬលើសពីនេះ ត្រូវចាត់ថ្នាក់ជាឥណទានបាត់បង់ (ពី ៣៦០ថ្ងៃ ឬ ១ឆ្នាំឡើងទៅ)។

៣.៤.២. ការធ្វើសំវិធានធន

ធនាគារត្រូវរក្សាសំវិធានធនសម្រាប់ឥណទានបាត់បង់ឱ្យបានគ្រប់គ្រាន់ ដើម្បីទូទាត់ការខាតបង់ក្នុងសម្គាតឥណទាន ដែលអាចកើតមានឡើង។ សំវិធានធនមាន២ប្រភេទគឺ សំវិធានធនទូទៅ និងសំវិធានធនជាក់លាក់។

សំវិធានធនសរុប = សំវិធានធនទូទៅ + សំវិធានធនជាក់លាក់

៣.៤.២.១. សំវិធានធនទូទៅ

សំវិធានធនទូទៅ ជាសំវិធានធនដែលធនាគាររក្សាទុក ១% នៃប្រាក់ដើម សម្រាប់ឥណ-ទានទាំងឡាយណាដែលខកខានសងពី សូន្យថ្ងៃដល់២៩ថ្ងៃ (ឥណទានថ្នាក់ធម្មតា)។

៣.៤.២.២. សំវិធានធនជាក់លាក់

សំវិធានធនជាក់លាក់ ជាសំវិធានធនដែលធនាគាររក្សាទុក៖

- ៣% នៃប្រាក់ដើម សម្រាប់ឥណទានថ្នាក់ឃ្លាំមើល
- ២០% នៃប្រាក់ដើម សម្រាប់ឥណទានថ្នាក់ក្រោមស្តង់ដារ
- ៥០% នៃប្រាក់ដើម សម្រាប់ឥណទានថ្នាក់សង្ស័យ
- ១០០% នៃប្រាក់ដើម សម្រាប់ឥណទានថ្នាក់បាត់បង់

៣.៤.៣. ការលុបបំណុលចេញពីបញ្ជី

ឥណទានថ្នាក់បាត់បង់ ដែលត្រូវបានធ្វើសំវិធានធនជាក់លាក់១០០% នឹងត្រូវបានលុបចេញពីបញ្ជី (Write-off) ដោយស្វ័យប្រវត្តិ បន្ទាប់ពីហួសរយៈពេល ៣៦០ថ្ងៃនៃកាលបរិច្ឆេទសងប្រាក់ចុងបញ្ចប់។ បំណុលទាំងអស់អាចលុបចេញពីបញ្ជីក្រោមការវិនិច្ឆ័យរបស់នាយកប្រតិបត្តិឥណទាន ក្នុងករណីដែលធនាគារបាត់សិទ្ធិតាមកិច្ចសន្យាលើការគ្រប់គ្រងឥណទាន ឬពេលដែលរកឃើញថា ឥណទានមួយផ្នែក ឬទាំងមូលមិនអាចប្រមូលមកវិញបាន ឬគ្មានសង្ឃឹមថាឥណទាននេះអាចប្រមូលមកវិញបាន។

ជាទូទៅ ករណីខាងក្រោមនេះជាសញ្ញាណដែលអាចឈានទៅដល់ការលុបចោលនូវឥណទាន ឬមួយផ្នែកនៃឥណទាន៖

i. ធនាគារបាត់បង់សិទ្ធិតាមកិច្ចសន្យាក្នុងការគ្រប់គ្រងឥណទានទាំងស្រុង ឬមួយផ្នែកដូចដែលបានសម្រេចដោយតុលាការ

ii. គ្រប់ប្រភេទនៃទ្រព្យធានាដែលត្រូវបានរឹបអូស និងលក់បញ្ចេញ ប៉ុន្តែនៅតែមិនគ្រប់គ្រាន់សម្រាប់ទូទាត់សងឥណទានទាំងមូល

iii. ធនាគារមិនអាចប្រមូល ឬលែងមានមូលហេតុសមស្របក្នុងការធានាថាអាចនឹងប្រមូលបានឥណទានគ្រប់ចំនួនវិញ ដែលត្រូវទារស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាឥណទាន និងបុរេប្រទាន។

iv. អ្នកខ្ចីប្រាក់បានក្ស័យធន ឬកំពុងតែស្ថិតក្នុងដំណាក់កាលស្តារនីតិសម្បទាផ្នែកហិរញ្ញវត្ថុ និងកំពុងតែជួបការលំបាកក្នុងការសងបំណុល។

v. ឥណទានត្រូវបានធ្វើចំណាត់ថ្នាក់ ជាប្រភេទឥណទានបាត់បង់។

៣.៤.៤. ឥណទានរៀបចំឡើងវិញ

ការរៀបចំឥណទានឡើងវិញ ឬការរៀបចំតារាងកាលវិភាគឥណទានឡើងវិញ ត្រូវបានធ្វើឡើងក្នុងគោលបំណងជួយដល់អតិថិជនក្នុងការកាត់បន្ថយបន្ទុកក្នុងការសងបំណុល ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុ។ ការរៀបចំឥណទានឡើងវិញ អាចធ្វើបានចំពោះតែអតិថិជនណាដែលមានដំណើរការអាជីវកម្មល្អនាពេលអនាគត ហើយដែលកំពុងជួប ឬរំពឹងថានឹងជួបការលំបាកជាបណ្តោះអាសន្នក្នុងការសងត្រឡប់វិញនូវប្រាក់ដើម និង/ឬ ការប្រាក់។

ឥណទានដែលនឹងត្រូវរៀបចំឡើងវិញ ត្រូវវិភាគលើមូលដ្ឋានទិសដៅអាជីវកម្ម និងសមត្ថភាពសងប្រាក់ត្រឡប់វិញរបស់អតិថិជន តាមការព្យាករណ៍នូវលំហូរសាច់ប្រាក់ថ្មី ដែលស្របតាមស្ថានភាពទីផ្សារ និងបច្ចុប្បន្នកម្មនៃទស្សនៈវិស័យអាជីវកម្ម ដោយផ្អែកលើសម្មតិកម្មជាក់ស្តែង និងការប្រុងប្រយ័ត្ន។

ការរៀបចំឥណទានឡើងវិញមិនត្រូវបានអនុវត្តសម្រាប់អតិថិជនណា ដែលគ្រាន់តែមានគោលបំណងក្នុងការជៀសវាង៖

- ការធ្លាក់ចំណាត់ថ្នាក់របស់ខ្លួន ព្រោះតែចំណាត់ថ្នាក់ឥណទាន
- ការកើនឡើងនូវសំវិធានធនលើឥណទានបាត់បង់

បន្ទាប់ពីឥណទានត្រូវបានរៀបចំឡើងវិញ ធនាគារត្រូវធ្វើចំណាត់ថ្នាក់ឥណទានដូចខាងក្រោមនេះ៖

- មិនធ្វើការផ្លាស់ប្តូរ សម្រាប់ឥណទានណាដែលពីមុនមកត្រូវបានចាត់ថ្នាក់ជាថ្នាក់ធម្មតា ឃ្លាំមើល ឬក្រោមស្តង់ដារ
- មិនត្រូវចាត់ថ្នាក់ឱ្យល្អជាងថ្នាក់ក្រោមស្តង់ដារឡើយសម្រាប់ឥណទាន ដែលពីមុនមកត្រូវបានចាត់ថ្នាក់ជាថ្នាក់សង្ស័យ ឬបាត់បង់

ការធ្វើចំណាត់ថ្នាក់នេះ នឹងត្រូវកែសម្រួលវិញ នៅពេលដែលការប្រាក់ និងប្រាក់ដើមត្រូវបានសងមកវិញក្នុងអំឡុងពេលបីគ្រានៃការសងរំលស់។

៣.៥. ការគ្រប់គ្រងហានិភ័យឥណទាន

៣.៥.១. កត្តាដែលបណ្តាលឱ្យមានហានិភ័យឥណទាន

- អតិថិជនគោលដៅ ជាពិសេសបុគ្គលដែលមានចំណូលពីអាជីវកម្មផ្ទាល់ខ្លួន គឺពួកគាត់មិនមានសៀវភៅកំណត់ត្រាលំហូរសាច់ប្រាក់ ឬគណនីឱ្យបានត្រឹមត្រូវនោះទេ លើសពីនេះទៅទៀតមិនមានរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ ហើយការវិភាគលើចំណូលរបស់អតិថិជនគឺផ្អែកលើការវាយតម្លៃជាក់ស្តែង ឬឯកសារយោងផ្សេងៗ ដូច្នោះហានិភ័យនៃការប៉ាន់ស្មានលើសនៃចំណូលនឹងនៅតែជាហានិភ័យបន្តទៀត។
- ការវាយតម្លៃនៃវត្ថុបញ្ចាំសម្រាប់កម្ចីដែលមានតម្លៃតូចជាង ៥០.០០០ដុល្លារអាមេរិក ត្រូវបានធ្វើឡើងដោយបុគ្គលិកផ្ទៃក្នុងដែលមានចំណេះដឹង និងជំនាញក្នុងការវាយតម្លៃទ្រព្យធានា ប៉ុន្តែវាអាចនាំឱ្យមានកំហុសខុសឆ្គងជាយថាហេតុណាមួយក្នុងការគណនា។
- ភាគច្រើននៃទ្រព្យបញ្ចាំគឺជាប្លង់ទន់ ដែលត្រូវបានចេញដោយអាជ្ញាធរមូលដ្ឋាន ដែលអាចនាំឱ្យមានការកើនឡើងនៃការក្លែងបន្លំប្លង់ និងអាចមានការផ្តល់ឥណទានជាន់គ្នាជាមួយនឹងស្ថាប័នផ្សេង ឬការផ្ទេរកម្មសិទ្ធិទ្រព្យដោយទ្រព្យទាំងនោះកំពុងជាប់ជាមួយស្ថាប័នហិរញ្ញវត្ថុ។
- ការប្រែប្រួលតម្លៃអចលនទ្រព្យ អាចនាំឱ្យមានករណីកាត់បន្ថយនូវដើមទុនរបស់អតិថិជននៅក្នុងអចលនទ្រព្យ។ វាអាចជាហេតុនាំឱ្យមានឥណទានយឺតយ៉ាវ។
- មិនមានមូលនិធិ ដោយសារតែ CASA មានកម្រិតទាប។

៣.៥.២. យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ

- ចំនួនប្រាក់ខែអប្បបរមា និងការចំណាយជាមធ្យមក្នុងមនុស្សម្នាក់ក្នុងមួយខែ សម្រាប់គ្រប់តំបន់រួមទាំងទីក្រុង និងតំបន់ជនបទត្រូវបានកំណត់។ ប្រាក់ចំណេញតាមវិស័យ តាមតំបន់ ក៏ត្រូវបានកំណត់ផងដែរ។ សកម្មភាពទាំងនេះជាកត្តាគ្រប់គ្រងនូវការគណនាលទ្ធភាពសងរបស់អតិថិជន។
- ធនាគារនឹងធ្វើការវិនិយោគលើបច្ចេកវិជ្ជាដែលមានឈ្មោះថា «ប្រព័ន្ធគ្រប់គ្រងការចុះ

ឈ្មោះខ្ចីឥណទាន» (Loan Origination System) ដើម្បីកាត់បន្ថយកំហុសលើការគណនា និងចំណុចសំខាន់ៗក្នុងការវាយតម្លៃប្រាក់កម្ចី។

- គ្រប់ទ្រព្យធានាជាប្លង់ទន់ទាំងអស់ ធនាគារនឹងសរសេរជាលិខិតរដ្ឋបាលជាផ្លូវការជូនដល់អាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យជ្រាបជាព័ត៌មានអំពីការទទួលយកទ្រព្យរបស់អតិថិជនក្នុងការដាក់ធានាបំណុលជាមួយធនាគារ ជៀសវាងការអនុញ្ញាតឱ្យទ្រព្យធានាដដែលនេះធ្វើការជំពាក់បំណុលស្ថាប័នផ្សេងទៀត។
- សម្រាប់ទីក្រុង អត្រាតម្លៃអចលទ្រព្យក្នុងមួយម៉ែត្រការេតាមតំបន់ ត្រូវបានរក្សាទុកជាខ្នាតគំរូក្នុងការវាយតម្លៃទ្រព្យធានាដែលមានលក្ខណៈស្រដៀងនៅតំបន់ដូចគ្នានេះ។
- យើងមានក្រុមការងារជាច្រើនធ្វើការពិនិត្យមើលការអនុវត្តរបស់សាខា និងក្រុមសវនកម្មផ្ទៃក្នុង។ វិធានការកែលម្អចាំបាច់ត្រូវបានដាក់ចេញនៅពេលកំហុសនានាត្រូវបានរកឃើញដោយក្រុមទាំងនេះ។ ធនាគារធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈតាមមុខងារ និងតួនាទីដើម្បីបញ្ចៀសនូវការអនុវត្តខុសរបស់បុគ្គលិកដែលបង្កជាហានិភ័យដល់ធនាគារទាំងមូល។
- ហានិភ័យនៃការខកខានឥណទានត្រូវបានកាត់បន្ថយ ដោយសារកំណត់ទំហំកម្ចីតាមតម្លៃនៃទ្រព្យធានា LTV ៧៥% ហើយទំហំឥណទាននោះក៏ផ្អែកលើចំណូលរបស់អតិថិជន និងលទ្ធភាពសង មិនមែនផ្អែកតែលើតម្លៃទ្រព្យសម្បត្តិបញ្ចាំមួយមុខនោះទេ។
- ហានិភ័យនៃការមិនបញ្ចប់គម្រោងអចលនទ្រព្យត្រូវបានកាត់បន្ថយ ពីព្រោះយើងនឹងទទួលបានទ្រព្យសម្បត្តិបន្ថែមទៀតជាទ្រព្យធានា ដើម្បីធានាគ្រប់ដណ្តប់ទៅលើឥណទានសម្រាប់រយៈពេលបណ្តោះអាសន្ននៅពេលដែលទ្រព្យសម្បត្តិចម្បងកំពុងត្រូវបានសាងសង់ ទោះបីទ្រព្យជាអចលទ្រព្យមិនត្រូវបានបញ្ចប់ក្នុងរយៈពេលកំណត់តាមការព្រមព្រៀងក៏ដោយ។
- មិនមានការផ្តល់ឥណទានបន្ថែមទៀត ដែលត្រូវបានអនុញ្ញាតលើអចលនទ្រព្យដែលដាក់បញ្ចាំលើផលិតផលគេហដ្ឋានសម្រាប់រយៈពេល ១២ខែ បន្ទាប់ពីទទួលបានឥណទានគេហដ្ឋានទិញផ្ទះ។
- ខណៈពេលដែល CASA មានកម្រិតទាប វាគឺគ្រប់គ្រាន់ដើម្បីបំពេញតាមទំហំឥណទានតិចតួចដែលកំពុងត្រូវបានស្នើសុំ។ គិតត្រឹមថ្ងៃ ១៧ ខែតុលា គុណ្យភាព CASA មានចំនួន ៥៦ លានដុល្លារ ហើយរំពឹងថានឹងបន្តកើនឡើងបន្ថែមទៀត។ ម្យ៉ាងវិញ

ទៀត សមតុល្យឥណទានខ្ពស់បំផុតសម្រាប់ផលិតផលឥណទានគេហដ្ឋាន រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០១៨ ត្រូវបានកំណត់ត្រឹមតែ ២០លានដុល្លារតែប៉ុណ្ណោះ។

៣.៥.៣. ដំណោះស្រាយបញ្ហាបំណុលឥណទាន

ការដោះស្រាយបំណុល គឺជាការចូលរួមការពារនូវទ្រព្យសកម្មរបស់ធនាគារ។ គោលដៅក្នុងការដោះស្រាយបំណុល គឺដើម្បីចូលរួមបង្កើនប្រាក់ចំណេញតាមរយៈ៖

- ការកាត់បន្ថយបំណុលបាត់បង់ឱ្យមកនៅត្រឹមកម្រិតអប្បបរមា
- ការត្រួតពិនិត្យការខកខានសង (និងសំវិធានធន) ស្របតាមគោលដៅប្រាក់ចំណេញ
- ការរក្សាបាននូវអតិថិជនដែលផ្តល់ប្រាក់ចំណេញដល់ធនាគារ
- ការធ្វើប្រតិបត្តិការដោយចំណាយថ្លៃដើមប្រកបដោយប្រសិទ្ធភាព

នៅក្នុងការដោះស្រាយបំណុល ធនាគារនីមួយៗអាចប្រើប្រាស់នូវមធ្យោបាយផ្សេងៗគ្នាជាច្រើនអាស្រ័យទៅតាមកម្រិតនៃការខកខានសងប្រាក់ ឬអាកប្បកិរិយារបស់អតិថិជននីមួយៗ។ ជាទូទៅ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ប្រើប្រាស់នូវមធ្យោបាយក្នុងការដោះស្រាយបំណុលដូចខាងក្រោម៖

1. លិខិតក្រើនរំលឹកឱ្យសងប្រាក់
2. ការទាក់ទងអតិថិជនខកខានប្រាក់តាមរយៈការហៅទូរស័ព្ទ
3. ការផ្ញើសារតាមទូរស័ព្ទ
4. ជំនួយតាមរយៈអន្តរការី
5. ការចុះដល់ទីកន្លែងតែងង ឬជាក្រុម
6. ការជ្រើសតាំងមន្ត្រីប្រមូលឥណទានខាងក្រៅ
7. លិខិតជូនដំណឹងស្តីពីការបង់ផ្តាច់ឥណទាន
8. លិខិតជូនដំណឹងតាមផ្លូវច្បាប់ ចំពោះអ្នកខ្ចី និងអ្នកធានា
9. ការរាយការណ៍ទៅកាន់ការិយាល័យឥណទានកម្ពុជា
10. វិធានការផ្លូវច្បាប់ និងការគ្រប់គ្រងទ្រព្យដាក់បញ្ចាំ
11. ការលុបបំណុលចេញពីបញ្ជី និងការដោះស្រាយ

៣.៦. ការវិភាគទិន្នន័យ

ទិន្នន័យខាងក្រោម គឺជាទិន្នន័យមួយចំនួនដែលទាក់ទងទៅហ្នឹងឥណទានគេហដ្ឋានរបស់

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលរួមមានសមតុល្យឥណទានគេហដ្ឋានសរុប និងសមតុល្យឥណទានគេហដ្ឋានដែលសងយឺត ចាប់ពីឆ្នាំ ២០១៦ ដល់ ២០១៨៖

៣.៦.១. ការវិភាគលើសមតុល្យឥណទានគេហដ្ឋានសរុប

<u>តារាង ៣.១</u>៖ សមតុល្យឥណទានគេហដ្ឋានសរុប

	សមតុល្យឥណទានគេហដ្ឋាន	បម្រែបម្រួល គិតជាសាច់ប្រាក់	បម្រែបម្រួល គិតជា %
២០១៦	USD ៨.៣០០.០០០	–	–
២០១៧	USD ១០.៥០០.០០០	USD ២.២០០.០០០	០.២១%
២០១៨	USD ១៣.០០០.០០០	USD ២.៥០០.០០០	០.១៩%

(ប្រភព៖ ការជួបផ្ទាល់ជាមួយនឹងគណៈគ្រប់គ្រងធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា)

<u>ដ្យាក្រាម ៣.១</u>៖ សមតុល្យឥណទានគេហដ្ឋានសរុប



យោងតាមដ្យាក្រាម ៣.១ ដែលបង្ហាញអំពីការបញ្ចេញឥណទានគេហដ្ឋានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ២០១៨ បានបង្ហាញឱ្យឃើញថា ការបញ្ចេញឥណទានគេហដ្ឋានសរុបមានចំនួន ៨.៣០០.០០០ ដុល្លាអាមេរិក គិតក្នុងឆ្នាំ២០១៦។ ឈានមកដល់ឆ្នាំ២០១៧ អត្រានៃការកើនឡើងនៃសមតុល្យឥណទានមានចំនួន ០.២១% បើធៀបនឹងឆ្នាំ២០១៦ ដែលត្រូវនឹងទឹកប្រាក់ចំនួន ២.២០០.០០០ ដុល្លាអាមេរិក។ ជាក់ស្តែងចំនួននៃការបញ្ចេញឥណទានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា

មានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលគិតមកត្រឹមឆ្នាំ២០១៨ សមតុល្យឥណទានគេហដ្ឋានសរុបមានចំនួន ១៣.០០០.០០០ ដុល្លាអាមេរិក ដោយមានការកើនឡើងចំនួន ០.១៨% បើធៀបទៅនឹងឆ្នាំ២០១៧ ដែលត្រូវនឹងទឹកប្រាក់ចំនួន ២.៥០០.០០០ ដុល្លាអាមេរិក។

៣.៦.២. ការវិភាគលើសមតុល្យឥណទានគេហដ្ឋានដែលសងយឺត

<u>តារាង ៣.២៖</u> សមតុល្យឥណទានគេហដ្ឋានដែលសងយឺត

	សមតុល្យឥណទានគេហដ្ឋាន	សមតុល្យឥណទានគេហដ្ឋានដែលសងយឺត	PAR %
២០១៦	USD ៨.៣០០.០០០	USD ៥០.០០០	០.៥៨%
២០១៧	USD ១០.៥០០.០០០	USD ១៩.០០០	០.១៨%
២០១៨	USD ១៣.០០០.០០០	USD ៣២.០០០	០.២៤%

(ប្រភព៖ ការជួបផ្ទាល់ជាមួយនឹងគណៈគ្រប់គ្រងធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា)

<u>ដ្យាក្រាម ៣.២៖</u>

យោងតាមដ្យាក្រាម ៣.២ ដែលបង្ហាញពីសមតុល្យគេហដ្ឋានដែលសងយឺតរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ក្នុងរយៈពេល ៣ឆ្នាំចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ បានបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ២០១៦ សមតុល្យឥណទានគេហដ្ឋានដែលមានការសងយឺតមានចំនួន ៤០.០០០ ដុល្លាអាមេរិក ដែលស្មើនឹងអត្រា ០.៥៨% នៃសមតុល្យឥណទានគេហដ្ឋានសរុប

ក្នុងឆ្នាំដដែល។ ប៉ុន្តែមកទល់ឆ្នាំ២០១៧ អត្រានៃការសងយឺតមានការធ្លាក់ចុះជាខ្លាំងមកសល់ត្រឹម ០.១៨% នៃសមតុល្យសរុបក្នុងឆ្នាំ២០១៧។ ចំណែកឯក្នុងឆ្នាំ២០១៨ ក៏ទោះបីជាអត្រានៃការសងយឺតមានការកើនឡើងវិញដល់ ០.២៤% ក៏ពិតមែន ប៉ុន្តែធនាគារពុំមានការលុបឥណទានចេញពីបញ្ជីនោះទេ ដែលនេះជាហេតុធ្វើឱ្យធនាគារពុំបានទទួលរងនូវការខាតបង់។

៣.៧. ចំណុចខ្លាំង និងចំណុចខ្សោយ

បន្ទាប់ពីក្រុមយើងខ្ញុំបានធ្វើការចុះកម្មសិក្សាអស់រយៈពេល ៤សប្តាហ៍កន្លងមក នៅឯធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ក្រោមប្រធានបទ "ការគ្រប់គ្រងឥណទានគេហដ្ឋាន" រួចមក ក្រុមយើងខ្ញុំបានសង្កេតឃើញពីចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនរបស់ធនាគារ។

៣.៧.១. ចំណុចខ្លាំង

- មានរចនាសម្ព័ន្ធគ្រប់គ្រងយ៉ាងរឹងមាំ ដែលធ្វើឱ្យការប្រព័ន្ធនៃការបំពេញការងាររបស់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់មានប្រសិទ្ធិភាព។
- ទាំងគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់នៅក្នុងធនាគារ សុទ្ធសឹងតែជាអ្នកដែលមានសីលធម៌វិជ្ជាជីវៈខ្ពស់ ក្នុងការប្រកបការងារ និងការប្រាស្រ័យទាក់ទង។
- ធនាគារមានគោលការណ៍ និងនីតិវិធីច្បាស់លាស់ ដែលបង្ហាញពីភាពហ្មត់ចត់ក្នុងការផ្តល់ឥណទានទៅដល់អតិថិជន។
- អត្រាការប្រាក់នៃឥណទានគេហដ្ឋាន មានភាពសមរម្យ និងទទួលបានទំហំឥណទានច្រើនដល់ទៅ ៧៥% នៃតម្លៃព្រមព្រៀងគ្នានៃគេហដ្ឋានដែលត្រូវទិញ។
- ធនាគារទទួលបានការទុកចិត្ត និងគាំទ្រពីសំណាក់អតិថិជន ដែលធ្វើឱ្យសមតុល្យឥណទានគេហដ្ឋានមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។
- ការគ្រប់គ្រងឥណទានគេហដ្ឋានមានភាពច្បាស់លាស់ និងត្រឹមត្រូវ ដោយធ្វើឱ្យគ្មានសមតុល្យឥណទានដែលលុបចេញពីបញ្ជី។

៣.៧.២. ចំណុចខ្សោយ

ទន្ទឹមនឹងចំណុចខ្លាំងដែលបានរៀបរាប់ខាងលើ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក៏មាននូវចំណុចខ្សោយមួយចំនួនផងដែរ ដូចជា៖

- ទំហំនៃការផ្តល់ឥណទានគេហដ្ឋានជូនដល់អតិថិជន មានភាពខុសគ្នាទៅតាមតំបន់មួយចំនួន។

- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ពុំទាន់មានសាខាគ្រប់ ២៥ រាជធានី-ខេត្តនៅឡើយ។
- ចំពោះដៃគូសហការអាជីវកម្មរបស់ធនាគារវិញ ពុំទាន់មានភាពធំទូលាយ ដែលជះឥទ្ធិពលដល់ភាពងាយស្រួលក្នុងការស្វែងរកគេហដ្ឋានរបស់អតិថិជន។
- ការផ្សព្វផ្សាយអំពីផលិតផលឥណទានគេហដ្ឋានរបស់ធនាគារ នៅមានកម្រិតនៅឡើយ។

សេចក្តីសន្និដ្ឋាន
និងការផ្តល់អនុសាសន៍

សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន

ក្រោយពីក្រុមយើងខ្ញុំបានបញ្ចប់ការចុះកម្មសិក្សាស្រាវជ្រាវលើប្រធានបទ "ការគ្រប់គ្រងឥណទានគេហដ្ឋាន" របស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណារួចកន្លងមក រួមផ្សំជាមួយការសិក្សាស្រាវជ្រាវលើផ្នែកទ្រឹស្តី យើងខ្ញុំសង្កេតឃើញថា ឥណទានគេហដ្ឋាន គឺជាផ្នែកមួយនៃប្រាក់ចំណូលរបស់ធនាគារ ដែលបានរួមចំណែកដ៏សំខាន់នៅក្នុងប្រតិបត្តិការរបស់ធនាគារ ហើយក៏បានជួយសម្រេចនូវគោលបំណងជាម្ចាស់កម្មសិទ្ធិលើគេហដ្ឋានជូនអតិថិជន។ ហេតុដូចនេះហើយទើបការគ្រប់គ្រងទៅលើឥណទានគេហដ្ឋាន គឺជាកត្តាដែលចាំបាច់ដែលធនាគារតែងតែខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការអនុវត្តតាមគោលការណ៍ និងនីតិវិធីនៃការផ្តល់ឥណទានគេហដ្ឋានបានយ៉ាងខ្ជាប់ខ្ជួន និងច្បាស់លាស់។

តាមរយៈការចុះកម្មសិក្សាផ្ទាល់នៅធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា យើងខ្ញុំសង្កេតឃើញថា ដំណើរការនៃការផ្តល់ និងគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារនេះ គឺមានភាពច្បាស់លាស់ និងត្រឹមត្រូវ ទៅតាមគោលការណ៍ និងនីតិវិធីរបស់ធនាគារ ដែលជាហេតុធ្វើឱ្យអត្រានៃសមតុល្យឥណទានគេហដ្ឋានមានការកើតឡើងពីមួយឆ្នាំទៅមួយឆ្នាំ (គិតត្រឹមឆ្នាំ ២០១៦-២០១៨)។ បន្ថែមពីលើនេះទៅទៀត ធនាគារបានបើកឱកាសទូលាយដល់អតិថិជនក្នុងការទទួលបានឥណទានគេហដ្ឋាន ដែលប្រៀបដូចជាបានជួយជម្រុញនូវចរន្តសេដ្ឋកិច្ចនៅក្នុងប្រទេសឱ្យកាន់តែមានភាពរីកចម្រើន បង្កើតការងារជូនប្រជាជន និងធ្វើអោយអតិថិជនមានគេហដ្ឋានសមរម្យតាមគោលបំណង។ ពិសេសជាងនេះទៅទៀត ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានការទទួលខុសត្រូវខ្ពស់ទៅលើការគ្រប់គ្រងឥណទានគេហដ្ឋាន ដែលទាំងនេះបានបង្ហាញឱ្យឃើញអំពីគុណភាពនៃការប្រតិបត្តិនូវការងារ និងប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធានរបស់ខ្លួន ដែលក្រៅពីការទទួលបានប្រាក់ចំណេញ ប៉ុន្តែថែមទាំងមានមុខងារសំខាន់មួយទៀត គឺជួយអភិវឌ្ឍសង្គមជាតិផងដែរ។

សរុបសេចក្តីមក ការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ពិតជាបានប្រព្រឹត្តទៅយ៉ាងមានគុណភាព និងមានប្រសិទ្ធិភាព ដែលបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់អតិថិជន សង្គមជាតិ និងធនាគារផ្ទាល់។

២. ការផ្តល់អនុសាសន៍

ទន្ទឹមនឹងការរីកចម្រើនក្នុងការផ្តល់ឥណទានគេហដ្ឋានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ យើងក៏សង្កេតឃើញនូវចំណុចខ្វះខាតមួយចំនួនដែលកើតមានផងដែរ។ អាស្រ័យហេតុនេះ យើងខ្ញុំសូមផ្តល់ជាគំនិតយោបល់មួយចំនួនជូនចំពោះធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាសុវណ្ណា ក្នុងន័យរួមចំណែកក្នុងការកែលម្អនូវចំណុចខ្វះខាតទាំងនោះ ដើម្បីធ្វើឱ្យការប្រតិបត្តិក្នុងការគ្រប់គ្រងឥណទានគេហដ្ឋានកាន់តែមានប្រសិទ្ធិភាព។

- ធនាគារគួរតែផ្តល់នូវទំហំឥណទានឱ្យបានស្មើភាពគ្នា នៅគ្រប់តំបន់ទាំងអស់នៅក្នុងប្រទេស ដើម្បីទទួលបានទីផ្សារគោលដៅកាន់តែច្រើន។
- ធនាគារគួរតែពង្រីកបន្ថែមនូវសាខាតាមបណ្តាខេត្ត-ក្រុងនានា ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការស្វែងរកសេវារបស់ធនាគារ។
- ធនាគារគួរតែបន្ថយអត្រាការប្រាក់នៃកម្ចីឥណទានគេហដ្ឋាន ដើម្បីទាក់ទាញអតិថិជនដែលមានបំណងចង់បានគេហដ្ឋានផ្ទាល់ខ្លួន ឱ្យងាកមកប្រើប្រាស់នូវកម្ចីឥណទានគេហដ្ឋាននៅធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ កាន់តែច្រើនថែមទៀត។
- ធនាគារគួរតែស្វែងរកដៃគូសហការអាជីវកម្មឱ្យបានច្រើនបន្ថែមទៀត ដែលពាក់ព័ន្ធទៅនឹងវិស័យលំនៅដ្ឋាន សម្រាប់ជាជម្រើសដល់អតិថិជនដែលប្រើប្រាស់កម្ចីឥណទានគេហដ្ឋានរបស់ធនាគារ។
- ដោយហេតុថា ការផ្សព្វផ្សាយអំពីឥណទានគេហដ្ឋានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ នៅមានកម្រិតនៅឡើយ ដូចនេះធនាគារគួរតែធ្វើការផ្សព្វផ្សាយបន្ថែមអំពីឥណទានគេហដ្ឋាននេះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។

ឯកសារយោង

ឯកសារយោង

ឯកសារជាខេមរភាសា

- ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, លេខ នស/រកម/១១៩៩/១៣, ០៣ វិច្ឆិកា ១៩៩៩, មាត្រា១ និងមាត្រា២។
- ប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមរ៉ែមិន, លេខ ធ៧-០១៧-៣៥៤ ប្រ.ក, ០១ ធ្នូ ២០១៧, ប្រការ២ ដល់ប្រការ៤។
- ប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, លេខ ធ៧ ០១៦ ១១៧ ប្រ.ក, ២៣ មីនា ២០១៦, ប្រការ៣ និងប្រការ៤។
- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, ២០១៧, គោលការណ៍ឥណទានគេហដ្ឋាន។
- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, ២០១៨, គោលការណ៍ណែនាំដោះស្រាយបំណុល។
- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, ២០១៨, របាយការណ៍ប្រចាំឆ្នាំ។
- ឈាង ហ៊ីយ, គ្មានកាលបរិច្ឆេទ, Credit Management, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣ (ឯកសារបន្ថែម), សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ឈាង ហ៊ីយ, គ្មានកាលបរិច្ឆេទ, Credit Management, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- សួន ចំរើន, ២០០៧, ស្ថាប័នទីផ្សារ និងហិរញ្ញវត្ថុ, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- សួន ចំរើន, ២០១៣, រូបិយវត្ថុ និងធនាគារ, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ឯកសារជាភាសាបរទេស

- Anthony S., 2010. *Credit Risk Measurement In and Out of the Financial Crisis*"។
- Peter S. Rose និង Sylvia C.Hudgins. 2013. *Bank Management & Financial Service*. Ninth Edition"។

ឯកសារជាគេហទំព័រ

- http://www.cambodiapostbank.com (ចូលទស្សនាថ្ងៃទី ០៣ មេសា ២០១៩) ។
- https://www.nbc.org.kh (ចូលមើលថ្ងៃទី ០៨ ឧសភា ២០១៩) ។

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

ធនាគារ ប្រៃសណីយ៍កម្ពុជា ភ.អ
柬埔寨邮政银行 CAMBODIA POST BANK PLC.

ពាក្យស្នើសុំខ្ចីឥណទាន (លើកទី.....)

១-ឈ្មោះ..... អក្សរឡាតាំង.....ភេទ.....ឯកសារសម្គាល់អត្តសញ្ញាណ:..... លេខ.....
មុខរបរ..... និង ឈ្មោះ:..... អក្សរឡាតាំង.....ភេទ.....
ឯកសារសម្គាល់អត្តសញ្ញាណ:..... លេខ..... ត្រូវជា..... មុខរបរ.....
ទីកន្លែងប្រកបមុខរបរ.....
២-អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ.....ក្រុមទី.....ផ្លូវលេខ..... ភូមិ.....ឃុំ-សង្កាត់.....
ក្រុង-ស្រុក-ខណ្ឌ.....រាជធានី-ខេត្ត.....ទូរស័ព្ទ/ទូសារ លេខ.....

សូមគោរពជូនមក

លោក នាយក-នាយិកា ធនាគារ ប្រៃសណីយ៍កម្ពុជា ភ.អ សាខា.....

ក្រោយពីបានយល់ជ្រួតជ្រាបពីផលិតផល និងសេវាកម្មរបស់ធនាគារ យើងខ្ញុំសន្យាអនុវត្តតាមទាំងស្រុងលើគោលការណ៍ និងលក្ខខណ្ឌរួមនៃ ឥណទានរបស់ធនាគារ និងសុំបើកគណនីទូទាត់ (Settlement Account) ដើម្បីទូទាត់សងឥណទាន និងប្រើប្រាស់ជាគណនីបញ្ជើសំចៃ ។

ការស្នើសុំ	☐ ស្នើសុំ ☐ ស្នើសុំបន្ថែម	កំពុងប្រើប្រាស់	☐ មាន ☐ គ្មាន
ទំហំឥណទាន		ទំហំឥណទាន	
រយៈពេលខ្ចី		រយៈពេលខ្ចី	
អត្រាការប្រាក់		អត្រាការប្រាក់	
គោលបំណងប្រើប្រាស់		សមតុល្យឥណទាន	
		គោលបំណងប្រើប្រាស់	

- **សរុបឥណទានទាំងអស់ចំនួន (Aggregate Amount):** .....

ដើម្បីជាសក្តីភាពនៃសំណើសុំខ្ចីឥណទានខាងលើ យើងខ្ញុំសូមជូនភ្ជាប់មកជាមួយនេះនូវ ៖

☐ ១- ច្បាប់ថតចម្លងឯកសារសម្គាល់អត្តសញ្ញាណ ☐អ្នកខ្ចី ☐អ្នករួមខ្ចី ☐អ្នកធានា ☐អ្នករួមធានា ☐អ្នកបញ្ចាំជំនួស ..... ច្បាប់
☐ ២- ច្បាប់ដើមឯកសារសម្គាល់កម្មសិទ្ធិ(ប្លង់ដី) ☐អ្នកខ្ចី ☐អ្នករួមខ្ចី ☐អ្នកធានា ☐អ្នករួមធានា ☐អ្នកបញ្ចាំជំនួស..... ច្បាប់
☐ ៣- ច្បាប់ថតចម្លងឯកសារបញ្ជាក់ពីប្រវត្តិការងារ ប្រាក់បៀវត្ស..... ច្បាប់
☐ ៤- ផ្សេងៗ..... ច្បាប់

បើធនាគារត្រូវការព័ត៌មានខាងលើបន្ថែមនៅពេលនេះ ឬក្នុងពេលកំពុងប្រើប្រាស់ឥណទាន យើងខ្ញុំនឹងបំពេញបន្ថែមតាមតម្រូវការ ។ យើងខ្ញុំសូមសន្យាថានឹងផ្តល់នូវការប្រែប្រួល ទាក់ទងនឹងស្ថានភាពគ្រួសារ ក្រុមហ៊ុន ទ្រព្យសម្បត្តិ និងរាល់ព្រឹត្តិការណ៍ឯទៀតបើធនាគារមានតម្រូវការ ។

ការយល់ព្រម

ខ្ញុំបាទ/នាងខ្ញុំ យល់ព្រមឲ្យធនាគារ ប្រៃសណីយ៍កម្ពុជា ភ.អ ប្រមូលព័ត៌មានដែលមាននៅក្នុងពាក្យស្នើសុំ និងព័ត៌មានដទៃទៀតដែលពាក់ព័ន្ធនឹងពាក្យសុំនេះ ព្រមទាំងបើកចំហព័ត៌មានទាំងនេះទៅឲ្យតតិយជន សម្រាប់គោលបំណងដូចមានចែងក្នុងប្រការ ៨ នៃប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទាន ។

ខ្ញុំបាទ/នាងខ្ញុំយល់ថា ក្រុមហ៊ុន ក្រេឌីត ប្យូរ (ខេមបូឌា) ខ្ជ អិលធីឌី និងធនាគារ ប្រៃសណីយ៍កម្ពុជា ភ.អ ទទួលខុសត្រូវលើការប្រមូលការដាក់ឲ្យដំណើរការ និងការផ្សព្វផ្សាយទិន្នន័យ ។ ខ្ញុំបាទ/នាងខ្ញុំមានសិទ្ធិទទួលព័ត៌មាន និងទិន្នន័យរបស់ខ្ញុំ និងមានសិទ្ធិតវ៉ា ដើម្បីស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យទាំងនោះ ប្រសិនបើមានហេតុផលគ្រប់គ្រាន់ស្របតាមនីតិវិធី ដូចមានចែងក្នុងប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទាន និង/ឬ ក្រមប្រតិបត្តិ ។

យើងខ្ញុំសូមសន្យា និងអះអាងថា ប្រាក់កម្ចីដែលស្នើសុំនេះ សម្រាប់តែប្រើប្រាស់ក្នុងគោលបំណងដូចបានបញ្ជាក់នៅខាងលើ ។ ក្នុងករណីយើងខ្ញុំប្រើប្រាស់កម្ចីនេះខុសពីគោលបំណងប្រើប្រាស់ យើងខ្ញុំយល់ព្រមបង្វៃប្រាក់កម្ចីទាំងអស់ រួមទាំងការប្រាក់សងមកធនាគារវិញ មិនឲ្យលើសពីរយៈពេល ៣០ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងពីធនាគារ ។

សូមលោក-លោកស្រី នាយក-នាយិកា ធនាគារ ប្រៃសណីយ៍កម្ពុជា ភ.អ ទទួលនូវការគោរពរាប់អាន ដ៏ជ្រាលជ្រៅអំពីយើងខ្ញុំ ។

> រាល់ការខ្ចីប្រាក់ ធនាគារមិនតម្រូវឲ្យអតិថិជនផ្តល់កម្រៃជាសាច់ប្រាក់ ឬផលប្រយោជន៍ណាមួយដល់បុគ្គលិក ក្នុងការទទួលប្រាក់កម្ចីពីធនាគារនោះទេ លើកលែងតែការបង់សោហ៊ុយចំណាយឥណទាន និងការចំណាយលើCBC។ ករណីមានជនណាទាមទារកម្រៃ ឬផលប្រយោជន៍ សូមជូនដំណឹងមកទូរស័ព្ទលេខ 070 200 002 / 023 220 772។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចសន្យាធានា

១- ឈ្មោះ.....ភេទ.....សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត.....ឯកសារកំណត់អត្តសញ្ញាណ:.....
លេខ.....ទូរស័ព្ទលេខ..... មុខរបរ.....
និងឈ្មោះ.....ភេទ..... សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត.....ត្រូវជា..... មុខរបរ.....
២- អាសយដ្ឋានបច្ចុប្បន្ន : ផ្ទះលេខ.....ក្រុមទី.....ផ្លូវលេខ.....ភូមិ.....
ឃុំ-សង្កាត់.....ក្រុង-ស្រុក-ខណ្ឌ.....ខេត្ត-រាជធានី.....

ក្រោយពីបានអានន្យកិច្ចសន្យាខ្ចីប្រាក់របស់ឈ្មោះ.....និងឈ្មោះ.....
មានអាសយដ្ឋានបច្ចុប្បន្ន :ផ្ទះលេខ.....ក្រុមទី.....ផ្លូវលេខ.....ភូមិ..... ឃុំ-សង្កាត់.....
ក្រុង-ស្រុក-ខណ្ឌ.....ខេត្ត-រាជធានី.....ជាភាគី«ខ» ដែលជាកូនបំណុលរបស់ធនាគារ
ប្រៃសណីយ៍កម្ពុជា អ.ក សាខា..... ជាភាគី«ក» យើងខ្ញុំបានយល់ច្បាស់ពីខ្លឹមសារគ្រប់ចំណុចទាំងអស់
ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ ហើយបានព្រមព្រៀងគ្នាធានាបំណុលទាំងស្រុងរបស់ភាគី«ខ» ចំនួន.....
(.....)ដោយយល់ព្រមចុះកិច្ចសន្យាធានា និងអនុវត្តតាមលក្ខខ្លួនប្រការដូចខាងក្រោម:

ប្រការ ១ : យើងខ្ញុំ សូមធានាអ:អាងលើបំណុលនេះទាំងស្រុង ប្រសិនបើភាគី«ខ» មិនបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យាខ្ចីប្រាក់ដោយប្រការណាមួយនោះ យើងខ្ញុំសូមធានាទទួលខុសត្រូវ និងបង់ប្រាក់បំណុលសងជំនួស ទាំងស្រុងដោយគ្មានលក្ខខណ្ឌ ។

ប្រការ ២ : ដើម្បីជាភស្តុតាងបញ្ជាក់លើកិច្ចសន្យាធានា យើងខ្ញុំសូមដាក់ទ្រព្យសម្បត្តិដូចខាងក្រោម ៖

	ប្រភេទទី ០១	ប្រភេទទី ០២
ប្រភេទទ្រព្យ		
ទីតាំងទ្រព្យ		
ទំហំ		
ព្រំប្រទល់ : ខាងជើង		
ខាងត្បូង		
ខាងលិច		
ខាងកើត		

ប្រការ ៣ : បើពុំប្រាកដ ដូចកិច្ចសន្យាធានាដោយប្រការណាមួយនោះ យើងខ្ញុំសុខចិត្តលក់ទ្រព្យសម្បត្តិអ:អាងធានាខាងលើ ឬឲ្យភាគី«ក» ប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬទៅតុលាការ ដើម្បីរឹបអូសទ្រព្យសម្បត្តិដាក់ធានាបំណុលនេះ លក់ឡាយឡុង ដើម្បីយកប្រាក់មកទូទាត់បំណុលជំនួសភាគី«ខ» ដែលនៅជំពាក់ភាគី«ក» ឲ្យបានគ្រប់ចំនួន រួមទាំងប្រាក់ដើម ទាំងការប្រាក់ និងប្រាក់ពិន័យផង ។ ក្នុងករណីមិនទាន់សងគ្រប់ ត្រូវបន្តកាតព្វកិច្ចសងបំណុលដែលនៅសល់បន្ថែមទៀត រហូតទាល់តែគ្រប់ចំនួន ។

យើងខ្ញុំទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ នូវរាល់ករណីដែលយើងខ្ញុំបានប្រព្រឹត្តប្រាសចាកពីកិច្ចសន្យាធានា ។

យើងខ្ញុំសូមផ្ទិតមេដៃស្តាំទុកជាភស្តុតាងតាមផ្លូវច្បាប់ ។

ធ្វើនៅ ថ្ងៃទី.....ខែ.....ឆ្នាំ.....

សាក្សី

ស្នាមមេដៃស្តាំអ្នកធានា

ឈ្មោះ.....
លេខ.....
<u>បានឃើញ និងបញ្ជាក់ថា</u> : សេចក្តីបញ្ជាក់របស់
លោកមេភូមិ.....
ខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន ។
ថ្ងៃទី.....ខែ.....ឆ្នាំ.....
មេឃុំ-ចៅសង្កាត់.....

ហត្ថលេខា និងត្រា

ឈ្មោះ.....
<u>បានឃើញ និងបញ្ជាក់ថា</u> :
ឈ្មោះ.....និង ឈ្មោះ.....
ពិតជាបានយល់ព្រមដាក់ទ្រព្យសម្បត្តិ ដែលបានរៀបរាប់ខាងលើអ:អាងធានាភាគី«ខ» ពិតប្រាកដមែន ហើយទ្រព្យសម្បត្តិ ដូចបានរៀបរាប់ខាងលើ ពុំមានពាក់ព័ន្ធបញ្ហាទំនាស់អ្វីឡើយ ។
ថ្ងៃទី.....ខែ.....ឆ្នាំ.....
មេភូមិ.....

ហត្ថលេខា និងឈ្មោះ

ប្រការ ២ : ប្រាក់កម្ចី និងសុវត្ថិភាព

២.១ ទ្រព្យសម្បត្តិដាក់បញ្ចាំ/ហ៊ីប៊ូតែក ដើម្បីធានាបំណុលដែលភាគី "ក" យល់ព្រមទទួលនោះគឺ:

- អចលនវត្ថុ/ចលនវត្ថុរបស់ឈ្មោះ.....និងឈ្មោះ..... ដែលបានបញ្ជាក់ក្នុងកិច្ចសន្យាបង្កើតហ៊ីប៊ូតែក/ កិច្ចសន្យាដាក់បញ្ចាំលេខ.....ចុះថ្ងៃទី..... និងកិច្ចសន្យាបង្កើតហ៊ីប៊ូតែក/ក្នុងកិច្ចសន្យាដាក់បញ្ចាំ លេខ..... ចុះថ្ងៃទី.....។

២.២ ក្នុងករណីភាគី"ខ" ខកខានមិនបានបង់ប្រាក់ទាន់ពេលវេលាតាមតារាងកាលវិភាគសងប្រាក់លើសពីរថ្ងៃ ភាគី"ខ" ត្រូវបង់ប្រាក់ពិន័យ ។ អត្រាពិន័យត្រូវបានគិតស្មើនឹង២៨ភាគរយ ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង សមាមាត្រទៅនឹងចំនួនថ្ងៃដែលខកខានសង គិតចាប់ពីថ្ងៃទី០១ តែមិនត្រូវតិចជាងចំនួន៥ដុល្លារអាមេរិកឡើយ ហើយយល់ព្រមបង់ដោយផ្ទាល់ ឬយល់ព្រមឲ្យកាត់យកជាស្វ័យប្រវត្តិពីគណនីរបស់ភាគី "ខ"។

២.៣ ក្នុងករណីដែលភាគី"ខ" ខកខានមិនបានសងប្រាក់តាមកាលកំណត់ណាមួយ នៅក្នុងរយៈពេលនៃកិច្ចសន្យា ដោយការយឺតយ៉ាវនោះ មានសភាពធ្ងន់ធ្ងរ ហើយភាគី"ក" យល់ឃើញថា អាចនឹងបាត់បង់បំណុលទាំងស្រុង ឬចំណែកណាមួយ ភាគី"ខ"ឯកភាពទាំងស្រុងដោយគ្មានលក្ខខណ្ឌក្នុងការលុយកិច្ចសន្យាមុនកាលកំណត់ តាមរយៈបណ្តឹងរបស់ភាគី"ក" ហើយភាគី"ខ" ត្រូវទូទាត់បំណុលមកភាគី"ក" ឲ្យគ្រប់ចំនួនទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ។

២.៤ ក្នុងករណីការខកខានមិនបានសងដូចមានចែងក្នុងចំណុច ១.២ បន្តរហូតដល់លើសពី ៣០ថ្ងៃ នោះភាគី"ក" ឬអ្នកធានាបំណុល ដែលបានសងឥណទានជំនួសនឹងប្តឹងទៅតុលាការ ដើម្បីបែអូសទ្រព្យសម្បត្តិជាចលនវត្ថុ ឬអចលនវត្ថុបានបង្កើតហ៊ីប៊ូតែក/ដាក់បញ្ចាំ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនផ្សេងទៀត លក់ឡាយឡុង ដើម្បីទូទាត់បំណុលដែលបានសងជំនួស ឬ/និងនៅជំពាក់ឲ្យបានគ្រប់ចំនួនរួមទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យផង ក្នុងករណីមិនគ្រប់ចំនួន ភាគី"ខ"នៅជាប់ភាពកិច្ចជាកូនបំណុលរបស់ភាគី"ក"ដដែល ហើយត្រូវបន្តសងរហូតដល់គ្រប់ចំនួន។

២.៥ ក្នុងករណីភាគី"ខ" ខកខានមិនបានសងប្រាក់ ហើយបំណុលទាំងមូលត្រូវបានសងត្រឡប់មកធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ វិញ ដោយអ្នកធានា សាច់ញាតិ ឬ តតិយជនណាម្នាក់ ភាគី"ខ" ឯកភាពឲ្យធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បង្វែរទ្រព្យសម្បត្តិទាំងអស់ ឬមួយចំណែកណាមួយ ព្រមទាំងឯកសារសំគាល់ម្ចាស់កម្មសិទ្ធិ ដែលខ្លួនបានបង្កើតហ៊ីប៊ូតែក/បានដាក់បញ្ចាំជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទៅអ្នកដែលបានសងបំណុលជំនួសខ្លួន ដោយមិនតម្រូវឲ្យមានរៀបចំបែបបទអ្វីផ្សេងទៀតឡើយ។ ភាគី"ក" មិនទទួលខុសត្រូវលើការបាត់បង់ ខូចខាត ឬបាត់ប្រយោជន៍ លើទ្រព្យសម្បត្តិខាងលើឡើយ ហើយភាគី"ខ" ក៏បានឯកភាពជាមុនថា មិនទាមទារតវ៉ា ឬប្តឹងផ្តល់អ្វីឡើយជាមួយភាគី"ក"។

២.៦ ភាគី"ខ" អះអាងថាទ្រព្យសម្បត្តិដែលបានបង្កើតហ៊ីប៊ូតែក/ដាក់បញ្ចាំ ដែលបានបញ្ជាក់ក្នុងប្រការ២ ខាងលើពិតជាកម្មសិទ្ធិស្របច្បាប់ផ្ទាល់របស់ខ្លួនដោយពុំមានជាប់ពាក់ព័ន្ធនឹងបញ្ហាអ្វីមួយ ឬជនណាមួយឡើយ ដែលធ្វើឲ្យបាត់បង់ភាពកិច្ចជាកម្មសិទ្ធិករ ហើយលើផ្នែកនេះនឹងទទួលខុសត្រូវចំពោះមុខច្បាប់ និងសន្យាថែរក្សា គ្រប់គ្រងគេហដ្ឋានរហូតដល់បំណុលសងចប់។

២.៧ ភាគី"ខ" យល់ព្រមឲ្យភាគី"ក" ចុះពិនិត្យសកម្មភាពអាជីវកម្មរបស់ខ្លួនគ្រប់ពេលវេលា បើទោះបីឥណទានសងទៀងទាត់ក៏ដោយ។

ប្រការ ៣ : ការធ្លាប់ជ្ជារបស់គូភាគី

គូភាគីនៃកិច្ចសន្យាបានបញ្ជាក់អះអាងថា នឹងគោរពយ៉ាងម៉ឹងម៉ាត់តាមរាល់ប្រការនៃកិច្ចសន្យាខាងលើ។ នៅក្នុងករណីមានការអនុវត្តមិនត្រឹមត្រូវតាមប្រការ ឬចំណុចណាមួយនៃកិច្ចសន្យានេះ ភាគីដែលល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ រាល់សោហ៊ុយចំណាយទាក់ទងនឹងការដោះស្រាយវិវាទ ជាបន្ទុកចំណាយរបស់ភាគី ដែលល្មើសបំពានកិច្ចសន្យា។

កិច្ចសន្យានេះ ត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងពិតប្រាកដ និងដោយសេរី គ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃផ្តិតមេដៃ និងចុះហត្ថលេខានេះតទៅ។

ធ្វើនៅថ្ងៃទី.....ខែ.....ឆ្នាំ.....

	ស្នាមមេដៃស្តាំ	**តំណាងភាគី "ក"**
ភាគី "ខ"	**អ្នកធានាកំណ្ចខ្ចីប្រាក់**	**ហត្ថលេខា និងត្រា**
ឈ្មោះ.....	ឈ្មោះ.....	.....
អ្នកស្ងួតមរតក	**សាក្សី**	
ឈ្មោះ.....	ឈ្មោះ.....	

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចសន្យាខ្ចីប្រាក់ (ឥណទានគេហដ្ឋាន)

<u>កិច្ចសន្យានេះធ្វើឡើងរវាង</u>

១- **ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខា**..... តំណាងស្របច្បាប់ដោយលោក/លោកស្រី..... មានតួនាទីជា..... ជាភាគីឲ្យខ្ចីប្រាក់ គ្រទៅនេះហៅកាត់ថា ភាគី"**ក**" និង

២- លោក/លោកស្រី ឈ្មោះ..... ភេទ..... ឯកសារសម្គាល់អត្តសញ្ញាណ:..... លេខ..... និងឈ្មោះ..... ភេទ..... ឯកសារសម្គាល់អត្តសញ្ញាណ:..... លេខ..... ត្រូវជា..... ទីលំនៅបច្ចុប្បន្នផ្ទះលេខ..... ផ្លូវលេខ..... ភូមិ/មណ្ឌល..... ឃុំ/សង្កាត់..... ស្រុក/ខណ្ឌ/ក្រុង..... ខេត្ត/រាជធានី.....គ្រទៅនេះហៅកាត់ថា ភាគី"**ខ**"។

ភាគីទាំងពីរនៃកិច្ចសន្យាគ្រទៅនេះ ហៅកាត់ថា "**ភាគី**" ។

ភាគីនៃកិច្ចសន្យាបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដោយអនុវត្តតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ប្រការ ១ : ប្រាក់កម្ចី និងលក្ខខណ្ឌ

យោងលើពាក្យស្នើសុំខ្ចីឥណទាន សម្រង់ព័ត៌មាននិងគម្រោងជំនួញ និងការប្រើប្រាស់ឥណទាន ភាគី"**ក**" បានយល់ព្រមឲ្យភាគី"**ខ**" ខ្ចីប្រាក់ ហើយភាគី"**ខ**" ក៏បានសន្យាយ៉ាងជាក់ច្បាស់ ជាមួយភាគី"**ក**" ថានឹងសងប្រាក់កម្ចីចងការនេះតាមចំនួន និងគោរពតាមលក្ខខណ្ឌ ដែលបានព្រមព្រៀងគ្នា ដូចខាងក្រោម៖

១.១ ប្រាក់កម្ចី តម្រៃ និងលក្ខខណ្ឌ

- ភាគី"**ខ**"បានទទួលប្រាក់កម្ចីចំនួនជាលេខ:.....ជាអក្សរ..... ភាគី"**ក**"នឹងផ្ទេរចំនួនទឹកប្រាក់កម្ចីនេះចូលគណនីរបស់ភាគីអ្នកលក់គេហដ្ឋាន ឬបើកជូនទៅអ្នកលក់គេហដ្ឋានដោយផ្ទាល់នូវចំនួនទឹកប្រាក់កម្ចីទាំងអស់តែមួយលើក បន្ទាប់ពីបានព្រមព្រៀង និងផ្តិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់។
- រយៈពេលខ្ចីចងការប្រាក់.....ខែ គិតចាប់ពីថ្ងៃផ្ទេរប្រាក់ចូលគណនីទូទាត់របស់ភាគី"**ខ**"។
- អត្រាការប្រាក់.....ភាគរយ/ខែ ។ ភាគី"**ខ**" ឯកភាពទទួលយកការកែប្រែអត្រាការប្រាក់ផ្អែកទៅលើ ថ្លៃដើម និងចំណាយប្រតិបត្តិការរបស់ធនាគារ ដោយរក្សាលក្ខខណ្ឌផ្សេងៗទៀតនៅដដែល តាមរយៈការជូនដំណឹងជាលាយលក្ខអក្សរពីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ។ ករណីមិនមានការជូនដំណឹងជាលាយលក្ខអក្សរ ភាគីទាំងពីរឯកភាពរក្សាអត្រាការប្រាក់នៅដដែល។
- ភាគី"**ខ**" យល់ព្រមបង់តម្រៃសេវាឥណទានស្មើនឹង ១% នៃទំហំឥណទានដែលបានអនុម័ត។
- ភាគី"**ខ**" យល់ព្រមបង់តម្រៃរដ្ឋបាលស្មើនឹង ១% នៃទំហំឥណទានដែលបានអនុម័ត។
- ភាគី"**ខ**" យល់ព្រមបង់តម្រៃសេវាផ្ទៀងផ្ទាត់ព័ត៌មានឥណទាន ក្នុងប្រព័ន្ធ ក្រេឌីតប្យូរ៉ូ ខេមបូឌា (CBC) ចំនួន.....

១.២ ការបើកប្រាក់: ភាគី"**ខ**" ត្រូវផ្តិតមេដៃលើប័ណ្ណដកប្រាក់ និងតារាងកាលវិភាគសងប្រាក់ ហើយភាគី"**ខ**" ព្រមព្រៀងផ្តល់សិទ្ធិឲ្យភាគី"**ក**" ដកសាច់ប្រាក់ពីគណនីភាគី"**ខ**" ទៅឲ្យអ្នកលក់គេហដ្ឋាន ឬផ្ទេរសាច់ប្រាក់ចូលទៅក្នុងគណនីអ្នកលក់គេហដ្ឋានដែលមានគណនីនៅធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ឬបើកប្រាក់ធ្វើឡើងតាមរយៈមូលប្បទានប័ត្រអ្នកលក់គេហដ្ឋាន។

១.២ ការសងប្រាក់ដើម និងការប្រាក់: ត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់ ដែលជាឧបសម្ព័ន្ធរបស់កិច្ចសន្យានេះ ដោយបង់ប្រាក់ផ្ទាល់ ឬកាត់ចេញដោយស្វ័យប្រវត្តិពីគណនីទូទាត់របស់ភាគី"**ខ**"។

១.៣ ការបង់ផ្តាច់មុនកាលកំណត់: ភាគី"**ខ**" ត្រូវបង់សោហ៊ុយឥណទាន ៣% នៃទំហំសមតុល្យឥណទានប្រាក់ដើមដែលបង់ផ្តាច់នោះ។

១.៤ ការបង់ប្រាក់មួយចំនួនមុនកាលកំណត់: ភាគី"**ខ**"ត្រូវបង់សោហ៊ុយឥណទាន២% នៃទំហំសមតុល្យឥណទាន ប្រាក់ដើមដែលបង់អុះកាលកំណត់។ ការបង់ប្រាក់ដើមមុនកាលកំណត់រហូតដល់២៥%នៃសមតុល្យឥណទានក្នុងមួយឆ្នាំ មិនតម្រូវឲ្យបង់សោហ៊ុយទេ។ ចំនួនលើកនៃការបង់មុនកាលកំណត់មិនឲ្យលើសពីដងក្នុងមួយឆ្នាំ។

១.៥ ទីកន្លែងបង់ប្រាក់ និងឧបសម្ព័ន្ធ ៖

- ភាគី "**ខ**" យល់ព្រមមកទទួលប្រាក់កម្ចី និងសងប្រាក់មកវិញនៅការិយាល័យ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។
- តារាងកាលវិភាគសងប្រាក់ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក / កិច្ចសន្យាដាក់បញ្ចាំ ជាឧបសម្ព័ន្ធនៃកិច្ចសន្យានេះ។

១.៦ ភាគី"**ខ**"សន្យាប្រើប្រាស់ប្រាក់កម្ចីសម្រាប់តែគោលបំណងដែលបានបរិយាយនៅក្នុងពាក្យស្នើសុំខ្ចីចងការប្រាក់ប៉ុណ្ណោះ ក្នុងករណីដែលភាគី"**ខ**"បានប្រើប្រាស់កម្ចីនេះ ខុសពីពាក្យស្នើសុំរបស់ខ្លួន ភាគី"**ខ**"ឯកភាពបង្វែរប្រាក់កម្ចីទាំងអស់មកភាគី"**ក**" ដោយអនុវត្តតាមលក្ខខណ្ឌក្នុងចំណុច ១.៣ មិនឲ្យលើសពីរយៈពេល៣០ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងពីភាគី"**ក**"។ ប្រសិនបើភាគី"**ខ**" មិនមានលទ្ធភាពសងបំណុលតាមការជូនដំណឹង ភាគី"**ខ**"សុខចិត្តលក់ទ្រព្យសម្បត្តិដែលបានចុះកិច្ចសន្យាដាក់បញ្ចាំ/បង្កើតហ៊ីប៉ូតែក ក្នុងតម្លៃឡាយឡុង ដើម្បីយកប្រាក់កាត់សងបំណុលទាំងអស់ដែលជំពាក់ភាគី"**ក**"។ ករណីដែលមិនមានការជូនដំណឹងជាលាយលក្ខអក្សរទេនោះ មានន័យថា ភាគី"**ក**" ឯកភាពទទួលយកហានិភ័យនៃការប្រើប្រាស់ឥណទានខុសពីពាក្យស្នើសុំឥណទាន។

១.៧ ភាគី"**ខ**"ត្រូវទិញប័ណ្ណធានាវ៉ាស៊ីរង៉ាអគ្គិភ័យលើអចលនវត្ថុដែលបានបង្កើតហ៊ីប៉ូតែក/ដាក់បញ្ចាំ ធានាប្រាក់កម្ចីក្នុងរយៈពេលជាប់បំណុល បន្ទាប់ពីធនាគារ ទូទាត់ប្រាក់ជាមួយអ្នកលក់រួចរាល់ ហើយត្រូវបង្ហាញឯកសារភស្តុតាងចំពោះការទិញនោះបកធនាគារម្តងរៀងរាល់មួយឆ្នាំម្តង។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតស្នើសុំក្សាទុកឯកសារកម្មសិទ្ធិនៅធនាគារ

□ យោងពាក្យស្នើសុំខ្ញុំឥណទានថ្ងៃទី.....ខែ.....ឆ្នាំ.....

នាងខ្ញុំ / ខ្ញុំបាទឈ្មោះ.....ភេទ.....ឯកសារកំណត់អត្តសញ្ញាណ:..... លេខ:.....
និងឈ្មោះ.....ភេទ..... ឯកសារកំណត់អត្តសញ្ញាណ:.....លេខ.....ត្រូវជា.....
អាសយដ្ឋានបច្ចុប្បន្ន:ផ្ទះលេខ.....ផ្លូវលេខ.....ក្រុមទី.....ភូមិ..... ឃុំ-សង្កាត់.....
ខណ្ឌ-ក្រុង-ស្រុក.....រាជធានី-ខេត្ត..... ។

ខ្ញុំ/យើងខ្ញុំ សូមជម្រាបជូន លោក-លោកស្រី ដែលជាតំណាង ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទទួលជ្រាបថា: ដើម្បីការពារនៅហានិភ័យផ្សេងៗ ដែលអាចកើតមាន និងចៀសវាងការបាត់បង់ឯកសារកម្មសិទ្ធិ ដើម្បីបញ្ជាក់លើការអះអាងធានាបន្ថែមលើការខ្ចីប្រាក់ពីធនាគារ ខ្ញុំ/យើងខ្ញុំ សូមស្នើសុំប្រគល់ដោយស្ម័គ្រចិត្តជូនធនាគារ ក្សាទុកនូវឯកសារកម្មសិទ្ធិអចលនវត្ថុ ហួតដល់សងបំណុលទាំងឡាយដែលបានខ្ចីជាមួយធនាគាររួចរាល់ ដូចខាងក្រោម ៖

	ប្រភេទទី១	ប្រភេទទី២
ប្រភេទឯកសារកម្មសិទ្ធិ		
លេខឯកសារកម្មសិទ្ធិ		
កាលបរិច្ឆេទចេញឯកសារ		
សមត្ថកិច្ចចេញឯកសារ		

ខ្ញុំ/យើងខ្ញុំ សូមធានាអះអាងថាឯកសារកម្មសិទ្ធិខាងលើនេះពិតជាកម្មសិទ្ធិរបស់ខ្ញុំ/យើងខ្ញុំពិតប្រាកដ ដោយពុំមានពាក់ព័ន្ធនឹងជនណាមួយ ដែលធ្វើឲ្យបាត់បង់នូវភាពជាកម្មសិទ្ធិករឡើយ បើផ្ទុយពីនេះ ខ្ញុំ/យើងខ្ញុំហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់ ។

ចំពោះលក្ខខណ្ឌនៃការប្រគល់-ទទួលឯកសារកម្មសិទ្ធិ ដែលបានស្នើសុំក្សាទុកនៅធនាគារ និងបន្ទាប់ពីការសងបំណុលរួចរាល់ ត្រូវអនុវត្តតាមលក្ខខណ្ឌ ទទួលនិងប្រគល់លិខិតកម្មសិទ្ធិម្នាក់ ក្នុងចំណោមអ្នកខ្ចី/អ្នកដាក់បញ្ចាំ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រី តំណាងធនាគារ មេត្តាទទួល និងក្សាទុកនូវឯកសារកម្មសិទ្ធិរបស់ខ្ញុំ/យើងខ្ញុំ ដោយសេចក្តីអនុគ្រោះ ។

ធ្វើនៅ.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

ស្នាមមេដៃស្តាំ
សាក្សី

ស្នាមមេដៃស្តាំ
ភាគីអ្នកស្នើសុំ

ឈ្មោះ..... ឈ្មោះ..... ឈ្មោះ.....

ការបញ្ជាក់របស់តំណាងភាគីធនាគារ

បានឃើញ និងយល់ព្រមទទួលយកឯកសារកម្មសិទ្ធិរបស់លោក.....
លោកស្រី.....មកក្សាទុកនៅធនាគារតាមការស្នើសុំ ។

ថ្ងៃទី.....ខែ.....ឆ្នាំ.....

ហត្ថលេខា និងត្រា

ប្រការ ៣ : លក្ខខណ្ឌរបស់ការ

គូភាគីនៃកិច្ចសន្យាបានអះអាងថា នឹងគោរពយ៉ាងម៉ឹងម៉ាត់តាមរាល់ប្រការក្នុងកិច្ចសន្យានេះ ។ ក្នុងករណីមានការអនុវត្តរំលោភលើលក្ខខណ្ឌនៃកិច្ចសន្យា ភាគីដែលល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។ រាល់ការចំណាយទាក់ទងក្នុងការដោះស្រាយវិវាទនៃកិច្ចសន្យានេះ ជាបន្ទុករបស់ភាគីដែលរំលោភបំពានលើកិច្ចសន្យា ។

កិច្ចសន្យាបង្កើតហ៊ីប៉ូតែកនេះត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងពិតប្រាកដ និងគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ និងមានប្រសិទ្ធភាពចាប់ពីថ្ងៃផ្តិតមេដៃ និង ចុះហត្ថលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី.....ខែ.....ឆ្នាំ.....

ស្នាមមេដៃស្តាំ
ភាគី"ខ"

តំណាងភាគី "ក"
ហត្ថលេខា និងត្រា

ឈ្មោះ.....

.....

អ្នកស្នងមរតក

ឈ្មោះ.....

លេខ:.....

បានឃើញ និងបញ្ជាក់ថា :
ស្នាមមេដៃស្តាំខាងលើនេះ ពិតជារបស់ភាគី"ខ" ប្រាកដមែន ។ ទ្រព្យសម្បត្តិ ដូចខាងលើ ពុំមានពាក់ព័ន្ធនឹងបញ្ហាអ្វីឡើយ ហើយភាគី"ខ"បានយល់ព្រមបង្កើតហ៊ីប៉ូតែកឲ្យធនាគារ ពិតប្រាកដមែន ។

ថ្ងៃទី.....ខែ.....ឆ្នាំ.....
មេភូមិ.....
ហត្ថលេខា

ឈ្មោះ.....

បានឃើញ និងបញ្ជាក់ថា : សេចក្តីបញ្ជាក់ របស់លោកមេភូមិ .....នេះពិតជាត្រឹមត្រូវប្រាកដមែន ។

ថ្ងៃទី.....ខែ.....ឆ្នាំ.....
មេឃុំ-ចៅសង្កាត់.....
ហត្ថលេខា និងត្រា

ឈ្មោះ.....

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

១ខាង

១- ភាគីទទួលយកការបង្កើតហ៊ីប៉ូតែក ៖ ធនាគារ ប្រែសណ៍យ៍កម្ពុជា ក.អ សាខា..... តទៅនេះហៅកាត់ថាភាគី "ក" និង
២- ភាគីបង្កើតហ៊ីប៉ូតែក ៖ ឈ្មោះ..... ភេទ..... ឯកសារសម្គាល់អត្តសញ្ញាណ:.....
លេខ..... និង ឈ្មោះ..... ភេទ..... ឯកសារសម្គាល់អត្តសញ្ញាណ:.....
លេខ..... ត្រូវជា..... អាសយដ្ឋានបច្ចុប្បន្ន: ផ្ទះលេខ.....ក្រុមទី.....ផ្លូវលេខ.....ភូមិ.....
ឃុំ-សង្កាត់..... ក្រុង-ស្រុក-ខណ្ឌ..... ខេត្ត-រាជធានី..... តទៅនេះហៅកាត់ថា ភាគី"ខ" ។
ភាគីទាំងពីរនៃកិច្ចសន្យាតទៅនេះហៅកាត់ថា "គូភាគី" ។

គូភាគីនៃកិច្ចសន្យាបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដោយអនុវត្តតាមរាល់ប្រការ ដូចខាងក្រោម:

ប្រការ ១ : លក្ខខណ្ឌទូទៅ

ភាគី"ខ"បានយល់ព្រមបង្កើតហ៊ីប៉ូតែកដោយស្ម័គ្រចិត្ត និងមានការព្រមព្រៀងពីក្រុមគ្រួសារឲ្យបង្កើតហ៊ីប៉ូតែកនូវអចលនវត្ថុ ដូចបានបញ្ជាក់ច្បាស់លាស់ នៅក្នុងតារាងខាងក្រោម ៖

	ប្រភេទទី ០១	ប្រភេទទី ០២
ប្រភេទទ្រព្យ		
ប្រភេទឯកសារកម្មសិទ្ធិ		
ទំហំទ្រព្យ		
ទីតាំងទ្រព្យ		
លេខឯកសារកម្មសិទ្ធិ		
កាលបរិច្ឆេទចេញឯកសារ		
សមត្ថកិច្ចចេញឯកសារ		

ដើម្បីធានាបំណុល: □ផ្ទាល់ខ្លួន □ធានាឲ្យឈ្មោះ.....អាយុ.....ឆ្នាំ ភេទ.....
និងឈ្មោះ..... អាយុ.....ឆ្នាំ ភេទ..... ទីលំនៅបច្ចុប្បន្នផ្ទះលេខ..... ក្រុមទី.....
ផ្លូវលេខ..... ភូមិ..... ឃុំ-សង្កាត់..... ក្រុង-ស្រុក-ខណ្ឌ..... ខេត្ត-រាជធានី.....

ប្រការ ២ : លក្ខខណ្ឌរួម

២.១- ភាគី"ខ" ធានាថា ទ្រព្យសម្បត្តិដែលចុះកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ពិតជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន ឬក្រុមហ៊ុន ដោយពុំមានពាក់ព័ន្ធនឹងជនណាមួយឡើយ បើផ្ទុយពីការអះអាងនេះ ខ្លួននឹងទទួលខុសត្រូវចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

២.២- ភាគី"ខ" សន្យាថា ធានាមិនធ្វើការចាត់ចែងសិទ្ធិណាមួយលើទ្រព្យដែលបានបង្កើតហ៊ីប៉ូតែក ដោយធ្វើការដោះដូរ លក់ ផ្ទេរ ហើយសន្យាថែរក្សា គ្រប់គ្រង ទ្រព្យឲ្យបានគង់វង្សល្អ រហូតសងបំណុលរួច ទើបភាគី"ខ" មានសិទ្ធិពេញលេញលើកម្មសិទ្ធិឡើងវិញ ។

២.៣- ករណីភាគី"ខ" គ្មានលទ្ធភាពសងបំណុលតាមតារាងកាលវិភាគសងប្រាក់ នៃកិច្ចសន្យាខ្ចីប្រាក់ដោយប្រការណាមួយក្រោមកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ភាគី"ក"នឹងប្តឹងទៅអាជ្ញាធរសមត្ថកិច្ច ឬតុលាការ ដើម្បីរឹបអូសទ្រព្យសម្បត្តិក្រោមកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនេះ លក់ឡាយឡុង ដើម្បីយកប្រាក់មកទូទាត់ បំណុលទាំងអស់ រួមទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យឲ្យបានគ្រប់ចំនួន ។ ករណីសងមិនទាន់គ្រប់ ភាគី"ខ" មានកាតព្វកិច្ចសងបំណុលដែលនៅជំពាក់រហូតទាល់តែគ្រប់ចំនួន ។

២.៤- ករណីភាគី"ខ" លួចធ្វើលិខិតកម្មសិទ្ធិផ្សេងលើទ្រព្យដែលបានចុះកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ភាគី"ក"នឹងប្តឹងទៅអាជ្ញាធរសមត្ថកិច្ចពីបទរំលោភលើសេចក្តីទុកចិត្ត ឬតម្រូវឲ្យសងប្រាក់ទាំងអស់មកធនាគារវិញ ក្នុងនោះរួមមាន ប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ឲ្យបានគ្រប់ចំនួន ដោយឥតលក្ខខណ្ឌ ។

យកប្រាក់មកទូទាត់បំណុលទាំងអស់ រួម ទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យឲ្យបានគ្រប់ចំនួន ។ ករណីសងមិនទាន់គ្រប់ ភាគី"ខ" មានកាតព្វកិច្ចសងបំណុលដែលនៅជំពាក់ហួតទាល់តែគ្រប់ចំនួន ។

២.៥- ករណីភាគី"ខ" លក់ ឬផ្ទេរទ្រព្យសម្បត្តិដែលបានចុះកិច្ចសន្យាដាក់បញ្ចាំទៅឲ្យជនទីបី ឬលួចចុះកិច្ចសន្យាដាក់បញ្ចាំជាភាគីទីបី ភាគី"ខ" ត្រូវទូទាត់បំណុលទាំងអស់ ឲ្យភាគី"ក" រួមទាំង ប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ឲ្យបានគ្រប់ចំនួន ដោយឥតលក្ខខណ្ឌ ។

២.៦- ករណីភាគី"ខ" លួចធ្វើលិខិតកម្មសិទ្ធិផ្សេងលើទ្រព្យដែលបានចុះកិច្ចសន្យាដាក់បញ្ចាំ ភាគី"ក"នឹងប្តឹងទៅអាជ្ញាធរសមត្ថកិច្ចពីបទរំលោកលើសេចក្តីទុកចិត្ត ឬតម្រូវឲ្យសងប្រាក់ទាំងអស់មកធនាគារវិញ ក្នុងនោះរួមមាន ប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យឲ្យបានគ្រប់ចំនួន ដោយឥតលក្ខខណ្ឌ ។

ប្រការ ៣ : លក្ខខណ្ឌអវសាន

គ្រាគីនៃកិច្ចសន្យាបានអះអាងថា នឹងគោរពយ៉ាងម៉ឺងម៉ាត់តាមរាល់ប្រការក្នុងកិច្ចសន្យានេះ ។ ក្នុងករណីមានការអនុវត្តរំលោកលើលក្ខខណ្ឌនៃកិច្ចសន្យា ភាគីដែលល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។ រាល់ការចំណាយទាក់ទងក្នុងការដោះស្រាយវិវាទនៃកិច្ចសន្យានេះ ជាបន្ទុករបស់ភាគីដែលរំលោកបំពានលើកិច្ចសន្យា ។

កិច្ចសន្យាដាក់បញ្ចាំនេះត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងពិតប្រាកដ និងគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ និងមានប្រសិទ្ធភាពចាប់ពីថ្ងៃផ្តិតមេដៃ និង ចុះហត្ថលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី.....ខែ.....ឆ្នាំ.....

ស្នាមមេដៃស្តាំ
ភាគី"ខ"

តំណាងភាគី "ក"
ហត្ថលេខា និងត្រា

ឈ្មោះ.....

.....

អ្នកសួងមរតក

ឈ្មោះ.....

លេខ:.....

